# អនុសាសន៍រៀបចំគម្រោង

## កម្មវិធីលើកកម្ពស់ចំណេះដឹងតាមសាលា

## ក្រសួងអប់រំ យុវជន និងកីឡា- ធនាគារអភិវឌ្ឍន៍អាស៊ី

# ពង្រាងចុងក្រោយ

**ធនធានបច្ចេកទេសផ្តល់ដោយៈ**

TA-7657 CAM: **កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំចុងក្រោយដំណាក់កាលទីបី** (ESDP III)

( ៤៣២៦០-០១២ )

**ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១២**

**ភ្នំពេញ ប្រទេសកម្ពុជា**

# មាតិកា

***ការប្រកាសបដិសេធ***
***តារាងអក្សរកាត់***

**១ សេចក្ដីផ្ដើម** ១
១.១ សាវតារ ១
១.២ គោលបំណង និងគោលដៅ ២

**២ ការពិចារណាពីការរៀបចំគម្រោងទូទៅ** ៣
**២.១ ម៉ូឌែលទ្រឹស្តីនៃការផ្លាស់ប្ដូរដើម្បីបង្កើនអត្រាការចូលរៀន** ៣
**២.២ រចនាសម្ព័ន្ធប្រតិបត្តិការ** ៦
**២.៣ លក្ខណៈសំខាន់ៗនៃការរៀបចំដែលបានស្នើរ និងភាពត្រឹមត្រូវរបស់វា** ៨
២.៣.១ តួនាទីរបស់ផែនការកែលម្អសាលារៀននៅក្នុងការរៀបចំ SBEP
២.៣.២ ការប្រើប្រាស់ម៉ឺនុយដើម្បីលើកកម្ពស់ភាពជាម្ចាស់ការ និងការតម្រូវតាមសកម្មភាពឲ្យត្រូវតាមបរិបទមូលដ្ឋាន
២.៣.៣ ចំណាត់ថ្នាក់នៃសាលារៀន និងសម្របសម្រួលនៅក្នុងការគាំទ្រជំនួយ
២.៣.៤ សកម្មភាពលើកកម្ពស់កម្មវិធីសិក្សាផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា
២.៣.៥ ការផ្ដោតលើលទ្ធភាពរកការងារ និងការប្រើប្រាស់គ្រូឧទេសមុខរបរ
**២.៤ ការត្រៀមជាបឋមមុនពេលអនុវត្ត** ១៧
២.៤.១ ការពិនិត្យលក្ខណនានាឡើងវិញនៅសាលារៀនដើម្បីកំណត់សមិទ្ធិលទ្ធភាព
២.៤.២ វិធានការដើម្បីធានាការអនុវត្តដែលមានសមិទ្ធិលទ្ធភាព
២.៤.៣ ការស្ទង់មតិព័ត៌មានដំបូង
២.៥ ការអភិវឌ្ឍឯកសារ ១៩

**៣. បទបញ្ញត្តិនៃការត្រួតពិនិត្យ** ២២
**៣.១ បទបញ្ញត្តិការត្រួតពិនិត្យនៅថ្នាក់សាលា** ២២
**៣.២ បទបញ្ញត្តិការត្រួតពិនិត្យនៅថ្នាក់ស្រុក** ២២
**៣.៣ បទបញ្ញត្តិការត្រួតពិនិត្យនៅថ្នាក់ខេត្ត** ២៣
**៣.៤ បទបញ្ញត្តិការត្រួតពិនិត្យនៅថ្នាក់ជាតិ** ២៤

**៤. ការវិភាគហានិភ័យ** ២៦

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី១៖ ការងារស្នូលនៃការសម្របសម្រួលថ្នាក់ខេត្ត និង DTMTs
ឧបសម្ព័ន្ធទី២៖ គម្រូលផែនការសម្រាប់ SBEP
ទម្រង់ **ក**៖ ព័ត៌មាន និងភាពអាចទទួលបាន
ទម្រង់ **ខ**៖ ស្ថិតិ និងអាំងឌីកាទ័រ
ទម្រង់ **ខ២**៖ ស្ថិតិ និងអាំងឌីកាទ័ររបស់ EMIS – សំណួរ
ទម្រង់ **គ**៖ ផែនការម៉ាទ្រីសឆ្លើយតបទៅនឹងតម្រូវការ
ទម្រង់ **ឃ**៖ ការប៉ាន់ប្រមាណតម្លៃសម្រាប់ធនធានដែលមានសក្តានុពលឆ្នាំនេះ
ទម្រង់ **ង**៖ តម្លៃសង្ខេបនៃផែនការសកម្មភាពសម្រាប់ឆ្នាំនេះ
ទម្រង់ **ច**៖ ការពណ៌នាពីសកម្មភាពសំខាន់ៗ
ទម្រង់ **ឆ**៖ កាលវិភាគអនុវត្តសកម្មភាព
ទម្រង់ **ជ**៖ ផែនការតាមដានការត្រួតពិនិត្យ និងវាយតម្លៃ (ថ្នាក់សាលា)
ឧបសម្ព័ន្ធ ៣៖ ការណែនាំពីការត្រួតពិនិត្យផែនការកែលម្អសាលារៀន
ឧបសម្ព័ន្ធទី ៤៖ ម៉ឺនុយសកម្មភាព SBEP
ឧបសម្ព័ន្ធទី ៥៖ ម៉ឺនុយកម្មវិធីបំណិនជីវិតរបស់ MoEYS
ឧបសម្ព័ន្ធទី ៦៖ ទម្រង់របាយការណ៍ត្រួតពិនិត្យនិងតាមដាន

# ការប្រកាសបដិសេធ

ទស្សនៈដែលបង្ហាញនៅក្នុងឯកសារនេះ គឺជាទស្សនៈរបស់ទីប្រឹក្សា និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី ឬក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# តារាងអក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CFS | សាលាកុមារមេត្រី |
| CRP | គ្រូឧទ្ទេសមុខរបរ |
| DOE | ការិយាល័យអប់រំស្រុក |
| DOF | នាយកដ្ឋានហិរញ្ញវត្ថុ |
| ECCD | ការអភិវឌ្ឍន៍ និងគាំពារកុមារតូច |
| EEQP | កម្រោងលើកកម្ពស់គុណភាពអប់រំ |
| EFA | អប់រំសម្រាប់ទាំងអស់គ្នា |
| EMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ |
| EQIP | កម្មវិធីលើកកម្ពស់គុណភាពអប់រំ |
| ESDP | កម្មវិធីអភិវឌ្ឍនវិស័យអប់រំ |
| ESSUAP | កម្មវិធីពង្រីកវិស័យអប់រំ |
| EU | សហគមន៍អឺរ៉ុប |
| FGD | ការពិភាក្សាក្រុមគោលដៅ |
| FTI | ការផ្តួចផ្តើមពន្លឿនការបរំសម្រាប់ទាំងអស់គ្នា |
| IBEC | គម្រោងកែលម្អការអប់រំកម្រិតមូលដ្ឋានក្នុងប្រទេសកម្ពុជា |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| KAPE | អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា |
| LLSP | កម្មវិធីបំណិនជីវិតថ្នាក់មូលដ្ឋាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| NEP | អង្គការដៃគូអប់រំមិនមែនរដ្ឋាភិបាល |
| NER | អត្រាចុះឈ្មោះចូលរៀនទូទាំងប្រទេស |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PB | ថវិការតាមកម្មវិធី |
| PAM | ឯកសាររដ្ឋបាលគម្រោង |
| PED | នាយកដ្ឋានបឋមសិក្សា |

| | |
|---|---|
| POE | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត |
| SBEP | កម្មវិធីលើកកម្ពស់ចំណេះដឹងតាមសាលា |
| SCI | អង្គការសង្គ្រោះកុមារអន្តរជាតិ |
| SD | នាយកសាលា |
| SED | នាយកដ្ឋានមធ្យមសិក្សា |
| Sida | ទីភ្នាក់ងារសម្រាប់អភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត |
| SIG | ជំនួយកែលម្អសាលារៀន |
| SIP | ផែនការកែលម្អសាលារៀន |
| SMIL | ការពង្រឹងការគ្រប់គ្រងតាមសាលា និងការដឹកនាំរចនាសម្ព័ន្ធស្ថាប័ន |
| SOB | ថវិការដំណើរការសាលារៀន |
| SSC | គណៈកម្មការទ្រទ្រង់សាលារៀន |
| STEPSAM | កម្មវិធីអប់រំគ្រូវិទ្យាសាស្ត្រ |
| TGL | គ្រូដឹកនាំថ្នាក់បច្ចេកទេស |
| TTD | នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ |
| UNICEF | មូលនិធិសហប្រជាជាតិសម្រាប់កុមារ (យូនីសេហ្វ) |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| VVOB | សមាគមនហ្វ្លេមីសសម្រាប់ការអភិវឌ្ឍន៍ និងជំនួយការបច្ចេកទេស |
| VOD | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| WEI | អង្គការអប់រំពិភពលោក |

# ១. សេចក្ដីផ្ដើម

## ១.១ សាវតារ

ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានចាប់ផ្ដើមអនុវត្តកម្មវិធី អភិវឌ្ឍន៍វិស័យអប់រំដំណាក់កាលទីបី (ESDP III) ដែលនឹងផ្ដោតលើធនធានសំខាន់ៗនៅមធ្យមសិក្សាបឋមភូមិ។ ឯកសារស្ដីពីក្របខ័ណ្ឌគម្រោងត្រូវបានអនុម័តក្នុងឆ្នាំ២០១២ ដោយធ្វើការកំណត់លទ្ធផលសំខាន់ៗ ចំនួនបីរួមមាន (i) ការពង្រីកលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ (ii) ការលើកកម្ពស់គុណភាព ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និង (iii) ការលើកកម្ពស់ការគ្រប់គ្រងអនុវិស័យ។ ESDP III គាំទ្រដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ ដែលបានចែងនូវក្របខ័ណ្ឌដើម្បីសម្រេចបានគោលដៅកំណត់ក្នុងផែនការជាតិសម្រាប់ការអប់រំទាំងអស់គ្នា ២០០៣-២០១៥។ ស្របទៅនឹងកិច្ចអន្តរាគមន៍គម្រោងក្នុងការពង្រឹងមធ្យមសិក្សាបឋមភូមិ កម្មវិធីនេះនឹងគាំទ្រដល់កំណែទម្រង់គោលនយោបាយដើម្បីធានាបាននូវវឌ្ឍនភាពរបស់ សិស្សពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ ការផ្ដល់ធនធានផ្ទាល់ដល់សាលារៀនដើម្បីបំពេញតម្រូវការចាំបាច់តាមមូលដ្ឋាន ការពង្រឹងការគ្រប់គ្រងតាមសាលា និងការចូលរួមរបស់សហគមន៍ ក្នុងការលើកកម្ពស់ការអនុវត្តតាមសាលារៀន និងការត្រួតពិនិត្យស្តង់ដារ និងការរៀបចំកិច្ចការរដ្ឋបាលនៃការអប់រំកម្រិតមូលដ្ឋាន។

សកម្មភាពសំខាន់មួយរបស់ ESDP III គឺពាក់ព័ន្ធនឹងការបង្កើត និងការអនុវត្តកម្មវិធីលើកកម្ពស់ចំណេះដឹងតាមសាលា (SBEP) ដែលនឹងត្រូវផ្ដោតលើអត្រាគង់វង្សរបស់សិស្សក្នុងកម្រិតអតិបរមា។ នៅក្នុងគម្រោងនេះ ជំនួយកែលម្អសាលារៀន (SIP) នឹងត្រូវសាកល្បងនៅក្នុងខេត្តគោលដៅចំនួន១៤ ដើម្បីអនុវត្ត SBEP ក្នុងសាលាមធ្យមសិក្សាបឋមភូមិដែលបានជ្រើសរើស។ ជំនួយថវិកានេះ នឹងត្រូវផ្អែកលើផែនការកែលម្អសាលារៀន សម្រាប់ទប់ស្កាត់ការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សា។ ដោយផ្អែកលើការសាកល្បងនេះ ការអនុវត្ត SBEP នៅទូទាំងប្រទេស នឹងទទួលបានហិរញ្ញវត្ថុពីជំនួយកែលម្អសាលារៀន ដែលសាលាមធ្យមសិក្សាបឋមភូមិ នឹងទទួលបានជាចំណែកនៃថវិកាដំណើរការសាលារៀន (SOB) ក្នុងពេលអនាគត។ វិធីសាស្ត្រអនុវត្ត SBEP គឺ ផ្អែកលើការសន្ទត់សំខាន់ៗ មួយចំនួន ដែលផ្ដោតលើការលើកកម្ពស់បរិស្ថានសិក្សា និងកិច្ចអន្តរាគមន៍តំបន់គោលដៅ ជាមធ្យោ បាយក្នុងការបង្កើនអត្រាចូលរួមរបស់សិស្ស និងធ្វើឱ្យសិស្សបន្តការសិក្សា។ SBEP សំខាន់ជាសកម្មភាពកសាងសម្ថភាព ដែលនឹងអនុវត្តសកម្មភាពដើម្បីពង្រឹងសាលារៀននិងសហគមន៍ ដូចជាការផ្ដល់ឲ្យប្រកបដោយប្រសិទ្ធិភាពនូវសេវាអប់រំ។ សកម្មភាពកសាងសម្ថភាពអប់រំរួមមានការគាំទ្រផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ការបណ្ដុះបណ្ដាលគ្រូបង្រៀន ការគ្រប់គ្រងសាលារៀន និងសេវាកម្មសិស្សដោយផ្ដោតលើភាពមានការងារធ្វើ។

ការបង្កើតកម្មវិធី SBEP នឹងត្រូវជូនដំណឹងមិនត្រឹមតែតាមរយៈការងារសំខាន់ៗ ដែលសម្រេចបានដោយអ្នកពាក់ព័ន្ធដទៃទៀត ដូចជាទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បី អភិវឌ្ឍន៍អន្តរជាតិ (USAID) អង្គការអប់រំពិភពលោក អង្គការសកម្មភាពអប់រំសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) ការផ្តួចផ្តើមពន្លឿនការអប់រំសម្រាប់ទាំងអស់គ្នា (FTI)-ធនាគារពិភពលោក និងស្ថាប័នផ្សេងៗទៀត ព្រមទាំងតាមរយៈការពិភាក្សាក្រុមគោលដៅ ដែលត្រូវបានរៀបចំ ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ក្នុងសាលាដែលបានជ្រើសរើសមួយចំនួន។

តាមលំដាប់លំដោយនៃការពិភាក្សារបស់អ្នកពាក់ព័ន្ធ ត្រូវបានរៀបចំដោយមានអ្នកពាក់ព័ន្ធជាង ៤០០នាក់ នៅក្នុងខែវិច្ឆិការ ឆ្នាំ២០១២។ អ្នកពាក់ព័ន្ធដែលបានពិគ្រោះយោបល់រួមមាន នាយកសាលា គ្រូបង្រៀន សមាជិកសហគមន៍ និងសិស្សានុសិស្ស។ ទស្សនៈដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធគឺស៊ីទៅនឹងការពិភាក្សារៀបចំគម្រោងពិស្ដារ ដែលធ្វើឡើងដោយនាយកដ្ឋានមធ្យមសិក្សា និងនាយកដ្ឋានដទៃទៀតរបស់ក្រសួង។ ទស្សនៈទាំងនេះបានសង្ខេបនៅក្នុងរបាយការណ៍ ដែលបានពិនិត្យមើល និងឯកភាពដោយក្រសួងក្នុងដើមខែតុលា ឆ្នាំ២០១២។ របាយការណ៍បានពិនិត្យមើលទស្សនៈយោបល់របស់អ្នកពាក់ព័ន្ធពីមូលហេតុនៃការបោះបង់ក្នុងសហគមន៍របស់ពួកគេ ធម្មតាទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ (រួមមានសហគមន៍ អ្នកគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស ធនធានដែលត្រូវកែលម្អសាលារៀនរបស់ពួកគេ និងការប្រើប្រាស់ធនធានទាំងនេះឲ្យមានប្រសិទ្ធិភាព។ អ្នកពាក់ព័ន្ធក៏បានផ្ដល់ព័ត៌មានត្រឡប់លើទ្រង់ទ្រាយរៀបចំដែលបានស្នើរនៅក្នុង SBEP ផងដែរ ដូចជាការបង្កើតគ្រូឧទ្ទេសមុខរបរតាមសាលារៀន តួនាទីដែលអាចធ្វើទៅបាននៃអ្នកពាក់ព័ន្ធជួយក្នុងការគ្រប់គ្រងជំនួយ ផ្ដោតលើការបង្កើនភាពពាក់ព័ន្ធខាងអប់រំ ព្រមទាំងការគ្រប់គ្រងជំនួយ។ ទស្សនៈរបស់អ្នកពាក់ព័ន្ធជាទូទៅមិនមានដូចគ្នានិងអ្នកផ្សេងទៀតឡើយ ឬដោយមានគំនិតសាមញ្ញលើហេតុផលដែសាលាមានការប្រសិទ្ធភាពអប់រំទាប ឬដំណោះស្រាយអ្វីដែលល្អប្រសើរក្នុងការបង្កើនប្រសិទ្ធភាពអប់រំ។ ឧទាហរណ៍ នៅថ្នាក់សាលារៀន ជាញឹកញាប់អ្នកពាក់ព័ន្ធបានចង្អុលទៅកត្តាសហគមន៍ ខណៈដែលសហគមន៍ទំនោលចង្អុលទៅលើកត្តាខាងសាលារៀនច្រើនជាងខាងសហគមន៍ចំពោះហេតុដែលបណ្ដាលឲ្យអត្រាចូលរៀនទាបនៅសាលាមូលដ្ឋាន។ របាយការណ៍ថ្មីៗនេះនឹងជួយក្រសួងក្នុងការធ្វើការសម្រេចចិត្តរៀបចំគម្រោងឲ្យមានតុល្យភាពត្រឹមត្រូវ ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

ESDP III មានផែនការអនុវត្ត SBEP នៅក្នុង សាលាចំនួន ១០០ ទូទាំងខេត្តគោលដៅ១៤ ដែលនៅជាប់ ឬនៅជិតបំផុតនឹងបឹងទន្លេសាប។ ខេត្តទាំងនេះមានដូចជា បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ ឧត្តរមានជ័យ ប៉ៃលិន សៀមរាប បន្ទាយមានជ័យ មណ្ឌលគិរី ស្ទឹងត្រែង និងព្រះវិហារ។ ខេត្តទាំងនេះ ត្រូវបានជ្រើសរើសដោយផ្អែកលើការពិនិត្យឡើងវិញនូវអត្រាបោះបង់ការសិក្សា (ខ្ពស់ជាងមធ្យម) និងអត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សា (ទាបជាងមធ្យម)។ ក្របខ័ណ្ឌសម្រាប់រៀបចំកម្មវិធី SBEP ដែលនឹងត្រូវបង្កើតនៅក្នុងដំណាក់កាលរៀបចំផែនការនៃកម្មវិធី នឹង ផ្ដល់គោលការណ៍ណែនាំដល់ក្រសួងអប់រំ យុវជន និង កីឡាលើការងារដូចខាងក្រោម ៖

- កំណត់នូវកត្តាផ្សេងៗដែលរួមចំណែកដល់ការទទួលបានការអប់រំកម្រិតមូលដ្ឋាន។
- ជ្រើសរើសយុទ្ធសាស្ត្រលើកកម្ពស់ឱកាសទទួលបានការអប់រំកម្រិតមូលដ្ឋាន និងអត្រាគង់វង្សដោយសមធម៌។
- កំណត់វិសាលភាពសមស្របសម្រាប់កម្មវិធី ជាពិសេសផ្ដោតការយកចិត្តទុកដាក់លើការងារតាម សាលារៀន (ដូចជា សកម្មភាពផ្ដោតលើលទ្ធភាពទទួលបានការអប់រំ សកម្មភាពផ្ដោតលើគុណភាព សកម្មភាព ផ្ដោតលើការគ្រប់គ្រងសាលារៀនជាដើម)។
- កំណត់កត្តាលើកទឹកចិត្តសំខាន់ៗ ដែលសមស្របសម្រាប់ក្រុមគោលដៅ និងទីតាំងគោលដៅ។
- បង្កើតរចនាសម្ព័ន្ធស្ថាប័ន និងដឹកនាំសម្រាប់គ្រប់គ្រងជំនួយដែលបានស្នើឡើង។

- បន្សុីកម្មវិធីជំនួយជាមួយនឹងរចនាសម្ព័ន្ធពាក់ព័ន្ធ ដែលបានគូសបញ្ជាក់នៅក្នុង ESDP III រួមទាំង វគ្គបណ្ដុះបណ្ដាលស្ដីពីការគ្រប់គ្រងសាលារៀន វគ្គបណ្ដុះបណ្ដាលគ្រូបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រជាដើម។
- បង្កើតប្រព័ន្ធពិនិត្យតាមដានដើម្បីធានាបានការគ្រប់គ្រងកម្មវិធីប្រកបដោយប្រសិទ្ធភាព។

ដំណើរការអភិវឌ្ឍន៍ការរៀបចំកម្មវិធី SBEP កំពុងទទួលបានការគាំទ្រតាមរយៈការផ្ដល់ការពិគ្រោះយោបល់បច្ចេកទេស ដែលរៀបចំឡើងដោយ ADB និងអនុម័តដោយ MoEYS កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងដៃគូនៅថ្នាក់ជាតិ ខេត្ត និងស្រុក។ ការពិគ្រោះយោបល់បច្ចេកទេសបានចាប់ផ្ដើមនៅចុងខែកក្កដា ឆ្នាំ២០១២ និងគ្រោងនឹងបញ្ចប់សកម្មភាពអភិវឌ្ឍន៍ការរៀបចំកម្មវិធីនៅចុងខែតុលា ឆ្នាំ២០១២។ ការផ្ដល់ការគាំទ្រនេះផ្ដោតជាសំខាន់ទៅលើការជួយដល់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការពិនិត្យឡើងវិញនូវព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធសំខាន់ៗនៅកម្រិតសាលារៀន ដែលនាំឆ្ពោះទៅទទួលបានសេចក្ដីព្រាងសកម្មភាព ដែលអ្នកពាក់ព័ន្ធយល់ឃើញថា អាចនឹងមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហានៅតាមសាលាប្រកបដោយប្រសិទ្ធភាពខ្ពស់ ជាពិសេសការបោះបង់ការសិក្សា។ ផ្អែកលើមូលដ្ឋាននៃបទពិសោធន៍ពីគម្រោងសាកល្បងមួយចំនួន ដែលគេដឹងជាទូទៅថា ត្រូវបានអនុវត្តក្រោមកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានមធ្យមសិក្សា (SED) និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ក្រសួងបានស្នើឡើងថា ព័ត៌មានត្រឡប់នេះគប្បីសង្ខេបជាទម្រង់មួយនៃ"ម៉ឺនុយ"សកម្មភាព ដែលនឹងផ្ដល់ជម្រើសដល់អ្នកពាក់ព័ន្ធ ក្នុងការជ្រើសរើស និងខ្លឹមសារនៃសកម្មភាពជំនួយ ដែលនឹងត្រូវគាំទ្រតាមរយៈ SBEP។ ការពិភាក្សារបស់អ្នកពាក់ព័ន្ធ ក៏បានផ្ដោតជាចម្បងលើជំនាញបំពេញការងារ ដែលនឹងធ្វើឲ្យការសិក្សានៅសាលា មានការពាក់ព័ន្ធច្រើនជាងមុនទៅនឹងការរស់នៅក្នុងសង្គមដែលជាកត្តាដ៏ចម្បងក្នុងការទាក់ទាញសិស្សឲ្យបន្តការសិក្សា។

## ១.២ គោលបំណង និងទិសដៅ

របាយការណ៍នេះពង្រីកលើការពិពណ៌នាគម្រោងដាក់នៅទីបួនក្នុងសេចក្ដីព្រាង ការគ្រប់គ្រងគម្រោង ESDP III ដោយផ្ដល់អនុសាសន៍ជាក់លាក់បន្ថែមទៀត និងដោយផ្អែកលើរចនាសម្ព័ន្ធប្រតិបត្តិការនៃ SBEP មាតិការសកម្មភាព និងពិធីការត្រួតពិនិត្យ។ ផ្អែកលើព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធ ឯកសារនេះបានបង្ហាញពីការម៉ូឌែល "ទ្រឹស្ដីនៃការផ្លាស់ប្ដូរ" ដែលផ្ដល់ភាពសមស្របសម្រាប់ការជ្រើសរើសការអន្តរាគមន៍ និងសកម្មភាពជាក់លាក់ ជាពិសេសវាទាក់ទងនៅនឹងការទប់ស្កាត់ការបោះបង់របស់សិស្ស។ ម៉ូឌែលទ្រឹស្ដីនៃការផ្លាស់ប្ដូរនេះធ្វើលើព័ត៌មានត្រឡប់ដ៏មានប្រសិទ្ធភាពពីអ្នកពាក់ព័ន្ធកំឡុងពេលពិភាក្សាក្រុម ដូចទៅនឹងហេតុដែលនាំសិស្សបោះបង់ រួមមានកត្តាជាច្រើនដែលពាក់ព័ន្ធទៅនឹងការផ្លាស់ប្ដូរបរិបទសេដ្ឋកិច្ច កំណើនចំណាកស្រុក បញ្ហារចនាសម្ព័ន្ធក្នុងវិស័យអប់រំ (ឧទាហរណ៍ ការខ្វះគ្រូបង្រៀន) និងការចំណាយផ្ទាល់លើការសិក្សា។

ដោយផ្អែកលើម៉ូឌែលទ្រឹស្ដីនៃការផ្លាស់ប្ដូរដែលបានរៀបរាប់ខាងលើ របាយការណ៍នេះនឹងបញ្ជាក់ពីផ្នែកសំខាន់ៗរបស់កម្មវិធីលើកកម្ពស់ចំណេះដឹងតាមសាលាក្នុងសាលាដែលបានជ្រើសរើសរួមមានគោលដៅអន្តរាគមន៍ក្នុងមេរៀនសំខាន់ៗនៅក្នុងមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ ការបង្កើនភាពពាក់ព័ន្ធផ្នែកអប់រំ និងការចូលរួមរបស់សិស្ស និងយុទ្ធសាស្ត្រដើម្បីបង្កើនការទប់ស្កាត់ការបោះបង់។ ការរៀបរាប់ពីតម្រូវការការក

សាងសមត្ថភាពចំពោះអ្នកគ្រប់សាលា និងសហគមន៍ ក៏ត្រូវបានរួមបញ្ចូលដើម្បីធានាថារចនាសម្ព័ន្ធប្រតិបត្តិបានអនុវត្តដើម្បីគ្រប់គ្រងធាតុចូលរបស់គម្រោងអាចដំណើរការទៀងទាត់។

របាយការណ៍នេះពិនិត្យមើលឡើញវិញនូវអ្វីដែលបានអនុវត្តកន្លងមក ដោយដៃគូអភិវឌ្ឍន៍ដទៃទៀតដែលធ្វើការជាមួយ MoEYS ដើម្បីកសាងសមត្ថភាព និងមេរៀនសិក្សាដោយគម្រោងផ្សេងទៀត។ សេចក្តីសង្ខេបដែលពាក់ព័ន្ធរបស់ដៃគូអភិឌ្ឍន៍ចំពោះសកម្មភាពនីមួយៗដែលស្ថិតនៅក្រោម ESDP III ត្រូវបានផ្តល់ក្នុងតារាង ១.១ ខាងក្រោម។ ដៃគូទាំងនេះបានអភិវឌ្ឍវិធីសាស្ត្រ និងអន្តរាគមន៍ជាច្រើនដែលនឹងមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តន៍ SBEP។ គម្រោងដែលបានស្នើនេះនឹងបញ្ជាក់ពីទីតាំងអភិវឌ្ឍន៍គម្រោងនាលពេលអនាគត ដែលត្រូវតែសម្រេចបានដើម្បីដាក់បញ្ចូលគម្រោងដូចបានរៀបរាប់។ ដើម្បីពង្រីកឲ្យធំទូលាយ ឯកសារជាច្រើនត្រូវការកែតម្រូវឲ្យរួចរាល់ទាន់ពេលវេលា ប៉ុន្តែនឹងទាមទាឲ្យមានការផ្លាស់ប្តូរខ្លះៗផងដែរ ដើម្បីឲ្យស្របជាមួយបរិបទឯកទេសដែលរកឃើញក្នុងសាលាគោលដៅ SBEP។

**តារាង ១.១ ដៃគូអភិវឌ្ឍន៍ដែលពាក់ព័ន្ធសម្រាប់ធាតុចេញ និងសកម្មភាពជាក់លាក់ក្នុង ESDP I I I ។**

| ធាតុចេញ | សកម្មភាពពាក់ព័ន្ធ | ដៃគូអភិវឌ្ឍន៍សំខាន់ៗ |
|---|---|---|
| *ធាតុចេញទី១៖* កែលម្អភាពងាយចូលរៀននៅមធ្យមសិក្សាបឋមភូមិ | ហេដ្ឋារចនាសម្ព័ន្ធថ្មី និងការកែលម្អ | -- |
| *ធាតុចេញទី២៖* កែលម្អគុណភាពនៅមធ្យមសិក្សាបឋមភូមិ *(កម្មវិធីលើកម្ពស់ចំណេះដឹងតាមសាលា)* | ជំនួយកែលម្អសាលារៀនសាកល្បង | ធនាគារពិភពលោក-ESSUAP<br>USAID-IBEC (World Ed & KAPE) |
| | ការពង្រឹងការសិក្សាគណិតវិទ្យា | BETT-JICA |
| | ការពង្រឹងការសិក្សាវិទ្យាសាស្ត្រ | VVOB |
| | ការណែនាំពីបំណិនលទ្ធភាពរកការងារ | USAID-IBEC (World Ed & KAPE) |
| ធាតុចេញទី៣៖ ការកែអម្អការគ្រប់គ្រងថ្នាក់ក្រោម | ការពង្រឹងការគ្រប់គ្រងតាមសាលា | USAID-IBEC (World Ed & KAPE) |
| | ការពង្រឹងគណៈកម្មការទ្រទ្រង់សាលា | -- |
| | កម្រងអប់រំមូលដ្ឋានសាកល្បង | -- |
| | ការណែនាំពីការស្រាវជ្រាវសម្រាប់ការបង្កើតគោលនយោបាយ | EEQP |

# ២. ការពិចារណាការរៀបចំគម្រោងទូទៅ

## ២.១ ម៉ូឌែលទ្រឹស្តីនៃការផ្លាស់ប្តូរដើម្បីបង្កើនអត្រាចូលរៀន




**រូបភាព ២.១៖ គម្រូកត្តាបណ្តាលឲ្យបោះបង់ ESDP III**

*មូលហេតុបោះបង់៖* មានការសិក្សាជាច្រើនដែលសរសេរអំពីការបោះបង់របស់សិស្សនៅកម្រិតមធ្យមសិក្សាក្នុងប្រទេសកម្ពុជា។ ការស្រាវជ្រាវថ្មីៗដោយ ESDP III បានបង្ហាញថា មានកត្តាជាច្រើនទៀតដែលជាហេតុនាំឲ្យមានការបោះបង់ ជាពិសេស បញ្ហាទាំងនេះវាទាក់ទងទៅនឹងការប្រែប្រួលផ្នែកសេដ្ឋកិច្ចបច្ចុប្បន្នដែលកំពុងកើតឡើងនៅជនបទ។ ការវិភាគពីទំនាក់ទំនងបែបតកម្មយបង្ហាញពីកត្តាដែលបណ្តាលឲ្យមានការបោះបង់ត្រូវបានផ្តល់ក្នុងរូបភាព ២.១។ កត្តាទាំងនេះអាចត្រូវបានគេយល់យ៉ាងច្បាស់ថាជាអន្តរកម្មរវាងកត្តា *តម្រូវការ* និង *ផ្នែកផ្គត់ផ្គង់*ទាំងពីរដែលនាំឲ្យអត្រាចុះឈ្មោះប្រចាំឆ្នាំធ្លាក់ចុះ និងមានអត្រាបោះបង់របស់សិស្ស។ កត្តាផ្គត់ផ្គង់ត្រូវបានភ្ជាប់ក្នុងបរិបទសាលារៀន និងទាក់ទងទៅនឹងបញ្ហារចនាសម្ព័ន្ធ ដូចជាកង្វះគ្រូបង្រៀន ភាពពាក់ព័ន្ធផ្នែកអប់រំ និងគុណភាពអប់រំខ្សោយ និងកត្តាផ្សេងទៀត។ កត្តាទាំងនេះអាចសាកល្បងការអន្តរាគមន៍ដែលផ្តោតលើសាលារៀនបាន។ កត្តាផ្នែកតម្រូវការគឺត្រូវបានបង្កប់នៅតាមផ្ទះ និងសហគមន៍និងពាក់ព័ន្ធទៅនឹងកត្តាដែលធ្វើឲ្យចុះខ្សោយតម្រូវការការអប់រំ ដូចដែលបានពិគ្រោះស្រាប់។ ដោយរួមបញ្ចូលទាំងកត្តាតវិយាបទ សាលានៅឆ្ងាយ និងបញ្ហាសេដ្ឋកិច្ច។ កត្តាទាំងនេះមានទំនាក់ទំនងគ្នាយ៉ាងស្មុកស្មាញ ដូច្នេះហើយផលប៉ះពាល់មួយអាចជះឥទ្ធិពលលើផ្នែកផ្សេងៗទៀត។ ដោយផ្អែកលើអ្វីដែលបានសិក្សាពីការពិភាក្សាជាក្រុមរៀបចំដោយ ESDP III ការយល់ដឹងពីតម្លៃនៃការអប់រំរបស់សិស្ស និងមាតាបិតាមានកម្រិតទាប ជាធម្មតាកើតមកពីបញ្ហារចនាសម្ព័ន្ធក្នុងប្រព័ន្ធអប់រំ និងអារម្មណ៍ដែលគិតថាការអប់រំមិនសូវមានភាពពាក់ព័ន្ធទៅនឹងតម្រូវការប្រចាំថ្ងៃ។ លើសពីនេះទៅទៀត ដោយទទួលបានប្រាក់កម្រៃពលកម្មខ្ពស់ ផ្នែកសេដ្ឋកិច្ចដាំដុះមានរយៈពេលយូរ ព្រមទាំងទទួលបានការងារនៅរោងចក្រ និងឱកាសទៅធ្វើការនៅប្រទេសថៃផងនោះ បានជម្រុញឲ្យមានការបោះបង់ការសិក្សា ជាពិសេសនៅពេលដែលពួកគេឲ្យតម្លៃលើការសិក្សាទំនងជាមិនមានទម្ងន់ស្មើនឹងតម្លៃទាំងអស់នោះ។

*ការបញ្ជាក់ពីកម្រងសកម្មភាពដើម្បីឆ្លើយតបនឹងបញ្ហាបោះបង់៖* កម្រង់សកម្មភាពស្ថិតនៅក្រោមធាតុចេញ

សំខាន់នីមួយៗបញ្ជាញក្នុង ESDP III នឹងឆ្លើយតបទៅនឹងខ្សែរយៈទំនាក់ទំនងបញ្ហាដែលបញ្ហាញយ៉ាងត្រឹមត្រូវនៅក្នុងរូបភាព ២.១ ខាងលើ។ ឧទាហរណ៍ អន្តរាគមន៍ដែលផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ (ធាតុចេញទី១) នឹងជួយដោះស្រាយបញ្ហាសាលានៅឆ្ងាយ ដែលបណ្តាលឲ្យតម្រូវការអប់រំខ្សោយ ខណៈដែលគម្រោងកែលម្អការគ្រប់គ្រងថ្នាក់ក្រោម (ធាតុចេញទី៣) នឹងធានាថាជំនួយសាលារៀនត្រូវបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពដូច្នេះហើយឆ្លើយតបទាំងកត្តាផ្គត់ផ្គង់ និងតម្រូវការ។ ភាពបត់បែនរបស់ជំនួយសាលារៀននឹងជាលក្ខណៈពិសេសនៃការអនុវត្ត SBEP (ធាតុចេញទី២) ដូច្នេះវាអាចឆ្លើយតបទៅនឹងកត្តាធំៗទាំងនេះបាន។ ជាការពិតណាស់ ជំនួយសាលារៀនត្រូវបានរួមបញ្ចូលគ្នាក្នុងការរៀបចំ SBEP ដោយសារតែភាពស្ទាត់ជំនាញរបស់ពួកគេក្នុងការដោះស្រាយបញ្ហាដែលបានចង្អុលបង្ហាញដោយអ្នកពាក់ព័ន្ធ។ ស្របគ្នានេះដែរ ជំនួយកែលម្អសាលារៀននឹងរៀបចំក្នុងម៉ឺនុយសកម្មភាពដែលសម្រេចចិត្តដោយអ្នកពាក់ព័ន្ធតាមរយៈការពិភាក្សាក្រុមខាងដើមរួចមកហើយ ដើម្បីដោះស្រាយបញ្ហាសំខាន់ៗដែលបានបញ្ជាក់ដោយអ្នកពាក់ព័ន្ធខ្លួនឯងផ្ទាល់កំឡុងពេលធ្វើផែនការសាលារៀន។ ជម្រើសនៅក្នុងសកម្មភាពដែលបានជ្រើសរើសនឹងធានាថាអន្តរាគមន៍ទាំងអស់ទាក់ទងទៅនឹងបរិបទ និងមានភាព "ម្ចាស់ការ" ដោយអ្នកពាក់ព័ន្ធ។ ភាពជាម្ចាស់ការនឹងជម្រុញឲ្យមាននិរន្តរភាព។

ទោះបីជាជំនួយសាលារៀនបានស្នើឲ្យស្ថិតនៅក្រោម SBEP ក៏ដោយ វានឹងត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយទាំងកត្តាផ្គត់ផ្គង់ និងតម្រូវការ អន្តរាគមន៍សំខាន់ៗដទៃទៀតដែលទាក់ទងការពង្រឹងមុខវិជ្ជាបង្រៀនវិទ្យាសាស្ត្រ គណិតវិទ្យា និងបំណិនលទ្ធភាពរកការងារនឹងផ្តោតសំខាន់លើកត្តាខាងសាលារៀនដើម្បីបង្កើនការសិក្សាដែលពាក់ព័ន្ធ និងបង្កើនការយល់ដឹងពីតម្លៃអប់រំដោយអ្នកពាក់ព័ន្ធ។ វាសង្ឃឹមថានៅពេលដែលអ្នកពាក់ព័ន្ធមានការយល់ដឹងពីតម្លៃអប់រំខ្ពស់ គេនឹងធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព នឹងឲ្យតម្លៃលើការសិក្សា ដោយទទួលបានបរិយាកាសល្អ និងតម្រូវការប្រាក់កម្រៃប្រចាំថ្ងៃខ្ពស់របស់អ្នកធ្វើការនាលពេលបច្ចុប្បន្ន ពួកគេត្រូវបានបង្កើនការដាំដុះ និងទៅធ្វើការនៅរោងចក្រនៅជនបទ។
សេចក្តីសង្ខេប "ទ្រឹស្តីនៃការផ្លាស់ប្តូរ" ប្រើនៅក្នុង ESDP III នឹងផ្តល់សទិទានភាពលើរចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃអន្តរាគមន៍ស្ថិតនៅក្រោមគម្រោងត្រូវបានផ្តល់ក្នុងតារាង ២.១ ខាងក្រោម៖

**តារាង ២.១៖ ម៉ូឌែលទ្រឹស្តីនៃពីផ្លាស់ប្តូរដែលពន្យល់ពីសទិទានភាពចំពោះអន្តរាគមន៍គាំទ្រដោយ ESDP III**

| | | | |
|---|---|---|---|
| ***អន្តរាគមន៍*** | ○ ពង្រឹងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា<br>○ បំណិនលទ្ធភាពរកការងារ/បំណិនជីវិត<br>○ ការសាកល្បងកម្រងអប់រំមូលដ្ឋាន<br>○ កន្លែងស្នាក់នៅគ្រូ<br>○ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ | ○ អគារសិក្សាថ្មី<br>○ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ<br>○ ជំនួយសាលារៀនដែលបទបែនបាន (ឧ.កង់ ។ល។) | ○ ពង្រឹងការគ្រប់គ្រងតាមសាលា<br>○ ការពង្រឹងគណៈកម្មការទ្រទ្រង់សាលា<br>○ ជំនួយសាលារៀនដែលបទបែនបាន (ឧ.ឯកសណ្ឋានសម្ភារសិក្សា ។ល។) |
| | ⇩ | ⇩ | ⇩ |

| | | | |
|---|---|---|---|
| **កត្តាត្រូវដោះស្រាយ** | ○ ការកែលម្អវត្តមានគ្រូ<br>○ ការយល់ពីតម្លៃអប់រំតិចតួច | ○ សាលានៅឆ្ងាយ | ○ ចំណាយផ្ទាល់លើការអប់រំខ្ពស់<br>○ សិស្សចុះឈ្មោះចូលរៀនយឺត |
| **ផលប៉ះពាល់ចម្បង** | ○ សិស្ស & មាតាបិតាឲ្យតម្លៃខ្ពស់លើការអប់រំ | ○ កែលម្អភាពងាយចូលរៀន | ○ សាលាត្រូវបានគ្រប់គ្រងបានប្រសើរឡើង<br>○ អវត្តមានគ្រូតិច<br>○ សិស្សចុះឈ្មោះនៅអាយុត្រឹមត្រូវ |
| **ផលប៉ះពាល់ដែលពាក់ព័ន្ធ** | ○ ការថ្លឹងថ្លែងលើតម្លៃការងារ | ○ បង្កើនអត្រាចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ | ○ អ្នកគ្រប់គ្រងសាលាប្រើប្រាស់ជំនួយសាលារៀនឲ្យមានប្រសិទ្ធភាពដើម្បីលើកកម្ពស់ការចូលរៀន<br>○ ការតស៊ូមតិរបស់សហគមន៍សម្រាប់ការអប់រំឥតបង់ថ្លៃ |

## ២.២ រចនាសម្ព័ន្ធប្រតិបត្តិ

*ការគ្រប់គ្រងថ្នាក់សាលា៖* កម្មវិធីកសាងសមត្ថភាពរបស់ SBEP នឹងត្រូវបានត្រួតពិនិត្យនៅថ្នាក់សាលាដោយគណៈកម្មការទ្រទ្រង់សាលា ដែលបានដាក់បញ្ចូលតំណាងសហគមន៍ និងគ្រូបង្រៀនព្រមទាំងនាយកសាលា។ ការសម្រេចចិត្តប្រើអង្គការចាត់តាំងនេះត្រូវបានយល់ព្រមដោយ MoEYS ហើយនឹងធ្វើឲ្យមានរូបរាងឡើងយ៉ាងត្រឹមត្រូវ ដូច្នេះនាយកសាលាមិនត្រូវជ្រាតជ្រែកដំណើរការរបស់គណៈគម្មការនេះទេ ទោះបីជាគាត់នឹងបន្តជាអ្នកដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍន៍សាលារៀន និងអនុវត្តផែនការកែលម្អសាលារៀនក៏ដោយ។ វាជាការសំខាន់ដើម្បីកត់សម្គាល់ថា MoEYS មិនចង់បង្កើតគណៈកម្មការគម្រោងដែលនឹងមកប្រកួតប្រជែងជាមួយគណៈកម្មការដែលមានស្រាប់រួចមកហើយនោះទេ ដូចជាគណៈកម្មការទ្រទ្រង់សាលាជាដើម។ ដោយមូលហេតុនេះហើយបានជាក្រសួងយល់ព្រមនឹងសំណើរដើម្បីអនុវត្តជំនួយសាលារៀន SBEP ដោយប្រើប្រាស់ SSC ដែលមានស្រាប់ ទោះបីជាមានការកែប្រែខ្លះនៅក្នុងកិច្ចការដែលបានចាត់តាំងក៏ដោយ វានឹងឆ្លើយតបទៅនឹងតម្រូវការនៃការអនុវត្តន៍ SBEP។ SSC នឹងដឹកនាំដោយប្រធានមួយរូបដែលត្រូវបានបោះឆ្នោតដោយតំណាងសហគមន៍ដើម្បីឆ្លើយតបនឹងតម្រូវការបច្ចុប្បន្នដែលផ្សព្វផ្សាយដោយក្រសួង (cf. លេខ. ២១ MoEYS/SNN ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១២)។

SSC នឹងធ្វើការប្រជុំយ៉ាងហោចណាស់បីដងក្នុងមួយឆ្នាំ និងត្រូវរួមបញ្ចូលទាំងសហគមន៍ និងតំណាងសិស្សផងដែរ។ បន្ទាប់មកត្រូវជ្រើសរើសពីក្រុមប្រឹក្សាយុវជន (សិស្ស) ដែល MoEYS ប្រគល់

**<u>ប្រអប់១៖</u> ភាគីចូលរួមដែលបានផ្ដល់អនុសាសន៍នៅក្នុងការប្រជុំ SSC និងតួនាទីរបស់ពួកគេក្នុងការអនុវត្តន៍ SBEP**

**សមាជិកគណៈកម្មការដែលបានផ្ដល់យោបល់**

- នាយកសាលា
- គ្រូ ជាពិសេសអ្នកដឹកនាំថ្នាក់បច្ចេកទេស (TGLs)
- សមាជិក SSC (ប្រធាន)
- តំណាងឃុំ/ប្រធានភូមិ/តំណាងវិហារសាសនា
- តំណាងក្រុមប្រឹក្សាកុមារ

**តួនាទីរបស់គណៈកម្មការដែលបានផ្ដល់យោបល់**

<u>ការធ្វើផែនការ</u>

- ណែនាំផ្ដល់ដោយ PoEYS/DoEYS ស្ដីពីការអនុវត្តគម្រោង SBEP។
- រៀបចំកាលវិភាគចាំបាច់នៅពេលចាប់ផ្ដើមក្នុងឆ្នាំនីមួយៗជាផ្នែកនៃផែនការកែលម្អសាលារៀន។
- អភិវឌ្ឍន៍ផែនការកែលម្អសាលារៀន (SIP) នៅពេលចាប់ផ្ដើមក្នុងឆ្នាំនីមួយៗដោយប្រើប្រាស់ម៉ឺនុយសកម្មភាពស្ដង់ដារ និងគម្រូផែនការបង្កើតឡើងដោយគម្រោង។
- អភិវឌ្ឍន៍កញ្ចប់ថវិកាផ្អែកលើ SIP។
- អភិវឌ្ឍន៍កាលវិភាគអនុវត្តន៍សកម្មភាពផ្អែកលើ SIP។

<u>ការគ្រប់គ្រងជំនួយ</u>

- ស្នើសុំការចំណាយជំនួយដោយប្រើប្រាស់ទម្រង់ស្ដង់ដារ។
- ប្រជុំទៀងទាត់ (យ៉ាងហោចណាស់រាល់ពីរខែម្ដង) ដើម្បីពិនិត្យមើលកាលវិភាគការអនុវត្តសកម្មភាព និងការសម្របសម្រួលថវិការជំនួយសម្រាប់សកម្មភាពជាក់លាក់។
- ចាត់តាំងអ្នកណាម្នាក់ (គ្រូ សិស្ស និងតំណាងសហគមន៍) ឲ្យបំពេញការងារឲ្យបានត្រឹមត្រូវ។
- អនុវត្តសកម្មភាពក្នុងផែនការដោយមិនប្រកាន់តួនាទីក្នុងចំណោមសមាជិកគណៈកម្មការទាំងអស់ រួមទាំងសមាជិកសហគមន៍។
- ត្រួតពិនិត្យដំណើរការនៃការអនុវត្តសកម្មភាព។
- ទូទាត់ថវិការជំនួយដោយប្រើប្រាស់ទម្រង់ស្ដង់ដារ។
- សហការជាមួយអ្នកសម្របសម្រួលថ្នាក់ប្រចាំខេត្តក្នុងការអនុវត្តសកម្មភាពSIP។
- រៀបចំរបាយការណ៍ស្ដីពីដំណើរការអនុវត្ត។

<u>ការឈានដល់របស់សហគមន៍</u>

- ពិនិត្យ និងតាមដានសិស្សដែលបោះបង់។
- ផ្ដល់ការចំណាយលើតម្លៃធ្វើដំណើរដល់អ្នកដែលតាមដានសិស្សក្នុងសហគមន៍។
- បង្កើនការយល់ដឹងចំពោះឪពុកម្ដាយ/បណ្ដុះបណ្ដាល។
- ផ្សព្វផ្សាយព័ត៌មានដល់សហគមន៍តាមរយៈបណ្ដាញដែលភ្ជាប់ជាមួយប្រធានភូមិ។
- សមាជិកសហគមន៍ត្រូវផ្ដល់ព័ត៌មានដល់គ្រូស្ដីពីតម្រូវការជាក់ស្ដែងរបស់សិស្ស។

សិទ្ធិក្នុងសាលាមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិទាំងអស់។ SSC ត្រូវតែចូលរួមក្នុងការតម្រង់ទិសដល់ SBEP ព្រមទាំងការធ្វើសិក្ខាសាលាណែនាំដែលផ្តល់ដោយការិយាល័យ និងមន្ទីរអប់រំ យុវជន និងកីឡាស្រុក និងខេត្ត (POEYS/DOEYSs) សម្រាប់សាលារៀនទាំងអស់។ ជារៀងរាល់ឆ្នាំ SSC នឹងបង្កើតផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ដែលរួមបញ្ចូលទាំងផែនការពីធនធានសមស្រប។ SSC ត្រូវតែមាននៅកន្លែង ឬមានឆន្ទៈយល់ព្រមជាអទិភាពដល់ជំនួយដែលបានផ្តល់ឲ្យ នីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានតម្លាភាព និងទូលំទូលាយដើម្បីធានាដល់ការប្រើប្រាស់ប្រភពជំនួយឲ្យបានត្រឹមត្រូវ។ មុនពេលថវិការជំនួយប្រគល់ឲ្យ SSC នីមួយៗនឹងតម្រូវឲ្យចុះហត្ថលេខាលើកិច្ចសន្យាដែលផ្តល់ចំណុចសំខាន់ៗ និងការរំពឹងទុកសម្រាប់ផលសម្រេចបាន។ បញ្ជីអនុសាសន៍ស្តីពីតួនាទី និងកតព្វកិច្ចផ្លូវការរបស់ SSC សម្រាប់ការអនុវត្ត SBEP ត្រូវបានផ្តល់នៅក្នុងប្រអប់ទី១។

*ការគ្រប់គ្រងថ្នាក់ស្រុក និងខេត្ត ៖* ការទទួលខុសត្រូវរបស់ SBEP នឹងអនុវត្តដោយអ្នកសម្របសម្រួលប្រចាំខេត្ត (PF) ដែលមានមូលដ្ឋាននៅទាំង PoEYS និង DoEYS (មើលរូបភាព ២.២)។ អ្នកសម្របសម្រួលប្រចាំខេត្តនឹងមានការគ្រប់គ្រងលើសាលារៀនរួមបញ្ចូលទាំងដាក់សំណើរផែនការកែលម្អសាលារៀន និងសំណើរជំនួយ។ ពួកគេក៏នឹងមានតួនាទីសម្របសម្រួលទូទៅក្នុងការអនុវត្តសកម្មភាពបច្ចេកទេសទាំងអស់ និងដឹកនាំសិក្ខាសាលាខាងដើមដែលទាក់ទងទៅនឹងការទម្រង់ទិសទូទៅដល់ ESDP III ព្រមទាំងផែនការជំនួយ និងធាតុចូលបច្ចេកទេសដែលផ្តល់ចំណុចសំខាន់ៗខាងក្រោម។ សេចក្តីពិស្តារពីតួនាទី និងកតព្វកិច្ចរបស់អ្នកសម្របសម្រួលប្រចាំខេត្តត្រូវបានផ្តល់ក្នុងឧបសម្ព័ន្ធទី១។

**រូបភាពទី២.២៖ រចនាសម្ព័ន្ធប្រតិបត្តិការសម្រាប់ SBEP**




អ្នកសម្របសម្រួលប្រចាំខេត្តនឹងធ្វើការយ៉ាងជិតស្និតជាមួយក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យប្រចាំស្រុក (DTMTs) ដែលមាននាលពេលបច្ចុប្បន្នក្នុងស្រុកជាច្រើនដើម្បីអនុវត្តគោលនយោបាយសាលាកុមារមេត្រីជាតិនៅកម្រិត

**<u>ប្រអប់ទី២</u>៖ កតព្វកិច្ចដែលស្នើដោយ DTMTs/jPFs នៅកម្រិតមធ្យមសិក្សា**

- ចូលរួមវគ្គបណ្តុះបណ្តាលផ្តល់ដោយ MoEYS និង PoEYS ស្តីពីដាក់ឲ្យដឹងកម្មវិធីលើកម្ពស់គុណភាពអប់រំតាមសាលារៀនរួមមាន៖
  - ⇒ វិធីការគ្រប់គ្រង និងត្រួតពិនិត្យជំនួយ
  - ⇒ គណិតវិទ្យា-INSET
  - ⇒ វិទ្យាសាស្ត្រ-INSET
  - ⇒ កម្មវិធីបំណិនការងារ
- ចូលរួមការប្រជុំធ្វើផែនការជាទៀងទាត់ស្តីពីការដាក់ឲ្យប្រើកម្មវិធី SBEP ។
- បង្កើតផែនការងារប្រចាំខែដើម្បីគាំទ្រការអនុវត្ត SBEP។
- ផ្តល់វគ្គបណ្តុះបណ្តាលដល់សាលារៀនតាមការធ្វើផែនការ ការធ្វើកញ្ចប់ថវិការ និងដំណើរឯកភាពជំនួយ។
- ជួយសាលារៀនក្នុងការអភិវឌ្ឍន៍ផែនការកែអម្ពសាលារៀនរបស់ពួកគេ។
- យល់ព្រមលើផែនការមុនពេលពួកគេជូនដំណឹងដល់ PoEYS សម្រាប់ការត្រួតពិនិត្យអាស្រ័យលើវិធីការដែលបានយល់ស្រប។
- យល់ព្រមលើការទូទាត់បញ្ជីធ្វើឡើងដោយសាលារៀននៅពេលពួកគេបានចំណាយថវិការជំនួយ។
- ជួយសាលារៀនក្នុងការចាត់ចែងផែនការ និងការផ្តល់វគ្គបណ្តុះបណ្តាលពិសេសណាមួយរបស់ពួកគេតម្រូវតាមការអនុវត្តសកម្មភាពពិសេសដែលជ្រើសរើសពីម៉ឺនុយសកម្មភាព SBEP។
- អនុវត្តការត្រួតពិនិត្យជាទៀងទាត់ដោយប្រើប្រាស់តារាងស្តង់ដារ។
- បំពេញរបាយការណ៍ទៅ PoEYSអាស្រ័យលើការទស្សនៈកិច្ចត្រួតពិនិត្យ។
- រាយការណ៍ជាទៀងទាត់ក្នុងការប្រើប្រាស់ថវិការជំនួយទៅ PoEYS នៅពេលពួកវាកើតឡើង។

សាលាបឋមសិក្សា ប៉ុន្តែនឹងត្រូវកាសម្របតាមដើម្បីដោះស្រាយការពង្រីកគោលនយោបាយដែលជិតមក ដល់ ដល់ផ្នែកមធ្យមសិក្សា។ ការសម្របទាំងនេះនឹងរួមបញ្ចូលទាំងការចូលរួមនៃបុគ្គលម្នាក់ៗពីការិយាល័យ មធ្យមសិក្សានៅក្នុង DoEYS ចូលទៅក្នុង DTMT។ SBEP នឹងបង្កើតវគ្គបណ្តុះបណ្តាល និងឯកសារ តម្រង់ទិសសម្រាប់កម្រិតមធ្យមសិក្សា DTMTs និងអ្នកសម្របសម្រួលប្រចាំខេត្តជាមួយអ្នកដែលពួកគេធ្វើ ការជាមួយ។ DTMTs/PFs នឹងត្រូវបានបណ្តុះបណ្តាលដើម្បីផ្តល់ការគាំទ្រ “ផ្នែកប្រឹក្សាយោបល់” ដល់ SSCs ក្នុងការធ្វើផែនការ និងគ្រប់គ្រងជំនួយព្រមទាំងការអនុវត្តសកម្មភាពស្នូលដែលជាប់ពាក់ព័ន្ធនឹងការកែ លម្អក្នុងមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងបំណិនលទ្ធរកការងារ។ សេចក្តីសង្ខេបនៃការងារដែលបានស្នើ ដើម្បីអនុវត្តដោយ DTMTs/PFs នៅកម្រិតមធ្យមសិក្សាត្រូវបានផ្តល់ក្នុងប្រអប់ទី២។

## ២.៣ លក្ខណៈសំខាន់ៗនៃការបង្កើតដែលបានស្នើ និងសនិទានភាពរបស់វា

### ២.៣.១ តួនាទីនៃការធ្វើផែនការកែលម្អសាលារៀននៅក្នុងការបង្កើតកម្មវិធី SBEP

**<u>ប្រអប់ទី ៣ ៖</u> ឯកសារធ្វើផែនការសំខាន់ៗ និងជំហានទាំងឡាយនៅក្នុងផែនការកែលម្អសាលារៀន**

- **<u>ទម្រង់ ក</u> ៖** ព័ត៌មានមូលដ្ឋាន និងសិទ្ធិទទួលបាន
- ***<u>ទម្រង់ ខ ១</u>*** ៖ ស្ថិតិ និងសូចនាករ
- ***<u>ទម្រង់ ខ ២</u>*** ៖ ស្ថិតិ និងសូចនាករ EMIS – សំណួរ
- ***<u>ទម្រង់ គ</u>*** ៖ ការធ្វើផែនការដើម្បីដោះស្រាយតម្រូវការ
- **<u>ទម្រង់ ឃ</u> ៖** ចំណូលប៉ាន់ស្មានប្រចាំឆ្នាំ – ធនធានសក្តានុពល
- **<u>ទម្រង់ ង</u> ៖** សង្ខេបចំណាយទៅលើសកម្មភាពដែលបានធ្វើផែនការសម្រាប់ឆ្នាំនេះ (សម្រាប់សាលារៀនដែលដាក់ជូនសំណើ)
- **<u>ទម្រង់ ច</u> ៖ បរិយាយសកម្មភាពជាក់លាក់**
- ***<u>ទម្រង់ ឆ</u>*** ៖ គម្រោងពេលអនុវត្តសកម្មភាព
- ***<u>ទម្រង់ ជ</u>*** ៖ ការត្រួតពិនិត្យ និងវាយតម្លៃ

*ដំណើរការធ្វើផែនការ និងការប្រើប្រាស់គំរូធ្វើផែនការដែលបានធ្វើបមាណីយកម្ម៖* ចំណុចចាប់ផ្តើមសម្រាប់ការអនុវត្តកម្មវិធី SBEP គឺដំណើរការធ្វើផែនការអនុវត្តរបស់សាលា។ ផែនការកែលម្អសាលារៀន (SIP) ដែលស្ថិតក្រោមកម្មវិធី SBEP ដើរតាមគោលវិធីដែលមានការទទួលយកយ៉ាងល្អ ដែលចាប់ផ្តើមជាមួយនឹងការវិភាគតម្រូវការដែលដឹកនាំនៅក្នុងមូលដ្ឋាន។ ការវិភាគតម្រូវការ ត្រូវមានទម្រង់ជា *ស្វ័យវាយតម្លៃ* ដោយសាលារៀន-សហគមន៍ ដែលបន្ទាប់មកត្រូវសង្ខេប និងកំណត់អាទិភាពតម្រូវការទាំងនេះ ក្នុងទម្រង់ជាផែនការអភិវឌ្ឍន៍សាលា ដើម្បីដោះស្រាយតម្រូវការដែលបានដឹង (សូមមើលទម្រង់ ខ)។ ការវិភាគតម្រូវការ បន្ទាប់មកត្រូវមានការកំណត់នូវគោលបំណង សកម្មភាព ថវិកា គម្រោងពេលអនុវត្ត និងផែនការត្រួតពិនិត្យ។ ផលិតផលនីមួយៗនេះ នឹងត្រូវអភិវឌ្ឍន៍នៅក្នុងអំឡុងសិក្ខាសាលាមូលដ្ឋានគ្រឹះនៅដើមឆ្នាំសិក្សា។ កម្មវិធី SBEP នឹងសម្របសម្រួលដល់ដំណើរការផែនការកែលម្អសាលារៀន ដោយប្រើគំរូដែលបានធ្វើបមាណីយកម្ម ដែលបានអនុម័តយកតាមគម្រោង ESSUAP របស់ក្រសួង ដែលត្រូវបានកែប្រែដើម្បីឆ្លើយតបទៅនឹងបរិបទឯកទេសនៃវិស័យអប់រំនៅមធ្យមសិក្សា។ កម្មវិធី SBEP នឹងអភិវឌ្ឍន៍សៀវភៅបណ្តុះបណ្តាល និងតម្រង់ទិស ដើម្បីណែនាំដល់គណកម្មការទ្រទ្រង់សាលាអំពីក្របខ័ណ្ឌធ្វើផែនការ និងរបៀបបំពេញទម្រង់បែបបទអមមកជាមួយ។ ការណែនាំនេះ នឹងត្រូវបានហៅថា *សិក្ខាសាលាធ្វើផែនការមូលដ្ឋានគ្រឹះ* ហើយវានឹងត្រូវបានផ្តល់ជូនដោយក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក (DTMT) នៅថ្នាក់អប់រំមធ្យមសិក្សា។ ទម្រង់ដែលនឹងត្រូវប្រើសម្រាប់ការធ្វើផែនការសាលាក្រោមកម្មវិធី SBEP ត្រូវបានសង្ខេបនៅក្នុងប្រអប់ទី ៣ ហើយមានចែងលម្អិតទាំងស្រុងនៅក្នុងឧបសម្ព័ន្ធទី ២ នៃឯកសារនេះ។ គោលបំណងនៃទម្រង់នីមួយៗ ត្រូវបានសង្ខេបនៅក្នុងរូបភាពទី ២.៣ ដូចខាងក្រោម៖

**រូបភាព ២.៣ ៖ សង្ខេបមុខងារនៃទម្រង់គំរូសម្រាប់ធ្វើផែនការ**




ការអនុម័តយកតាមក្របខ័ណ្ឌធ្វើផែនការ ដែលពីមុនត្រូវបានអភិវឌ្ឍន៍ដោយក្រសួង ទទួលស្គាល់តម្រូវការក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការដែលអាចកើតឡើង ជាមួយនឹងការណែនាំអំពីលំហូរប្រាក់ចំណូលចំរុះនៅក្នុងសាលា ដែលប្រើគោលវិធីជំនួយសម្រាប់សាលារៀន ដើម្បីលើកកម្ពស់ការអភិវឌ្ឍសាលារៀន។ ដូច្នេះ

**រូបភាពទី ២.៤ ៖ ជំហាននៃដំណើរការធ្វើផែនការដែលរំពឹងទុកដោយក្រសួងអប់រំ**




គេយល់ថា ក្រសួងអប់រំនឹងត្រូវលើកកម្ពស់គំរូដែលបានធ្វើបមាណីយកម្មមួយ សម្រាប់ការធ្វើផែនការសាលានៅថ្នាក់មធ្យមសិក្សា ដើម្បីឲ្យសាលាត្រូវការធ្វើតែលំហាត់ធ្វើផែនការសាលារៀនតែមួយប៉ុណ្ណោះនៅដើមឆ្នាំសិក្សា ដែលអាចដាក់បញ្ចូលនូវប្រភពថវិកាពីគម្រោងជាច្រើន (ការគាំទ្រតាមគម្រោងរបស់អង្គការ Sida ចំពោះការអប់រំនៅកម្ពុជា តាមរយៈគ្រោងការជំនួយកែលម្អសាលារៀន)។ ការនេះ នឹងនាំទៅរកការបង្កើតផែនការកែលម្អសាលារៀនទូលំទូលាយតែមួយសម្រាប់សាលានីមួយៗ ជាជាងឯកសារធ្វើផែនការជាច្រើនដែលមានលក្ខណៈប្រកួតប្រជែងគ្នា និងដាច់ដោយឡែកពីគ្នា ដែលការអនុវត្តរបស់វានឹងជាបន្ទុកយ៉ាងធ្ងន់ទៅលើសមត្ថភាពរបស់គណកម្មការទ្រទ្រង់សាលា។ ដំណើរការធ្វើផែនការដែលបានរំពឹងទុកដោយក្រសួង អាចត្រូវបានសង្ខេប ដូចមានបង្ហាញនៅក្នុងរូបភាព ២.៤ ខាងលើ។

***ដំណើរការ និងជំហានអនុម័ត បន្ទាប់ពីបញ្ចប់សិក្ខាសាលាធ្វើផែនការមូលដ្ឋានគ្រឹះ ៖*** ជំនួយសម្រាប់កែលម្អសាលា នឹងត្រូវផ្អែកទៅលើផែនការកែលម្អសាលា ដែលបានដាក់ជូនដោយសាលា។ ផែនការកែលម្អសាលាដែលបានបញ្ចប់ នឹងត្រូវបញ្ជូនទៅកាន់ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក និងអ្នកសម្របសម្រួលថ្នាក់ខេត្តដើម្បីសុំចំណារពីពួកគេ។ នៅក្នុងការពិនិត្យផែនការឡើងវិញ អ្នកសម្របសម្រួលថ្នាក់ខេត្ត/ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ត្រូវប្រើគោលការណ៍ណែនាំស្តីពីការពិនិត្យផែនការកែលម្អសាលារៀន ដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី ៣។ ក្រោយពីមានចំណារពីអ្នកសម្របសម្រួលថ្នាក់ខេត្ត/ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ផែនការនោះត្រូវចុះហត្ថលេខាដោយការិយាល័យអប់រំស្រុក និងបញ្ជូនទៅឲ្យមន្ទីរអប់រំខេត្តដើម្បីពិនិត្យ និងសម្រេច។ ជួនកាល ប្រសិនបើមន្ទីរអប់រំមើលឃើញពីតម្រូវការត្រូវផ្លាស់ប្តូរនៅក្នុងផែនការកែលម្អសាលារៀន ត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរ ហើយងបញ្ជូនទៅសាលារៀនវិញតាមរយៈការិយាល័យអប់រំស្រុក។ ការពន្យល់ ត្រូវមានលក្ខណៈច្បាស់លាស់ និងលម្អិត។ ការនេះនឹងផ្តល់នូវការណែនាំនៅក្នុងការជួយដល់សាលារៀន ឲ្យបានយល់អំពីវិធីកែសម្រួលផែនការកែលម្អសាលារៀន និងកែ

លម្អជំនាញក្នុងការសរសេរ និងធ្វើផែនការរបស់ពួកគេ។ បន្ទាប់មក សាលារៀនត្រូវធ្វើការកែសម្រួលទៅតាមការគួរ ហើយដាក់ជូនផែនការរបស់ពួកគេម្ដងទៀត ដើម្បីសុំការពិនិត្យតាមរយៈការិយាល័យអប់រំស្រុក។

បន្ទាប់មក មន្ទីរអប់រំខេត្តត្រូវសុំការអនុម័តថវិកាសម្រាប់ផែនការកែលម្អសាលារៀនទាំងអស់នៅក្នុងខេត្តរបស់ខ្លួន ពីនាយកដ្ឋានមធ្យមសិក្សា ដែលបន្ទាប់ពីអនុម័តរួចហើយ ត្រូវសុំការអនុម័តចុងក្រោយពីអគ្គនាយកដ្ឋានអប់រំ ដែលបន្ទាប់មកអគ្គនាយកដ្ឋាននេះត្រូវអនុញ្ញាតឲ្យចេញថវិកាជំនួយដល់សាលារៀន (សូមមើលរូបភាពទី ២.៥)។ នៅពេលក្រសួងអប់រំបានអនុម័តលើបញ្ជីផែនការកែលម្អសាលារៀនរួចហើយ សាលារៀននឹងទទួលបានការជូនដំណឹងថា ផែនការរបស់ខ្លួនត្រូវបានអនុម័តយល់ព្រម។ ថវិកានឹងត្រូវចែកចាយដោយបើកចំហ និងមានតម្លាភាពក្នុងពិធីជាសាធារណៈមួយ។ នៅពេលសាលារៀនទទួលបានថវិកាហើយ សាលារៀននោះ ត្រូវតែអភិវឌ្ឍន៍ផែនការសកម្មភាពសម្រាប់ការអនុវត្តសកម្មភាពកែលម្អសាលារៀនរបស់ខ្លួន (សូមមើល**ឧបសម្ព័ន្ធ ឆ**)។ ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តជំនួយ ចាប់ផ្ដើមនៅពេលថវិកាជំនួយត្រូវបានបញ្ចេញ។ មេរៀនពិសោធន៍ដែលទទួលបានពីការអនុវត្ត នឹងក្លាយជាធាតុចូលសម្រាប់វគ្គសិក្ខាសាលាមូលដ្ឋានគ្រឹះនៅឆ្នាំក្រោយ។




**រូបភាព ២.៥៖ ដំណើរការអនុម័តសម្រាប់ …ផែនការ …ម្អសាលា**

គណកម្មការទ្រទ្រង់សាលា ត្រូវតែផ្ដល់ភស្ដុតាងអំពីការប្រជុំជាសាធារណៈដែលប្រកាសអំពីជំនួយថវិកាដល់សមាជិកសហគមន៍ និងសាលារៀន។ នៅក្នុងអង្គប្រជុំ សាលារៀន និងសហគមន៍ត្រូវអង្កេតមើលការរាប់ប្រាក់ជំនួយ ដើម្បីបញ្ជាក់ថាតើបានទទួលប្រាក់ចំនួនប៉ុន្មាន។ ការធ្វើបែបនេះ គឺដើម្បីលើកកម្ពស់តម្លាភាពនៅក្នុងគណនេយ្យជំនួយ។ ទាំងសាលារៀន ទាំងសហគមន៍ ត្រូវដឹងថា តើជំនួយមានប៉ុន្មាន ហើយ តើវានឹងត្រូវចំណាយទៅលើអ្វីខ្លះក្នុងមួយខែ ហើយចំណាយទៅលើអ្វីខ្លះ។ ក្ដារខៀនប្រកាសព័ត៌មាន អំពីរាល់សកម្មភាពទាំងអស់ ត្រូវដាក់តាំងបង្ហាញនៅក្រៅការិយាល័យរបស់សាលារៀន ដើម្បីឲ្យប្រជាពលរដ្ឋបានដឹង។ ការធ្វើបែបនេះ កសាងនូវការជឿជាក់ និងទំនុកចិត្តទៅលើការគ្រប់គ្រងក្នុងមូលដ្ឋាននៃប្រាក់ជំនួយ។

នៅក្នុងឆ្នាំបន្តបន្ទាប់របស់គម្រោង សាលារៀនត្រូវវាយតម្លៃឡើងវិញទៅលើផែនការរបស់ខ្លួន និងកំណត់អាទិភាពដោយផ្អែកលើមេរៀនពិសោធន៍ដែលទទួលបានពីឆ្នាំកន្លងមក។ នៅចុងឆ្នាំនីមួយៗ ពួកគេត្រូវវាយតម្លៃថាតើចក្ខុវិស័យ និងតម្រូវការរបស់ពួកគេនៅតែដូចគ្នាដែរឬទេ។ ផ្អែកលើបទពិសោធន៍ និងការវាយតម្លៃរបស់ពួកគេ សាលារៀនត្រូវសរសេរនូវសំណើថ្មីមួយសម្រាប់ឆ្នាំនោះ។

***ចំនួនទឹកប្រាក់ជំនួយសម្រាប់ការអនុវត្តផែនការកែលម្អសាលារៀន៖*** ជំនួយរបស់គម្រោង SBEP ដែលប្រើដើម្បីធ្វើឲ្យផែនការកែលម្អសាលារៀនមានភាពរស់រវើក គឺមានចំនួនថេរ ៥00 ដុល្លារ សម្រាប់សាលារៀនមួយ មិនថាសាលារៀននោះមានទំហំធំប៉ុណ្ណាទេ គឺផ្អែកទៅលើសំណើពីក្រសួងអប់រំអំពីការសរុបទឹកប្រាក់តាមបទដ្ឋានសម្រាប់សាលារៀននីមួយៗ។ ជំនួយនេះ អាចត្រូវបានបំពេញបន្ថែមដោយលំហូរប្រាក់ចំណូលផ្សេងៗ រួមមាន ជំនួយរបស់អង្គការ Sida ដែលនឹងផ្តល់ដល់សាលារៀនប្រហែល ៤00 ដុល្លារ ជាថវិកាជំនួយបន្ថែមជាមធ្យម។ ជំនួយរបស់កម្មវិធី SBEP នឹងត្រូវបញ្ចេញជាពីរដំណាក់កាលក្នុងអំឡុងឆ្នាំនោះគឺ ៣00 ដុល្លារ និង ២00 ដុល្លារ។ ការបញ្ចេញថវិកាលើកទីមួយត្រូវមានចំនួនច្រើនជាង ដើម្បីធានាថាសាលារៀនអាចផ្តួចផ្តើមសកម្មភាពនៅដើមឆ្នាំ ទោះបីជាថវិកាប្រតិបត្តិការសាលារៀនមិនទាន់បានផ្តល់ទៅឲ្យសាលារៀនក៏ដោយ។ ទោះបីជាថវិកាទាំងពីរភាគនេះ ត្រូវបានធ្វើបមាណីយកម្មក្នុងចំនួនទឹកប្រាក់ថេរក៏ដោយ ថវិកាមួយភាគៗត្រូវតែផ្អែកលើសកម្មភាពទាំងឡាយដែលបានកំណត់នៅក្នុងផែនការកែលម្អសាលាដែលបានអភិវឌ្ឍន៍ដោយសាលារៀននីមួយៗនៅដើមឆ្នាំសិក្សាដែរ។ ក្រសួងយល់ឃើញថា ការកំណត់រយៈពេលនៃការបញ្ចេញជំនួយទាំងនេះ មានលក្ខណៈសំខាន់ចំពោះភាពជោគជ័យនៃសកម្មភាពអភិវឌ្ឍន៍សាលារៀន ជាមួយនឹងថវិកាភាគទីមួយ ដែលនឹងត្រូវបញ្ចេញឲ្យយ៉ាងយូរបំផុតត្រឹមខែតុលានៃឆ្នាំសិក្សានីមួយៗ។ ការធ្វើបែបនេះ នឹងធានាបាននូវការបំពេញ និងការអនុម័តសកម្មភាពនៃផែនការកែលម្អសាលារៀនក្នុងអំឡុងខែសីហា-កញ្ញា។ ថវិកាភាគទីពីរ នឹងត្រូវបញ្ចេញឲ្យនៅក្នុងឆមាសទីពីរ ត្រឹមខែមីនានៃឆ្នាំនីមួយៗ។ ការបញ្ចេញថវិកាទីពីរ នឹងអាស្រ័យទៅលើការពិនិត្យដោយជោគជ័យ ទៅលើរបៀបដែលថវិកាភាគទីមួយត្រូវបានប្រើប្រាស់ ហើយតើបានប្រកាន់ខ្ជាប់តាមគោលការណ៍អភិបាលកិច្ចល្អ គណនេយ្យភាព និងតម្លាភាពត្រឹមត្រូវដែរឬទេ។

***ក្របខ័ណ្ឌផែនការរបស់កម្មវិធី SBEP និងគោលនយោបាយកុមារមេត្រី៖*** ក្របខ័ណ្ឌផែនការដែលអនុម័តយកតាមដោយកម្មវិធី SBEP ក៏នឹងលើកកម្ពស់ការអនុវត្តគោលនយោបាយកុមារមេត្រីរបស់ក្រសួងអប់រំផងដែរ។ ហេតុដូច្នេះហើយ ទើបគំរូដែលបានអនុម័តយក តម្រូវឲ្យសាលារៀនរៀបចំសកម្មភាពដែលបានសម្រាំងរបស់ពួកគេ ឲ្យទៅជាកម្រងសកម្មភាពចំនួនប្រាំមួយ ដែលកម្រងនីមួយៗឆ្លើយតបទៅនឹងវិមាត្រទាំងប្រាំមួយដែលបានកំណត់នៅក្នុងគោលនយោបាយសាលាកុមារមេត្រី។ ខណៈកម្មវិធី SBEP នឹងជម្រុញឲ្យមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងទៅលើការទប់ស្កាត់ការបោះបង់ចោលការសិក្សា និងបរិយាកាសសិក្សាសម្បូរបែប ទិដ្ឋភាពផ្សេងៗនៃបរិបទរបស់សាលារៀន ក៏នឹងត្រូវយកមកពិចារណាផងដែរ ដោយផ្អែកទៅលើព័ត៌មានត្រឡប់ពីអ្នកពាក់ព័ន្ធនៅអំឡុងពេលនៃការពិភាក្សារបស់ក្រុមទទួលបន្ទុក។ ការនេះរួមមានសំណើសុំសាងសង់បង្គន់អនាម័យ ការប្រើប្រាស់ការអប់រំបច្ចេកវិទ្យា ICT ខ្លះ ការធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងសកម្មភាពផ្សេងៗដែលនឹងពង្រីកបរិស្ថានសាលារៀនផងដែរ។ ការទទួលស្គាល់នូវ

កង្វល់ទាំងនេះ ដែលជាកង្វល់ដែលបានសម្តែងដោយអ្នកពាក់ព័ន្ធ នឹងជួយជម្រុញឲ្យមានកំណើនភាពជាកម្មសិទ្ធិ និងនិរន្តរភាពនៃសកម្មភាពរបស់កម្មវិធី។ ដូច្នេះហើយ ទើបគោលវិធីធ្វើផែនការសាលារៀនរបស់កម្មវិធី SBEP ប្រកាន់យកគំនិតអភិវឌ្ឍន៍ដែលជម្រុញដោយអ្នកពាក់ព័ន្ធ ដែលក្នុងនោះនឹងមានជម្រើសសកម្មភាពទាំងឡាយណាដែលសាលារៀនអនុវត្ត។ គោលវិធីនេះ ក៏មានសង្គតិភាពជាមួយនឹងទស្សនវិជ្ជាដែលបានដាក់ចេញដោយក្របខ័ណ្ឌគោលនយោបាយសាលាកុមារមេត្រីផងដែរ។ ការប្រើ *ម៉ឺនុយសកម្មភាព* ដែលបានស្នើដោយក្រសួងអប់រំ និងផ្អែកលើសំណើរបស់អ្នកពាក់ព័ន្ធនូវសកម្មភាពជាច្រើន ដើម្បីទប់ស្កាត់ការបោះបង់ចោលការសិក្សា នឹងក្លាយទៅជាមធ្យោបាយគន្លឹះ ដើម្បីធានានូវគោលវិធីដែលបានជម្រុញដោយអ្នកពាក់ព័ន្ធសម្រាប់ការអនុវត្តកម្មវិធី SBEP ។

### ២.៣.២ ការប្រើម៉ឺនុយដើម្បីលើកកម្ពស់ភាពជាកម្មសិទ្ធិ និងការសម្របសកម្មភាពទៅតាមបរិបទក្នុងមូលដ្ឋាន

*គោលគំនិតអភិវឌ្ឍន៍សំខាន់ៗដែលបានលើកកម្ពស់ដោយការប្រើប្រាស់ម៉ឺនុយសកម្មភាព៖* ការប្រើប្រាស់ម៉ឺនុយសកម្មភាពដូចជា គោលគំនិតមួយដែលបានស្នើនៅក្នុងការបង្កើតកម្មវិធី SBEP ជួយធានាបានថាអន្តរាគមន៍របស់គម្រោងត្រូវបានដាក់បញ្ចូលទៅក្នុងបរិបទជាក់លាក់មួយបានយ៉ាងត្រឹមត្រូវ។ ការពិភាក្សារបស់ក្រុមទទួលបន្ទុកនៅក្នុងខេត្តខុសៗគ្នា ដែលត្រូវបានរៀបចំឡើងជាផ្នែកនៃដំណើរការបង្កើតតាមបែបចូលរួមសម្រាប់កម្មវិធី SBEP បានបង្ហាញនូវបញ្ហាខុសៗគ្នាជាច្រើនដែលអ្នកពាក់ព័ន្ធប្រឈម។ ការប្រើម៉ឺនុយសកម្មភាព ជួយធានាថា អ្នកពាក់ព័ន្ធអាចដាក់បញ្ចូលទៅក្នុងបរិបទនូវអន្តរាគមន៍ទាំឡាយដែលបានគាំទ្រដោយគម្រោងនេះ ដើម្បីឲ្យអន្តរាគមន៍ទាំងនេះមានភាពពាក់ព័ន្ធ និងឆ្លើយតបទៅនឹងតម្រូវការដែលបានដឹង។ ការធ្វើបែបនេះ ពួកគេនឹងដឹងច្បាស់នូវគោលដៅរបស់កម្មវិធី SBEP ក្នុងការជម្រុញ *អន្តរាគមន៍ដែលផ្តួចផ្តើមគំនិតដោយសាលារៀន (SII)*។ គោលវិធីនេះ នឹងជួយលើកកម្ពស់គោលគំនិតសំខាន់ៗនៅក្នុងការអភិវឌ្ឍដូចជា "ការផ្តល់អំណាច" "ភាពជាកម្មសិទ្ធិ" និង "និរន្តរភាព"។ បន្ទាប់ពីមានគំរូអភិវឌ្ឍន៍ដែលជម្រុញពីផ្នែកកណ្តាល បច្ចុប្បន្ននេះមានការទទួលស្គាល់ជាទូទៅថា ដើម្បីសម្រេចបាននូវផែនការកែលម្អសាលារៀន និងការអនុវត្តប្រកបដោយភាពជោគជ័យ គេត្រូវធានា អ្នកពាក់ព័ន្ធមានអារម្មណ៍ថាត្រូវបានគេផ្តល់អំណាចនៅពេលអភិវឌ្ឍន៍ឧបករណ៍ធ្វើផែនការទាំងនេះ។ ការផ្តល់អំណាចកើតឡើងនៅពេលណាអ្នកពាក់ព័ន្ធមានអារម្មណ៍ថា ពួកគេបានធ្វើជម្រើសដោយខ្លួនឯងនូវអ្វីដែលពួកគេចង់ធ្វើ ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ។ អត្ថន័យនៃការផ្តល់អំណាច នឹងផ្តល់មកវិញនូវការធានាថា ក្រុមការងារនៅក្នុងមូលដ្ឋានមានភាពជាកម្មសិទ្ធិទៅលើផែនការអនុវត្តរបស់ខ្លួន។ នៅពេលមានភាពជាកម្មសិទ្ធិទៅលើផែនការហើយ វារឹតតែទំនងថែមទៀតថា អ្នកពាក់ព័ន្ធនឹងប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីធ្វើឲ្យមាននិរន្តរភាពសកម្មភាពដែលពួកគេបានកំណត់។ ដូច្នេះ ពួកគេម្នាក់ៗអាចមើលឃើញពីសំណុំទំនាក់ទំនងដ៏មានសារៈសំខាន់មួយរវាងគោលគំនិតទាំង ៣ ដូចខាងក្រោមនេះ ៖

**រូបភាព ២.៦៖ ការលើកកម្ពស់និរន្តរភាពតាមរយៈការផ្តល់អំណាច**




*សេរីភាពនៅក្នុងរចនាសម្ព័ន្ធ៖* ទស្សនវិជ្ជាដែលបង្កើតបានជាមូលដ្ឋានសម្រាប់ទ្រទ្រង់ការប្រើប្រាស់ម៉ឺនុយ

ផែនការនៅក្នុងការអនុវត្តគម្រោង អាចបូកសរុបបានយ៉ាងល្អបំផុតដោយពាក្យ "សេរីភាពនៅក្នុងរចនាសម្ព័ន្ធ" ។ កម្មវិធី SBEP ព្យាយាមចៀសវាងគោលវិធីដាក់បញ្ញត្តិចំពោះការអភិវឌ្ឍ ប៉ុន្តែទទួលស្គាល់នូវឧបសគ្គនៃការអនុវត្តនៅក្នុងគម្រោងដែលបានជម្រុញដោយអ្នកពាក់ព័ន្ធក្នុងបរិបទកម្ពុជា។ វានិយាយអំពីកង្វះបទពិសោធន៍ និងការប្រឈមរបស់សាលារៀន និងសហគមន៍ទៅនឹងវិធីថ្មីក្នុងការធ្វើអ្វីមួយ។ ការប្រើប្រាស់ម៉ឺនុយ ផ្តល់នូវកាលានុវត្តភាពសម្រាប់ការផ្តល់អំណាចនៅក្នុងរចនាសម្ព័ន្ធមួយ ដែលទទួលស្គាល់ឧបសគ្គនៅក្នុងមូលដ្ឋានទាំងនេះ។ វាផ្តល់នូវ "ផ្លូវកណ្តាល" រវាងបញ្ហាទាំងពីរនេះគឺ "ការចៀសវាងការដាក់បញ្ញត្តិ" និង "ការទទួលស្គាល់ថា អ្នកពាក់ព័ន្ធក្នុងមូលដ្ឋានតែងតែខ្វះបទពិសោធន៍ និងការប្រឈមទៅនឹងគំនិតថ្មីៗ។"

*រចនាសម្ព័ន្ធនៃម៉ឺនុយសកម្មភាព៖* ម៉ឺនុយសកម្មភាពដែលបានអភិវឌ្ឍន៍ជាផ្នែកនៃការបង្កើតកម្មវិធី SBEP ត្រូវបានកំណត់រចនាសម្ព័ន្ធជាម៉ាទ្រិចមួយដែលមានកូឡោនប្រាំមួយ។ សំណើម៉ឺនុយសកម្មភាពដែលនឹងត្រូវប្រើនៅក្នុងគម្រោងនេះ មានចែងនៅក្នុងឧបសម្ព័ន្ធទី ៤។ ដើម្បីលើកកម្ពស់គោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា សកម្មភាពទាំងអស់ត្រូវបានរៀបចំ ក្នុងន័យវិមាត្រសាលាកុមារមេត្រីដែលវាតំណាងឲ្យ។ វិមាត្រទាំងអស់មានប្រាំមួយគឺ៖

| | |
|---|---|
| ១. ការអប់រំបញ្ចូលគ្នា (និងសមធម៌យេនឌ័រ) | <u>កូដពណ៌៖</u> ខៀវ |
| ២. ការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាព | <u>កូដពណ៌៖</u> ទឹកសមុទ្រ |
| ៣. សុខភាព សុវត្ថិភាព និងការការពារ | <u>កូដពណ៌៖</u> ក្រហម |
| ៤. សមធម៌យេនឌ័រ (បញ្ចូលជាមួយវិមាត្រទី ១) | <u>កូដពណ៌៖</u> -- |
| ៥. ការចូលរួមរបស់កុមារ មាតាបិតា និងសហគមន៍ | <u>កូដពណ៌៖</u> ផ្កាឈូក |
| ៦. បរិយាកាសអនុញ្ញាត៖ អភិបាលកិច្ចសាលារៀន | <u>កូដពណ៌៖</u> ទឹកក្រូច |

ម៉ឺនុយសកម្មភាព ត្រូវបានកំណត់រចនាសម្ព័ន្ធ ដើម្បីឲ្យវាមានភាពងាយស្រួលសម្រាប់អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ក្នុងការប្រើប្រាស់នៅថ្នាក់សាលារៀន។ ឧទាហរណ៍ "សកម្មភាពត្រូវបានរៀបចំជា**វិមាត្រសាលាកុមារមេត្រី** ហើយត្រូវបានដាក់កូដពណ៌ ដូចដែលបានកត់សម្គាល់នៅខាងលើ ដើម្បីងាយស្រួលរកមើល។ វិមាត្រសាលាកុមារមេត្រី គឺជាកូឡោនទីមួយ ដែលម្នាក់ៗអាចមើលឃើញនៅក្នុងមាទ្រិចនៅលើផ្នែកខាងចុងឆ្វេងដៃ។ សកម្មភាពក៏ត្រូវបានរៀបចំជាបញ្ហាដែលវាជួយដោះស្រាយផងដែរ។ បញ្ហានីមួយៗមានរាយបញ្ជីនៅក្នុងកូឡោនឈ្មោះ **វិស័យបញ្ហា** នៃម៉ាទ្រិចម៉ឺនុយសកម្មភាព។ ក្រោយពីអ្នកពាក់ព័ន្ធបានកំណត់បញ្ហារបស់ពួកគេនៅក្នុង **ទម្រង់ ខ** នៃគំរូផែនការរួចហើយ (សូមមើលរូបភាពទី ២.៣) ពួកគេអាចបើកកូនសៀវភៅម៉ឺនុយនោះ ហើយព្យាយាម **ផ្គូផ្គង** បញ្ហារបស់ខ្លួនជាមួយនឹងសកម្មភាពសមស្របមួយដែលបានបង្កើតដើម្បីដោះស្រាយវា។ ដើម្បីឲ្យប្រាកដ ក៏មានសកម្មភាពស្នូលមួយចំនួនផងដែរ ដែលសាលារៀននឹងត្រូវបានតម្រូវឲ្យអនុវត្តជាផ្នែកនៃទ្រឹស្តីរួមនៃការផ្លាស់ប្តូរដែលបានគូសបញ្ជាក់ពីខាងដើម។ ក្នុងន័យនេះ សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការបង្រៀនបន្ថែមមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ក៏ដូចជាបំណិនសមត្ថភាពធ្វើការងារ នឹងត្រូវបានតម្រូវសម្រាប់ការដាក់បញ្ចូលទៅក្នុងផែនការកែលម្អសាលារៀន ទោះបីជាការអនុវត្តរបស់វានឹងត្រូវយកធនធានពីថវិកា ESDP III កណ្តាលក៏ដោយ។

អ្នកពាក់ព័ន្ធអាចសម្រេចចិត្តក្នុងចំណោមពួកគេ ថាតើពួកគេចូលចិត្តសកម្មភាពមួយនោះដែរឬទេ ឬ

ថាតើវាពាក់ព័ន្ធនឹងបរិបទរបស់ពួកគេដែរឬទេ តាមរយៈការអាន**បរិយាយសកម្មភាព**ខ្លីដែលនៅជាមួយនឹងសកម្មភាពនីមួយៗ។ នៅក្នុងបរិយាយសកម្មភាព មានពាក្យមួយ ឬច្រើន ដែលមានចែងជា *អក្សរទ្រេត* ដើម្បីសង្កត់ធ្ងន់ទៅលើសកម្មភាពទាំងឡាយណាដែលត្រូវធ្វើ ដើម្បីធ្វើឲ្យសកម្មភាពនេះកើតឡើងបាន។ ពាក្យដែលបានធ្វើឲ្យទៅជាអក្សរទ្រេតទាំងនេះ តាមធម្មតាគឺជាកិរិយាស័ព្ទដូចជា *ផ្តល់ កសាង ធ្វើ រៀបចំ* ។ល។ ការប្រើពាក្យសកម្មភាពទាំងនេះនៅក្នុងផែនការកែលម្អសាលារៀន ជួយរក្សាឲ្យផែនការនេះផ្តោតទៅលើ *សកម្មភាពជាក់ស្តែង* ហើយចៀសវាងការប្រើប្រាស់អ្វីដែលជួនកាលត្រូវបានហៅថា ពាក្យពេចន៍ផែនការ "ក្លែងក្លាយ"។ ពាក្យពេចន៍ផែនការក្លែងក្លាយ រួមមានពាក្យដូចជា *ពង្រឹង លើកទឹកចិត្ត ផ្សព្វផ្សាយ* ។ល។ ហើយមិនមានលក្ខណៈច្បាស់លាស់ទេ ទាក់ទងនឹងប្រភេទនៃសកម្មភាពដែលត្រូវកំណត់នៅក្នុងផែនការ។ ជាផ្នែកនៃដំណើរការពិនិត្យផែនការកែលម្អសាលារៀន ដែលបានដាក់ជូនក្រោមកម្មវិធី SBEP ផែនការទាំងឡាយណាដែលប្រើពាក្យបច្ចេកទេសទាំងនេះ ត្រូវកែសម្រួលឡើងវិញ។ ដោយសារបរិយាយសកម្មភាពមានលក្ខណៈខ្លី វាក៏មានរូបភាពមួយផងដែរ ដែលផ្តល់មកជាមួយនឹងសកម្មភាពនីមួយៗ ដើម្បីជួយឲ្យអ្នកអានបានយល់ដឹងកាន់តែប្រសើរថាតើសកម្មភាពនោះនិយាយអំពីអ្វី។ រូបភាពនោះមាននៅក្នុងកូឡោន **រូបភាព** នៅចុងស្តាំដៃនៃម៉ាទ្រិច។ រូបភាពទាំងនេះ អាចមានសារៈប្រយោជន៍សម្រាប់អ្នកពាក់ព័ន្ធទាំងឡាយណាដែលបំណិនអក្ខរកម្មនៅមានកម្រិត។ សកម្មភាពទាំងឡាយនៅក្នុងម៉ឺនុយនីមួយៗមាន **លេខយោង** មួយ ដើម្បីងាយស្រួលរកមើលវា។ ប្រសិនបើសមាជិកក្រុមធ្វើផែនការ សុំឲ្យនរណាម្នាក់ផ្សេងទៀតមើលសកម្មភាពជាក់លាក់ណាមួយនោះ វានឹងមានសារៈប្រយោជន៍ក្នុងការធានាថា ម្នាក់ៗសុទ្ធតែកំពុងអាននៅលើទំព័រតែមួយដូចគ្នា។

សរុបទាំងអស់ មានសកម្មភាពខុសៗគ្នាចំនួន ៣២ ដែលត្រូវបានរាយបញ្ជីនៅក្នុងម៉ឺនុយសកម្មភាព ដើម្បីព្យាយាមជួយអ្នកពាក់ព័ន្ធ ក្នុងការកំណត់សកម្មភាពសមស្របដែលអាចដោះស្រាយបញ្ហានានា ដែលពួកគេបានជួបប្រទះនៅក្នុងសាលារៀន-សហគមន៍របស់ពួកគេ។ ដូចបានកត់សម្គាល់ពីខាងដើម សកម្មភាពទាំងនេះត្រូវបានផ្តល់ជូន ពីព្រោះអ្នកពាក់ព័ន្ធជាច្រើនមានការប្រឈមមានកម្រិតទៅនឹងមធ្យោបាយពីខាងក្រៅក្នុងការធ្វើអ្វីមួយ។ *ទោះជាយ៉ាងណា ប្រសិនបើអ្នកពាក់ព័ន្ធមានគំនិតយោបល់ផ្ទាល់ខ្លួន សម្រាប់សកម្មភាពសមស្របមួយ ឬម៉ឺនុយសកម្មភាពបានជួយដល់ពួកគេក្នុងការបង្កើតសកម្មភាពថ្មីមួយនោះ ពួកគេអាចនឹងដាក់បញ្ចូលសកម្មភាពនេះទៅក្នុងផែនការរបស់ពួកគេយ៉ាងប្រាកដ ដរាបណាអាចផ្តល់យុត្តាធិការសមហេតុផល។* ដូច្នេះ ម៉ឺនុយសកម្មភាព មិនមានគោលបំណងធ្វើជាឧបករណ៍ដាក់កម្រិតឡើយ ប៉ុន្តែជាឧបករណ៍មួយដែលផ្តល់នូវវចនាសម្ព័ន្ធសកម្មភាពដែលមានតុល្យភាព សម្រាប់ឲ្យអ្នកពាក់ព័ន្ធយកទៅពិចារណា។

ជាទីបញ្ចប់ សកម្មភាពនីមួយនៅក្នុងម៉ឺនុយ ក៏ដាក់បញ្ចូលនូវបញ្ជីខ្លីមួយអំពី **ធនធានសញ្ញាណ** ដែលម្នាក់ៗត្រូវតែអនុវត្តសកម្មភាពដែលបានបញ្ជាក់ផងដែរ។ នៅក្នុងផែនការណាមួយក៏ដោយ ម្នាក់ៗត្រូវធ្វើផែនការថវិកាមួយដែលគូសបញ្ជាក់អំពីធនធាននានា ដែលត្រូវការសម្រាប់អនុវត្តសកម្មភាពមួយ។ កូឡោនធនធានសញ្ញាណអាចជួយឲ្យអ្នកពាក់ព័ន្ធកំណត់ធនធានទាំងនេះបានយ៉ាងងាយស្រួល ដើម្បីឲ្យពួកគេអាចរៀបរាប់ធនធានទាំងនេះបាននៅក្នុងកញ្ចប់ថវិកា។ ធនធានទាំងនេះ អាចរួមមានសម្ភារៈជាក់លាក់ (ឧ. សៀវភៅណែនាំបច្ចេកទេសជាក់លាក់ណាមួយ) សម្ភារៈសិក្សា សាច់ប្រាក់សម្រាប់គោលបំណងផ្សេងៗគ្នា

(ឧ. ភ្នាក់ងារទេសចរណ៍) និងធនធានមនុស្សផងដែរ។ ដើម្បីកម្រិតបរិមាណចំណាយជាប្រាក់នៃធនធាននីមួយៗ ផ្នែកចំណាយជាឯកតា នឹងមានចែងនៅផ្នែកខាងចុងនៃកូនសៀវភៅម៉ឺនុយ ដើម្បីជួយដល់អ្នកពាក់ព័ន្ធជាមួយនឹងដំណើរការនេះ។

### ២.៣.៣ ការធ្វើចំណាត់ថ្នាក់សាលារៀន និងការលៃតម្រូវការគាំទ្រជំនួយ

ការយល់ដឹងដ៏សំខាន់អំពីគម្រោងជំនួយសាលារៀនពីមុនមកគឺថា សាលារៀនមានភាពខុសៗគ្នាយ៉ាងទូលំទូលាយ ក្នុងន័យសមត្ថភាព និងតម្រូវការនីមួយៗរបស់សាលារៀននោះ។ ដោយពិចារណាអំពីភាពខុសគ្នាទាំងនេះ វាមិនមែនជាការវៃឆ្លាតនោះទេដែលចាត់ទុកថា សាលារៀនទាំងអស់សុទ្ធតែដូចគ្នាទាក់ទងនឹងសកម្មភាពដែលពួកគេអាចនឹងជ្រើសរើស។ គម្រោងមួយចំនួន បានអភិវឌ្ឍន៍គោលវិធីពហុកម្រិតនៅក្នុងរចនាសម្ព័ន្ធនៃការលៃចែកជំនួយរបស់ខ្លួន ដើម្បីឲ្យសាលារៀនដែលមានសមត្ថភាពខ្លាំងជាងគេចាត់ចែងធនធានដើម្បីទទួលបានការគាំទ្រជំនួយច្រើន ចំណែកសាលារៀនដែលមានសមត្ថភាពខ្សោយទទួលបាននូវកម្រិតនៃការគាំទ្រ ដែលត្រូវបានលៃតម្រូវទៅនឹងសមត្ថភាពរបស់ខ្លួន ដើម្បីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ខណៈពេលទទួលស្គាល់នូវសារៈសំខាន់នៃការចៀសវាងគោលវិធី "ទំហំមួយត្រូវទាំងអស់" នៅក្នុងការផ្តល់ជំនួយ ក្រសួងអប់រំបានជ្រើសរើសយកចំណាត់ថ្នាក់សាលារៀនទៅជាពីរកម្រិត៖ (i) សាលារៀន*ដែលជួបការលំបាក* (ផ្អែកលើគោលការណ៍ណែនាំរបស់នាយកដ្ឋានបុគ្គលិក) និង (ii) សាលារៀន*ធម្មតា*។ ក្នុងន័យនេះ លក្ខណៈវិនិច្ឆ័យសំខាន់មួយក្នុងការធ្វើចំណាត់ថ្នាក់សាលារៀនថាជាសាលារៀនជួបការលំបាក ទាក់ទងទៅនឹងអត្រាបំពេញមានកម្រិតទាបប៉ុណ្ណា។ ជាជាងការអភិវឌ្ឍម៉ឺនុយខុសៗគ្នាសម្រាប់ប្រភេទសាលារៀននីមួយៗ ក្រសួងអប់រំបានសម្រេចរឹតត្បិតសកម្មភាពមួយចំនួន ដែលសាលារៀន*ជួបការលំបាក* អាចដាក់បញ្ចូលនៅក្នុងផែនការកែលម្អសាលារៀនរបស់ខ្លួន ដើម្បីកុំឲ្យលើសបន្ទុកសមត្ថភាពរបស់ពួកគេក្នុងការចាត់ចែងសកម្មភាពទាំងនេះ។ ក្នុងន័យនេះ សាលារៀនជួបការលំបាក នឹងត្រូវបានកម្រិតចំពោះសកម្មភាពពីប្រាំទៅប្រាំមួយក្នុងមួយឆ្នាំ ចំណែកសាលារៀនធម្មតា អាចអនុវត្តបានច្រើនចាប់ពីដប់ទៅដប់ពីរសកម្មភាព ដោយមិនរាប់បញ្ចូលទាំងសកម្មភាពស្នូលដែលនឹងត្រូវប្រើធនធានពីថវិកា ESDP III កណ្តាលទេ។

### ២.៣.៤ សកម្មភាពពង្រីកកម្មវិធីសិក្សាវិទ្យាសាស្រ្ត និងគណិតវិទ្យា

***ពង្រឹងការអប់រំគណិតវិទ្យា៖*** ESDP III នឹងបង្កើនការសាកល្បងធ្វើវិក្រឹត្រការគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា (Math-INSET) ដែលបានអភិវឌ្ឍន៍ និងអនុវត្តតាមរយៈគម្រោងអប់រំមូលដ្ឋាន និងបណ្ដុះបណ្ដាលគ្រូបង្រៀន (BETT) ដែលបានគាំទ្រដោយសហប្រតិបត្តិការបច្ចេកទេសប៊ែលហ្ស៊ិក[1]។ Math-INSET មានបំណងពង្រឹងចំណេះដឹងលើមុខវិជ្ជា និងជំនាញក្នុងការបង្រៀនរបស់គ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យានៅតាមអនុវិទ្យាល័យ ដើម្បីប្រើប្រាស់វិធីសាស្រ្តបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល។ Math-INSET មានលក្ខណៈស្របគ្នាជាមួយនឹងកម្មវិធីសិក្សាជាតិ និងសៀវភៅសិក្សាដែលមានស្រាប់ សម្រាប់មុខវិជ្ជាគណិតវិទ្យានៅថ្នាក់

[1] គម្រោង BETT ត្រូវបានអនុវត្តចាប់ពីឆ្នាំ ២០០៣-២០១១ នៅក្នុងខេត្តចំនួន ៣ គឺ៖ សៀមរាប ឧត្តរមានជ័យ និងកំពង់ចាម។ ការបណ្តុះបណ្តាលគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យា សម្រាប់ថ្នាក់អនុវិទ្យាល័យ គឺជាសមាសភាពមួយនៃកិច្ចប្រឹងប្រែងបណ្តុះបណ្តាលគ្រូបង្រៀនកាន់តែធំ ដែលគ្របដណ្តប់លើមុខវិជ្ជាផ្សេងៗទាំងនៅថ្នាក់បឋមសិក្សា និងថ្នាក់អនុវិទ្យាល័យ។ ចាប់តាំងពីឆ្នាំ ២០១១ មក ធនធានបង្រៀន និងរៀនមុខវិជ្ជាគណិតវិទ្យាសម្រាប់គ្រូ និងសិស្ស ដែលត្រូវបានអភិវឌ្ឍន៍ក្រោមគម្រោងនេះគឺស្ថិតក្រោមភាពជាកម្មសិទ្ធិរបស់ក្រសួងអប់រំ។

អនុវិទ្យាល័យ។ វារួមមាន ៦ ជំពូកមេរៀន ដែលដោះស្រាយការបង្រៀនលើផ្នែកមួយចំនួនដូចតទៅ៖ ចំនួនការគណនា ពិជគណិត ស្ថិតិ ធរណីមាត្រ រង្វាស់។ ជំពូកមេរៀននីមួយៗ គ្របដណ្ដប់លើគោលគំនិត ចំណេះដឹង និងបំណិន គរុកោសល្យ និងសកម្មភាពសិក្សា។

ESDP III នឹងបង្កើតការបង្កើន Math-INSET ដោយសម្របសម្រួលជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ការបង្កើន Math-INSET នឹងសម្របទៅតាមរចនាសម្ព័ន្ធ និងការរៀបចំសម្រាប់ការធ្វើវិក្រឹត្រការគ្រូបង្រៀន ដែលបានផ្ដល់តាមរយៈមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ (ឧ. INSET នៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ) ដែលបានបង្កើតឡើងក្រោមគម្រោងអប់រំគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្ររបស់អង្គការ JICA (STEPSAM)។ គម្រោងនេះ ក៏នឹងសម្របសម្រួលជាមួយ អគ្គនាយកដ្ឋានអប់រំ (DGSE) ដើម្បីផលិតឡើងវិញនូវសម្ភារៈឧបទ្ទេសសម្រាប់ការបង្រៀនមុខវិជ្ជាគណិតវិទ្យានៅក្នុងថ្នាក់ BETT ផងដែរ។ គម្រោងនេះ នឹងគាំទ្រដល់ការផ្សព្វផ្សាយសម្ភារៈឧបទ្ទេសនៃថ្នាក់រៀន BETT ទៅដល់សាលារៀនអនុវិទ្យាល័យទាំង ១៥០០ នៅទូទាំងប្រទេស។ សម្ភារៈឧបទ្ទេសទាំងអស់របស់ BETT ស្ថិតក្រោមភាពជាកម្មសិទ្ធិរបស់ក្រសួងអប់រំ។ ការបណ្ដុះបណ្ដាលគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យានៅតាមសាលាអនុវិទ្យាល័យ (ឧ. INSET នៅតាមសាលារៀន) នឹងត្រូវធ្វើឡើងដោយប្រធានក្រុមបច្ចេកទេស តាមរយៈការប្រជុំក្រុមបច្ចេកទេស។ នាយកសាលា/នាយករងអនុវិទ្យាល័យ ត្រូវទទួលខុសត្រូវក្នុងការធានាឲ្យបាននូវការប្រជុំក្រុមបច្ចេកទេសដែលដឹកនាំដោយប្រធានក្រុមបច្ចេកទេស។[2]

*ពង្រឹងការអប់រំវិទ្យាសាស្ត្រ៖* ESDP III នឹងបង្កើតកម្មវិធីសាកល្បងការធ្វើវិក្រឹត្រការគ្រូបង្រៀនមុខវិជ្ជាវិទ្យាស្ត្រ (Science-INSET) សម្រាប់អនុវិទ្យាល័យចំនួន ១០០ ដែលជាបណ្ដាញរបស់សាលាមធ្យមសិក្សាធនធាន – មជ្ឈមណ្ឌលមធ្យមសិក្សាធនធាន (SRS-SRC) ដែលបានទទួលស្គាល់ដោយប្រកាសរបស់ក្រសួងអប់រំលេខ ៣២៧៧[3]។ បញ្ជីសាលអនុវិទ្យាល័យនៅក្នុងបណ្ដាញសាលាមធ្យមសិក្សាធនធាន – មជ្ឈមណ្ឌលមធ្យមសិក្សាធនធាននីមួយៗ មាននៅក្នុងឧបសម្ព័ន្ធទី ៥។ ការបង្កើតកម្មវិធីសាកល្បង Science-INSET នឹងត្រូវអភិវឌ្ឍន៍ដោយមានការសម្របសម្រួលជាមួយនឹងនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្រការ (TTD) អង្គការ JICA និងសមាគម Flemish សម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយបច្ចេកទេស (VVOB)។ **ការបង្កើតនេះ នឹងផ្អែកលើគំរូ** INSET **នៅតាមសាលារៀនដែលបានបង្កើតឡើងក្រោមគម្រោង** STEPSAM របស់អង្គការ JICA មានបំណងពង្រឹងចំណេះដឹងលើមុខវិជ្ជា និងជំនាញក្នុងការបង្រៀនរបស់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅតាមអនុវិទ្យាល័យ ដើម្បីប្រើប្រាស់គោលវិធីសិក្សា និងស្រាវជ្រាវមេរៀន។

គម្រោងនេះនឹងគាំទ្រការបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់ជាតិចំនួន ២០ ដែលនឹងត្រូវបង្រៀនដោយគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនៅខេត្តកណ្ដាល[4]។ អង្គការ VVOB នឹងជួយបង្កលក្ខណៈ

[2] ក្រោមធាតុចេញទី ៣ ធាតុចេញរង គម្រោងនេះនឹងកសាងសមត្ថភាពនាយកសាលា/នាយករងអនុវិទ្យាល័យដើម្បីក្លាយជាអ្នកដឹកនាំការបង្រៀនដែលគាំទ្រការអភិវឌ្ឍគ្រូបង្រៀន។

[3] ក្រោមគម្រោងលើកកម្ពស់គុណភាពអប់រំ (EEQP) បណ្ដាញសាលាមធ្យមសិក្សាធនធាន-មជ្ឈមណ្ឌលមធ្យមសិក្សាធនធានចំនួន ១៨ ត្រូវបានទទួលស្គាល់តាមរយៈការចេញប្រកាសរបស់ក្រសួងអប់រំលេខ ៣២៧៧ ចុះថ្ងៃទី ១៤ ធ្នូ ឆ្នាំ ២០១០។

[4] មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនៅខេត្តកណ្ដាល គឺជាផ្នែកមួយនៃកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនសាកល្បង ក្រោមកម្មវិធី SEAL ដែលគាំទ្រដោយអង្គការ VVOB។ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនេះ បានផ្ដល់កន្លែងស្នាក់នៅដល់ក្រុមការងាររបស់អង្គការ VVOB។

ងាយស្រួលដល់ការបណ្ដុះបណ្ដាលគ្រូឧទ្ទេសថ្នាក់ជាតិ ដោយមានការសម្របសម្រួលជាមួយនឹងនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹត្យការ។ គម្រោងនេះ ក៏នឹងគាំទ្រដល់ការបណ្ដុះបណ្ដាលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រចំនួន ៨០០ រូប (រួមទាំងប្រធានក្រុមបច្ចេកទេសមុខវិជ្ជាវិទ្យាសាស្ត្រ) ដែលមកពី សាលាអនុវិទ្យាល័យទាំង ១០០ ផងដែរ នៅក្នុងសិក្ខាសាលារយៈពេល ៣ ថ្ងៃ ដែលនឹងត្រូវបង្រៀនដោយគ្រូឧទ្ទេសថ្នាក់ជាតិចំនួន ២០ រូប។ ការបណ្ដុះបណ្ដាលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ នឹងធ្វើឡើងនៅក្នុងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រនៃមជ្ឈមណ្ឌលមធ្យមសិក្សាធនធានដែលបានកំណត់ នៅក្នុងខេត្តចំនួន ១៧ ដូចតទៅ៖ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល កោះកុង ក្រចេះ ព្រះវិហារ ព្រៃវែង សៀមរាប ព្រះសីហនុ ស្ទឹងត្រែង និងតាកែវ។

គម្រោងនេះ នឹងធ្វើការផ្ដល់សម្ភារៈបណ្ដុះបណ្ដាលដែលបានអភិវឌ្ឍន៍ដោយអង្គការ VVOB សម្រាប់ការបណ្ដុះបណ្ដាលទាំងពីរលើក។ គម្រោងនេះ ក៏នឹងធ្វើការផ្ដល់សម្ភារៈនៅក្នុងថ្នាក់រៀនរបស់ VVOB សម្រាប់ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រដល់សាលាអនុវិទ្យាល័យទាំង ១០០ នៅក្នុងបណ្ដាញសាលាមធ្យមសិក្សាធនធាន-មជ្ឈមណ្ឌលមធ្យមសិក្សាធនធានផងដែរ។ សម្ភារៈនៅក្នុងបន្ទប់សិក្សារបស់ VVOB គាំទ្រដល់ការសិក្សាតាមបែបសិស្សមជ្ឈមណ្ឌលដែលបំពេញបន្ថែមដល់គោលវិធីសិក្សា និងស្រាវជ្រាវមេរៀននៃគម្រោង STEPSAM របស់ JICA។ សម្ភារៈនៅក្នុងបន្ទប់សិក្សានឹងរួមមាន៖ ក្រដាសផ្ទាំងធំវិទ្យាសាស្ត្រ គំនូរកំប្លែងអំពីគំនិត សៀវភៅគ្រូអំពីគោលវិធីសិស្សមជ្ឈមណ្ឌល សៀវភៅសកម្មភាពជាក់លាក់តាមមុខវិជ្ជា ការធ្វើពិសោធន៍ (សម្ភារៈពិសោធន៍ និងសម្ភារៈដែលមានតម្លៃទាប) និងសម្ភារៈសិក្សាតាមពហុមេឌៀ (ឧ. ការសិក្សាតាមវីដេអូ គំនូរជីវចល និងការធ្វើត្រាប់តាម)។ នាយកសាលា/នាយករងអនុវិទ្យាល័យ ត្រូវត្រួតពិនិត្យកម្រិតដែលគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រអាចអនុវត្តចំណេះដឹង និងជំនាញដែលទទួលបានតាមរយៈកម្មវិធីសាកល្បង Science-INSET នៅក្នុងការបង្រៀននៅក្នុងថ្នាក់របស់ពួកគេ។

### ២.៣.៥ ការផ្ដោតលើសមត្ថភាពធ្វើការងារ និងការប្រើប្រាស់បុគ្គលធនធានអាជីព

*ណែនាំអំពីកម្មវិធីបំណិនសមត្ថភាពធ្វើការងារ៖* ESDP III នឹងគាំទ្រដល់ការបង្កើត និងការអនុវត្តកម្មវិធីបំណិនសមត្ថភាពធ្វើការងារដែលផ្ដោតលើសហគ្រិនភាព។ កម្មវិធីនេះ នឹងផ្ដល់នូវបទពិសោធន៍សិក្សារួមបញ្ចូលគ្នាសម្រាប់យុវជនដែលមានអាយុពី ១២-១៤ ឆ្នាំ ដែល

**<u>ប្រអប់ទី ៤៖</u> ប្រធានបទបំណិនជីវិតដែលអាចរកបានពីក្រសួងអប់រំ យុវជន និងកីឡា**

***<u>វិស័យទី ១ ៖</u> គោលគំនិតដែលទាក់ទងនឹងសង្គម***

១. ការយល់ដឹងអំពីពលរដ្ឋ
*២. ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស*
៣. ការបង្ការការញៀនគ្រឿងស្រវឹង
*៤. ការបង្ការការប្រើប្រាស់គ្រឿងញៀន*
៥. ទឹកស្អាត អនាម័យ និងបង្គន់អនាម័យ
៦. បញ្ហាវប្បធម៌
៧. បញ្ហាបរិស្ថាន
៨. ការយល់ដឹងផ្ទាល់ខ្លួន
*៩. ការយល់ដឹងអំពីយែនឌ័រ*
១០. តន្ត្រី និងរបាំ

***<u>វិស័យទី ២ ៖</u> ការសិក្សាអាជីវកម្ម និងសេដ្ឋកិច្ច***

*១១. ខ្ញុំ និងបំណិនទីផ្សាររបស់ខ្ញុំ*
*១២. ខ្ញុំ និងអនាគតរបស់ខ្ញុំ*
១៣. បំណិនគ្រប់គ្រងប្រាក់
*១៤. ពិភពការងារ*
១៥. សហគ្រាសសង្គម និងកុមារ
១៦. ការសន្សំប្រាក់ និងការចាយវាយ
*១៧. បច្ចេកវិទ្យាព័ត៌មាន*

***<u>វិស័យទី ៣ ៖</u> បំណិនបុរេអាជីព***

*១៨. ការដាំស្រូវ*
*១៩. ការដាំបន្លែ*
*២០. ការចិញ្ចឹមត្រី*
២១. ការចិញ្ចឹមកង្កែប
២២. សួនជីវៈចម្រុះ
២៣. ការបណ្ដុះផ្សិត
*២៤. ការចិញ្ចឹមមាន់*
*២៥. ការជួសជុលកង់ ម៉ូតូ*
*២៦. ការកាត់សក់ និងការអ៊ុតសក់*
២៧. កិច្ចការជាងកំបោរ
*២៨. ការធ្វើម្ហូប*
*២៩. ការកាត់ដេរ*
៣០. ការកែច្នៃម្ហូបអាហារ

*ប្រធានបទជាអក្សរទ្រេតត្រូវបានស្នើក្នុងពេលពិភាក្សារបស់ក្រុមទទួលបន្ទុក (FGD)*

រៀបចំពួកគេសម្រាប់កន្លែងធ្វើការនៅពេលអនាគត។ បទពិសោធន៍សិក្សារួមបញ្ចូលគ្នា នឹងក្លាយជាគោលគំនិតចាក់ស្រេះគ្នា ដែលកំណត់លក្ខណៈគោលគំនិតសិក្សានៅក្នុងសៀវភៅណែនាំបច្ចេកទេសដែលបានប្រើនៅក្នុងកម្មវិធី SBEP។ គោលគំនិតសិក្សាចាក់ស្រេះគ្នាទាំងនេះ រួមមាន ការផ្តោតលើមុខវិជ្ជាបំណិនចំនួនដូចតទៅ៖ (i) បំណិនមូលដ្ឋានដូចជា អំណាន និងនព្វន្ត (ii) បំណិនក្នុងការគិតលំដាប់ខ្ពស់ដូចជា ការដោះស្រាយបញ្ហា និងការសម្រេចចិត្ត និង (iii) បំណិនក្នុងការសម្តែងអារម្មណ៍ និងលក្ខណៈនិស្ស័យដូចជា ភាពអាចទុកចិត្តបាន ដែលជាឥរិយាបថវិជ្ជមាន និងភាពរួបរួមគ្នា។ កម្មវិធីបំណិនសមត្ថភាពធ្វើការងារ នឹងត្រូវបង្កើតឡើងដោយមានការផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់អំណាចដល់ក្មេងស្រី។

បទបញ្ញត្តិនៅក្នុងកម្មវិធី SBEP ទាំងនេះ មានលក្ខណៈស្របគ្នាជាមួយនឹងសំណើពីអ្នកពាក់ព័ន្ធ នៅក្នុងអំឡុងនៃការពិភាក្សារបស់ក្រុមទទួលបន្ទុកប្រធានបទអប់រំវិជ្ជាជីវៈ និងបំណិនជីវិតជាច្រើន។ គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលារៀន បានកត់សម្គាល់ថា ទោះបីជាពួកគេចង់បង្រៀនកម្មវិធីបំណិនជីវិតដល់សិស្សក៏ដោយ ក៏ពួកគេគ្មានកម្មវិធី ជំនាញឯកទេស ឬឯកសារដែលចាំបាច់សម្រាប់បង្រៀនដែរ។ ជារួម អ្នកពាក់ព័ន្ធបានស្នើសុំការគាំទ្រនូវប្រធានបទអប់រំវិជ្ជាជីវៈ/បំណិនជីវិតចំនួន ១៥ ដែលក៏ជាផ្នែកមួយនៃម៉ឺនុយបំណិនជីវិតថ្មីរបស់ក្រសួងអប់រំផងដែរ ដែលបានអភិវឌ្ឍន៍ដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា (DCD) ក្នុងកិច្ចសហការជាមួយ *គម្រោងពង្រឹងគុណភាពអប់រំ* (EEQP) និងគម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC)។ មកទល់នឹងពេលបច្ចុប្បន្ននេះ នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា បានអភិវឌ្ឍន៍សៀវភៅបំណិនជីវិតចំនួន ៣០ ប្រធានបទ ដោយប្រើគម្រោងដែលត្រូវបានធ្វើបមាណីកម្ម ដែលគ្របដណ្តប់លើបញ្ហានានាលើវិស័យប្រធានបទចំនួនបីគឺ៖ (i) គោលគំនិតដែលទាក់ទងនឹងសង្គម (ឧ. ការបង្ការការប្រើប្រាស់គ្រឿងញៀន ការធ្វើចំណាកស្រុក) (ii) ការសិក្សាអាជីវកម្ម និងសេដ្ឋកិច្ច (ឧ. ពិភពនៃកន្លែងការងារ-អាជីព) និង (iii) បំណិនបុរេអាជីព (ឧ. កាត់ដេរ ដាំបន្លែ ។ល។) (សូមមើលប្រអប់ទី ៤)។ ក្នុងចំណោមភាពសំខាន់ជាពិសេសក្នុងន័យបង្កើតកម្មវិធីសមត្ថភាពការងាររបស់កម្មវិធី SBEP គឺវិស័យទី ២ ដែលផ្តោតលើបំណិនសហគ្រិន។ គោលវិធីដែលប្រើនៅនៅក្នុងសៀវភៅទាំងនេះ ប្រសព្វគ្នាជាមួយនឹងគោលវិធីសិក្សាដែលបានដាក់បញ្ចូលទៅក្នុងកម្មវិធី SBEP ហើយនឹងផ្តល់នូវគំរូល្អសម្រាប់សៀវភៅបន្ថែមដែលផលិតក្រោមកម្មវិធី SBEP។ បច្ចុប្បន្ននេះ សៀវភៅទាំងនេះកំពុងត្រូវបានពិនិត្យឡើងវិញដោយ *ក្រុមប្រឹក្សាអនុម័តសម្ភារអប់រំ* របស់ក្រសួងអប់រំ ហើយត្រូវបានរំពឹងថា នឹងអាចប្រើប្រាស់បានជាទូទៅនៅតាមសាលារៀន ត្រឹមដើមឆ្នាំ ២០១៣ ជាកម្មវិធីសិក្សាដែលបានអនុម័តជាផ្លូវការ។

សៀវភៅរបស់កម្មវិធី SBEP ដែលប្រើសម្រាប់លើកកម្ពស់បំណិនសមត្ថភាពធ្វើការងារ នឹងដាក់បញ្ចូលនូវបំណិនមួយចំនួនដែលបានអភិវឌ្ឍន៍ដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ក៏ដូចជាបំណិនថ្មីៗផងដែរ។ គម្រោងនេះ នឹងប្រើការអនុវត្តល្អដែលបានជួបប្រទះនៅក្នុងគម្រោងដែលមានអត្ថិភាពពីមុន ហើយនឹងប្រើគំរូដែលបានធ្វើបមាណីយកម្មសម្រាប់សៀវភៅដែលមាន (i) ផែនការបង្រៀនច្បាស់លាស់សម្រាប់គ្រូបង្រៀន (ii) ឯកសារចែកឲ្យសិស្ស និង (iii) ស្លាយសម្រាប់សិស្សសិក្សាដែលអ៊ុតជាសន្លឹកស្តើងៗ ដើម្បីអាចយកមកប្រើប្រាស់ឡើងវិញពីមួយឆ្នាំទៅមួយឆ្នាំ។ សៀវភៅនេះ ក៏នឹងដាក់បញ្ចូលនូវក្របខ័ណ្ឌវាយតម្លៃសិស្សច្បាស់លាស់ ដើម្បីជួយត្រួតពិនិត្យ និងចងក្រងឯកសារអំពីការសិក្សារបស់សិស្សផងដែរ។ មានសនិទានភាពដ៏សំខាន់មួយសម្រាប់ការរៀបចំរចនាសម្ព័ន្ធសៀវភៅបំណិនជីវិតតាមរបៀបនេះ ដែលពាក់ព័ន្ធជា

ចម្លងទៅនឹងតម្រូវការក្របខ័ណ្ឌអនុវត្តទូលំទូលាយ ដែលបច្ចុប្បន្ននេះនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សាបាន ដាក់ឲ្យនៅនឹងកន្លែង។ ការអនុវត្តល្អមួយចំនួនដែលនឹងត្រូវអនុម័តយកដោយកម្មវិធី SBEP ត្រូវបានសង្ខេប នៅក្នុងតារាង ២.២ ខាងក្រោម៖

**តារាង ២.២៖ ការអនុវត្តល្អក្នុងការអនុវត្តបំណិនជីវិតដែលនឹងត្រូវអនុម័ត ក្រោមកម្មវិធីបំណិនសមត្ថភាពធ្វើការងារ របស់កម្មវិធី SBEP**

| លរ | បញ្ហាដែលបានសង្កេតឃើញ | ការឆ្លើយតប/ការអនុវត្តល្អរបស់ក្រសួងអប់រំ |
|---|---|---|
| ១ | កង្វះឯកសារបំណិនជីវិតទូលំទូលាយនៅក្នុងផ្នែកបំណិនដែលត្រូវការ | ○ ការអភិវឌ្ឍកម្មវិធីសិក្សាបំណិនជីវិតរបស់គម្រោង EEQP<br>○ ការអភិវឌ្ឍសៀវភៅបំណិនជីវិតចំនួន ៣០ ប្រធានបទ<br>○ ការណែនាំអំពីគំរូសៀវភៅដែលបានធ្វើបមាណីយកម្ម |
| ២ | គ្រូបង្រៀនមិនដឹងពីរបៀបបង្រៀនប្រធានបទទាំងនោះ | ○ សៀវភៅបង្កើតបានជាផែនការបង្រៀនរបស់គ្រូបង្រៀន |
| ៣ | សៀវភៅមានតម្លៃខ្ពស់ | ○ ស្លាយសិក្សាដែលបានអ៊ុតជាសន្លឹកស្តើងៗ/ឯកសារចែកឲ្យសិស្ស (ដាក់បញ្ចូលនៅក្នុងសៀវភៅគ្រូ) |
| ៤ | កង្វះគោលការណ៍ណែនាំច្បាស់លាស់អំពី **របៀប**អនុវត្តការអប់រំបំណិនជីវិតនៅថ្នាក់សាលារៀន (ឧ. កាលវិភាគ តួនាទីរបស់ក្រុមប្រឹក្សាសិស្ស ។ល។) | ○ ក្របខ័ណ្ឌអនុវត្តដែលគូសបញ្ជាក់អំពីជំហានសំខាន់ៗនៅក្នុងការអនុវត្ត និងវិធីសាស្ត្របង្រៀនរបស់គ្រូដែលចង់បាន |
| ៥ | កង្វះគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃសិស្ស | ○ ការអភិវឌ្ឍក្របខ័ណ្ឌវាយតម្លៃសិស្ស**ច្បាស់លាស់**សម្រាប់សៀវភៅបំណិនជីវិតនីមួយៗ |
| ៦ | គ្មានការទូទាត់ប្រាក់បន្ថែមម៉ោងសម្រាប់ការបង្រៀនបំណិនជីវិត | ○ ការកែសម្រួលរបស់ក្រសួងអប់រំទៅលើគោលការណ៍ណែនាំកម្មវិធីសិក្សា ដែលទទួលស្គាល់បំណិនជីវិតថាជាមុខវិជ្ជាផ្លូវការមួយ ហើយមានសិទ្ធិទទួលបានប្រាក់បង្រៀនបន្ថែមម៉ោង |

កម្មវិធីសមត្ថភាពធ្វើការងារ នឹងត្រូវបានកំណត់លក្ខណៈដោយលក្ខណៈពិសេសមួយចំនួនដែលមានតែមួយ ដែលនឹងធានាបាននូវ គុណភាពនៃការផ្តល់ខ្លឹមសារបំណិនសមត្ថភាពធ្វើការងារ (សូមមើលប្រអប់ទី ៥)។ កម្មវិធីនេះ រួមមាន ក្របខ័ណ្ឌអនុវត្តច្បាស់លាស់ ដែលដាក់ចេញនូវជំហាន និងគោលវិធីទាំងឡាយក្នុងការធ្វើផែនការកម្មវិធីបំណិនទាំងឡាយ ដែលត្រូវផ្តល់ទៅឲ្យសិស្សនៅថ្នាក់សាលារៀន។ ក្នុងន័យនេះ ក្របខ័ណ្ឌអនុវត្ត នឹងត្រូវកំណត់លក្ខណៈដោយដំណើរការដែលមានប្រាំជំហាន ដែលចាប់ផ្តើមជាមួយនឹងការកំណត់ប្រធានបទសមត្ថភាពធ្វើការងារ ដែលសហគមន៍-សាលារៀនចង់បាន ដោយផ្អែកលើលទ្ធភាព

**<u>ប្រអប់ទី ៥</u> ៖ សមាសភាពសំខាន់ៗនៃការបង្កើតកម្មវិធីសមត្ថភាពធ្វើការងារ**

- ○ គោលវិធីសិក្សារួមគ្នា
- ○ ក្របខ័ណ្ឌអនុវត្តច្បាស់លាស់
- ○ ប្រើគំរូសៀវភៅដែលបានធ្វើបមាណីយកម្ម ដែលដាក់បញ្ចូលនូវផែនការបង្រៀនរបស់គ្រូបង្រៀន ឯកសារចែកឲ្យសិស្ស និងស្លាយសម្រាប់សិក្សា
- ○ វដ្តនៃការបង្រៀន ១០ សប្តាហ៍ចំនួនពីរ (មួយវដ្តសម្រាប់មួយឆមាស)
- ○ ជម្រើសរបស់សាលារៀនលើប្រធានបទដែលត្រូវបង្រៀន
- ○ ជម្រើសរបស់សិស្សលើប្រធានបទដែលមាន ដែលបានជ្រើសរើសដោយសាលារៀន
- ○ ការប្រើប្រាស់បច្ចេកទេសបណ្តុះបណ្តាលដែលមានលក្ខណៈបត់បែន និងបច្ចេកវិទ្យា ICT នៅពេលបណ្តុះបណ្តាលគ្រូបង្រៀន
- ○ ក្របខ័ណ្ឌវាយតម្លៃសិស្សច្បាស់លាស់

ប្រើប្រាស់គ្រូបង្រៀន និងអ្នកជំនាញឯកទេសក្នុងស្រុក ដើម្បីបង្រៀនប្រធាន ទាំងនេះ (សូមមើលរូបភាពទី ២.៧)។ ការសម្រាំងប្រធានបទដោយគណកម្មការទ្រទ្រង់សាលា នឹងត្រូវបានសម្របសម្រួលដោយការប្រើប្រាស់ម៉ឺនុយបំណិនជីវិតរបស់ក្រសួងអប់រំ ដែលអាចត្រូវបានកែប្រែសម្រាប់ប្រើប្រាស់ដោយកម្មវិធី SBEP ដើម្បីផ្ដោតលើសមត្ថភាពធ្វើការងារ។ គំរូនៃម៉ឺនុយបំណិនជីវិតមានចែងនៅក្នុងឧបសម្ព័ន្ធទី ៥។ ទោះជាស្ថិតក្រោមការកែប្រែក៏ដោយ ម៉ឺនុយនេះផ្ដល់នូវចំណុចចាប់ផ្ដើមដ៏មានសារៈប្រយោជន៍ សម្រាប់ធានានូវជម្រើសប្រធានបទ ដែលអាចមានលទ្ធភាពប្រើប្រាស់បានចំពោះសាលារៀន និងសហគមន៍គោលដៅផងដែរ។

**រូបភាព ២.៧ ៖ ដំណើរការចង្អុលបង្ហាញសម្រាប់ការអនុវត្តកម្មវិធីបំណិនសមត្ថភាពធ្វើការងារ**




គ្រូបង្រៀននឹងត្រូវបានបណ្ដុះបណ្ដាលដោយអ្នកសម្របសម្រួលថ្នាក់ខេត្ត និងក្រុមបណ្ដុះបណ្ដាល និងត្រួតពិនិត្យថ្នាក់ស្រុក ក្នុងការប្រើប្រាស់សៀវភៅផ្លូវការ ដែលសៀវភៅនីមួយៗ មានផែនការបង្រៀនច្បាស់លាស់ ចំនួនដប់។ ផែនការបង្រៀននីមួយៗ ត្រូវមាន មេរៀនប្រចាំសប្ដាហ៍ពីរម៉ោង ដែលជាលទ្ធផលគឺមានការបង្រៀនសិស្សយ៉ាងហោចណាស់ ២០ ម៉ោង ក្នុងមួយឆមាស (ពោលគឺ រយៈពេលដប់សប្ដាហ៍)។ វដ្ដពីរ (មួយវដ្ដសម្រាប់មួយឆមាស) នៃការបង្រៀនបំណិន (ដែលអាស្រ័យលើលទ្ធភាពប្រើប្រាស់គ្រូបង្រៀន) នឹងនាំទៅរកការបង្រៀនរយៈពេល ៤០ ម៉ោង ក្នុងមួយឆ្នាំសិក្សា។ វិធីសាស្ត្រដែលប្រើនៅក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀន អំពីការបង្រៀនបំណិនទាំងនេះ ត្រូវប្រើបច្ចេកទេសបណ្ដុះបណ្ដាលដែលមានលក្ខណៈបត់បែន ដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើការប្រើប្រាស់បច្ចេកវិទ្យា ICT ដូចជា កុំព្យូទ័រយួរដៃ និងបទបង្ហាញមីក្រូបង្រៀន (micro-teaching presentations)។ សិស្សក៏នឹងមានជម្រើសក្នុងចំណោមប្រធានបទទាំងឡាយ ដែលសាលាបានជ្រើសរើសយកមកផ្ដល់ឲ្យផងដែរ។ ឧទាហរណ៍ ប្រសិនបើសាលារៀនជ្រើស

រើសយកប្រធានបទចំនួនបីមកបង្រៀន សិស្សនឹងមានជម្រើសក្នុងការជ្រើសយកប្រធានបទមួយ។ ក្នុងអំឡុងវដ្តទីពីរនៃការបង្រៀន ពួកគេអាចជ្រើសរើសប្រធានបទមួយទៀត។ គោលវិធីនេះ នឹងជួយផ្តល់អំណាចដល់សិស្ស បង្កើនចំនួនប្រធានបទដែលសិស្សអាចសិក្សាបានក្នុងមួយឆ្នាំសិក្សា ហើយពង្រីកភាពជាកម្មសិទ្ធិរបស់កម្មវិធី។ ជំហានចុងក្រោយនៅក្នុងកម្មវិធី ត្រូវមានការវាយតម្លៃសិស្សមួយ ដោយប្រើទម្រង់ និងកិច្ចការដែលបានធ្វើបមាណីយកម្ម។

*ការកសាងសមត្ថភាពសម្រាប់បុគ្គលធនធានអាជីព៖* សមាសភាពដែលបានស្នើមួយទៀតនៃកម្មវិធីសមត្ថភាពធ្វើការងារ សំដៅទៅលើការរៀបចំបុគ្គលធនធានអាជីព (CRPs) នៅក្នុងសាលារៀន ដែលជាអ្នកត្រូវជួយធ្វើឲ្យ *សេវាផ្តល់ដំបូន្មានអាជីព* មានភាពរស់រវើក។ ក្នុងអំឡុងការពិភាក្សាក្រុមទទួលបន្ទុកសិស្ស សិស្សភាគច្រើនបានចង្អុលបង្ហាញថា ពួកគេកម្របានទទួលដំបូន្មានណាមួយអំពីអនាគត ឬទិសដៅមុខរបរនៅក្នុងជីវិតរបស់ពួកគេណាស់។ ភាគច្រើន ពួកគេហាក់ដូចជាពឹងផ្អែកទៅលើការស្តាប់មិត្តភក្តិរបស់ខ្លួន (ឬជួនកាលឪពុកម្តាយ និងបងប្អូនបង្កើតរបស់ពួកគេ) ជាពិសេសអ្នកដែលបានបោះបង់ការសិក្សា ហើយមានការងារដែលមានប្រាក់ចំណូល។ ដំបូន្មាននេះ មានបំណងផ្តោតលើការគិតអំពីហិរញ្ញវត្ថុរយៈពេលខ្លី ដែលមានការគិតតិចតួចទៅលើការបោះបង់ចោលសាលារយៈពេលវែង។ ដូច្នេះហើយទើប តម្រូវការសេវាផ្តល់ដំបូន្មានអាជីព ឬយ៉ាងហោចណាស់សេវាដែលផ្តល់នូវការណែនាំខ្លះៗសម្រាប់ការធ្វើផែនការអនាគត ត្រូវបានរាយការណ៍ថា មានអត្រាសិស្សបោះបង់ចោលការសិក្សាស្រួចស្រាវនៅក្នុងសាលារៀនគោលដៅ។

ដូចក្នុងករណីបំណិនជីវិត កិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពនៅក្នុងមុខវិជ្ជានេះ អាចធ្វើឲ្យមានសមត្ថភាពកាន់តែច្រើនថែមទៀត តាមរយៈការពិនិត្យឡើងវិញនូវការងារដែលបានដំណើរការដោយក្រសួងរួចមកហើយ។ ក្នុងន័យនេះ ការងារជាច្រើនត្រូវបានធ្វើដោយនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ (VOD) នៅក្នុងការណែនាំអំពីអាជីព។ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ បាននិងកំពុងធ្វើការទៅលើបញ្ជីសេវាអាជីពដែលត្រូវប្រើនៅតាមសាលារៀន។ នាយកដ្ឋាននេះ ក៏បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងគម្រោង IBEC ដើម្បីសាកល្បងអនុវត្តសៀវភៅបណ្តុះបណ្តាលមួយ ដែលបង្កើតនូវសេវាផ្តល់ដំបូន្មានអាជីព ដែលដំណើរការដោយបុគ្គលធនធានអាជីព ដោយមានកិច្ចសហការជាមួយនឹងក្រុមប្រឹក្សាយុវជន/សិស្ស។ សៀវភៅណែនាំនេះ ត្រូវបានធ្វើពិសោធន៍នៅតាមមូលដ្ឋានដោយនាយកដ្ឋាននេះ ដោយមានកិច្ចសហការជាមួយនឹងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងអង្គការអប់រំពិភពលោក (World Education) នៅឆ្នាំ ២០១១-២០១២ ហើយបច្ចុប្បន្ននេះកំពុងត្រូវបានកែសម្រួលឡើងវិញ។ សៀវភៅណែនាំនេះ ត្រូវបានប្រើព្រមគ្នាជាមួយនឹងសៀវភៅបំណិនជីវិតមួយទៀត ដែលត្រូវបានអភិវឌ្ឍន៍ដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ហៅថា *"ពិភពការងារ"* ដែលផ្តល់ឲ្យសិស្សានុសិស្សនូវវចនាសម្ព័ន្ធសិក្សាអំពីមុខរបរដែលអាចជ្រើសរើសបាន (សូមមើលប្រធានបទលេខ ១៤ នៅក្នុងម៉ឺនុយបំណិនជីវិតនៃឧបសម្ព័ន្ធទី ៥)។ ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាពសំខាន់ៗជាច្រើននៃសេវាផ្តល់ដំបូន្មានអាជីពគឺថា វាប្រើប្រាស់នូវសហគ្រិនក្នុងមូលដ្ឋានជាប្រភពព័ត៌មានអំពីសហគ្រិនភាពក្នុងមូលដ្ឋាន ដែលជាទិដ្ឋភាពដ៏សំខាន់មួយនៃកម្មវិធីបំណិនសមត្ថភាពធ្វើការងាររបស់កម្មវិធី SBEP។ សៀវភៅណែនាំដែលបានស្នើ ដែលអាចសម្របទៅតាមតម្រូវការរបស់កម្មវិធី SBEP ផ្តល់នូវវចនាសម្ព័ន្ធដ៏មានសារៈប្រយោជន៍ សម្រាប់ឲ្យសិស្សធ្វើការស្រាវជ្រាវមុខរបរក្នុងមូលដ្ឋាននៅក្នុងសហគមន៍របស់ខ្លួន និងសម្ភាសន៍សហគ្រិនក្នុងមូលដ្ឋានអំពីរបៀបធ្វើការងារទាំងនោះ។ ផ្នែកកសាង

សមត្ថភាពដែលមានគូសបញ្ជាក់នៅក្នុងសៀវភៅណែនាំបុគ្គលធនធានអាជីព ត្រូវបានសង្ខេបនៅក្នុងតារាង ២.៣ ដូចខាងក្រោម។

**តារាង ២.៣៖ មេរៀនកសាងសមត្ថភាពដែលបានស្នើសម្រាប់បុគ្គលធនធានអាជីព**

| ចំណងជើងមេរៀន | រយៈពេល | សង្ខេប |
|---|---|---|
| ១. សេចក្តីផ្តើមស្តីពីសេវាផ្តល់ដំបូន្មានអាជីព និងឱកាសការងារ | ១០០ នាទី | យល់ដឹងថាតើសេវាផ្តល់ដំបូន្មានអាជីពជាអ្វី? គិតអំពីអាជីពទាំងឡាយដែលមាននៅកម្ពុជា។ |
| ២. ការងារនៅក្នុងមូលដ្ឋាន៖ ការជួយសិស្សក្នុងការស្រាវជ្រាវឱកាសការងារនៅក្នុងសហគមន៍របស់ពួកគេ | ៦៥ នាទី | ដឹងពីរបៀបបង្កើតផែនទីការងារដែលមាននៅក្នុងតំបន់មូលដ្ឋាន ជាពិសេសសហគ្រិនក្នុងមូលដ្ឋាន។ |
| ៣. បទសម្ភាសន៍ករណីសិក្សា៖ ការជួយសិស្សក្នុងការសម្ភាសន៍សហគ្រិនក្នុងមូលដ្ឋាន | ៩០ នាទី | ដឹងពីរបៀបរៀបចំករណីសិក្សាអំពីការងាររបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ |
| ៤. ការងារគោលដៅ៖ ការតាមដានចំណាប់អារម្មណ៍របស់សិស្សចំពោះការងារ | ៧០ នាទី | ដឹងពីរបៀបរក្សាកំណត់ត្រាអំពីការងារដែលបានកំណត់គោលដៅដោយសិស្សក្នុងអំឡុងពេលស្រាវជ្រាវរបស់ពួកគេ |
| ៥. កម្រងសំណួរវាយតម្លៃអាជីព | ៧០ នាទី | អាចប្រើកម្រងសំណួរក្នុងការវាយតម្លៃថាតើ សិស្សណាខ្លះត្រូវការបទសម្ភាសន៍មួយទល់មួយ |
| ៦. របៀបអនុវត្តបទសម្ភាសន៍មួយទល់មួយ៖ ការផ្តល់ប្រឹក្សាជាបុគ្គល | ៩០ នាទី | ហ្វឹកហាត់ផ្តល់បទសម្ភាសន៍មួយទល់មួយដល់សិស្ស |
| ៧. ការធ្វើផែនការសម្រាប់ការអនុវត្ត | ៨៥ នាទី | ធ្វើផែនការអំពីរបៀបអនុវត្តការបណ្តុះបណ្តាលនៅក្នុងសាលារៀនរបស់ពួកគេ |

បច្ចុប្បន្ននេះ នាយកដ្ឋានកំពុងពិចារណាអំពីជម្រើសរបស់ខ្លួនក្នុងការផ្តុំបញ្ចូលគ្នារវាងសេវាណែនាំអាជីព ជាមួយនឹងសៀវភៅបណ្តុះបណ្តាលបុគ្គលធនធានអាជីពឲ្យទៅជាសៀវភៅតែមួយ ដើម្បីជួយបង្កលក្ខណៈងាយស្រួលដល់សាលារៀនក្នុងការផ្តល់សេវាប្រឹក្សាអាជីព តាមការស្នើសុំរបស់ភាគីពាក់ព័ន្ធ នៅក្នុងអំឡុងពេលសម្ភាសន៍ប្រមូលទិន្នន័យ ដើម្បីជូនដំណឹងដល់ការបង្កើតកម្មវិធីឲ្យបានកាន់តែល្អប្រសើរឡើង។ ជាជំហានដំបូង នាយកដ្ឋានធ្វើការជាមួយនឹងអង្គការយូណេស្កូ ដើម្បីអភិវឌ្ឍន៍ *គោលការណ៍ណែនាំប្រតិបត្តិការ* ដែលនឹងផ្តល់នូវក្របខ័ណ្ឌគោលនយោបាយមួយសម្រាប់អន្តរាគមន៍របស់បុគ្គលធនធានអាជីព។ *សំណួរដ៏សំខាន់មួយដែលនឹងត្រូវឆ្លើយដោយនាយកដ្ឋានគឺ តើអាចបន្តទៅមុខជាមួយនឹងគម្រោងសាកល្បងមួយផ្សេងទៀត ក្រោមគម្រោង SBEP នៅក្នុងសមត្ថភាពធ្វើការងារ មុននឹងគោលការណ៍ណែនាំត្រូវបានបញ្ចប់ និងអនុម័តដោយក្រសួងអប់រំដែរឬទេ?* ក្នុងន័យនេះ នាយកដ្ឋានកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអង្គការយូណេស្កូ អង្គការអប់រំពិភពលោក និងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) ហើយកំពុងទទួលជំនួយបច្ចេកទេសដែលបានសម្របសម្រួលពីភ្នាក់ងារចំនួនបី ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍគោលការណ៍ណែនាំថ្មី។ ក្រសួងបានចង្អុលបង្ហាញជាលក្ខណៈស្វាបស្ទង់ថា វាអាចទៅរួចសម្រាប់កម្មវិធី SBEP ក្នុងការបន្តទៅមុខជាមួយនឹងសកម្មភាពរបស់ក្រុមប្រឹក្សាណែនាំ អំពីប្រភេទដែលបានស្នើ ទោះបីជាមុនពេលដែលគោលការណ៍ណែនាំដែលនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈកំពុងតែធ្វើការលើ ត្រូវបានបញ្ចប់ហើយក៏ដោយ។ ការសាកល្បងនៅក្នុងសាលារៀនរបស់កម្មវិធី SBEP នេះ មិនចាំបាច់ត្រូវអនុវត្តនៅក្នុង

សាលារៀនទាំងអស់ទេ ដោយសារតែមានអត្ថិភាពនៃកង្វះគ្រូបង្រៀនធ្ងន់ធ្ងរនៅតាមសាលារៀនមួយចំនួន។ ជាងនេះទៅទៀត ការសាកល្បងអនុវត្តនៅក្នុងសាលារៀនចំនួន ៣០ ទៅ ៤០ អាចត្រូវបានផ្ដល់អនុសាសន៍ឲ្យអនុវត្តច្រើនជាង។

សមាសភាពមួយក្នុងចំណោមសមាសភាពដែលគួរឲ្យទាក់ទាញជាច្រើន នៃសៀវភៅបណ្ដុះបណ្ដាលបុគ្គលធនធានអាជីព ដែលនឹងត្រូវបានដាក់បញ្ចូលទៅក្នុងគោលវិធីរបស់កម្មវិធី SBEP ផងដែរនោះគឺថា វាប្រើប្រាស់ក្រុមប្រឹក្សាសិស្ស ដែលបានកំណត់អាណត្តិក្រោមគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ ដើម្បីជួយដល់គ្រូបង្រៀនទាំងឡាយដែលបានកំណត់ជ្រើសរើស ក្នុងការដំណើរការសេវាផ្ដល់ប្រឹក្សាអាជីពនៅក្នុងសាលារៀន (សូមមើលប្រអប់ទី ៦)។ សមាជិករបស់ក្រុមប្រឹក្សាអាចបង្កើតបណ្ដាញមួយ ដែលកំណត់អត្តសញ្ញាណសិស្សទាំងឡាយណាដែលបានបោះបង់ចោលការសិក្សា ឬកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់នៃការបោះបង់ចោលការសិក្សា ដើម្បីឲ្យពួកគេអាចបញ្ជូនទៅកាន់អ្នកផ្ដល់ដំបូន្មានម្នាក់ដើម្បីផ្ដល់ប្រឹក្សា។ រចនាសម្ព័ន្ធនេះ ផ្ដល់នូវគោលបំណងបន្ថែមទៅលើក្រុមប្រឹក្សា និងមធ្យោបាយដែលគ្រូបង្រៀនក៏មានជំនួយខ្លះនៅក្នុងការធ្វើឲ្យប្រព័ន្ធនេះរស់រវើកផងដែរ។

## ២.៤ ការត្រៀមជាបឋមមុនពេលអនុវត្ត

### ២.៤.១ ការពិនិត្យលក្ខខណ្ឌនានាឡើងវិញនៅតាមសាលារៀនដើម្បីកំណត់សមិទ្ធិលទ្ធភាព

ការផ្ដល់ធនធានហិរញ្ញវត្ថុ និងបច្ចេកទេសដល់សាលារៀន គឺទំនងជាមិនអាចទទួលបានជោគជ័យទេ ប្រសិនបើមិនមានបុព្វលក្ខខណ្ឌសម្រាប់ការបង្កើតមួយចំនួននៅក្នុងដៃដើម្បីធានាថាធនធានទាំងនេះអាចប្រើប្រាស់បានដោយប្រសិទ្ធភាពទេនោះ។ ក្នុងន័យនេះ លទ្ធភាពប្រើប្រាស់ធនធានមនុស្សមានសារៈសំខាន់ជាពិសេស ទាំងបរិមាណ និងគុណភាព។ ឧទាហរណ៍ លំហាត់ប្រមូលទិន្នន័យ ដែលបានធ្វើជាផ្នែកមួយនៃដំណើរការរៀបចំសម្រាប់កម្មវិធី SBEP បានបញ្ជាក់ថា ៩០% នៃគំរូសាលារៀនដែលបានចុះទស្សនកិច្ច មានការខ្វះខាតគ្រូបង្រៀនយ៉ាងខ្លាំង ដែលតម្រូវឲ្យនាយកសាលាត្រូវបង្រៀនផង គ្រប់គ្រងសាលាផង។ លក្ខខណ្ឌទាំងនេះ ទំនងជាធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព ដែលត្រូវបានបង្កើតឡើង ដើម្បីកែលម្អគុណភាពអប់រំនៅក្នុងសាលារៀនគោលដៅទាំងនោះ។

ដើម្បីកាត់បន្ថយកត្តាទាំងនេះ ការស្ទង់មតិបឋមអំពីសាលារៀនគោលដៅ គួរកើតឡើងមុនពេលអនុវត្តកម្មវិធី SBEP ដើម្បីទទួលបាននូវរូបភាពកាន់តែច្បាស់លាស់អំពីបរិបទស្ថានភាពនៃសាលារៀននីមួយៗ។ ការស្ទង់មតិនេះ នឹងអនុវត្តដោយអ្នកសម្របសម្រួលថ្នាក់ខេត្ត ដោយសហការជាមួយក្រុមបណ្ដុះបណ្ដាល និងគ្រូតពិនិត្យថ្នាក់ស្រុក។ ការស្ទង់មតិនេះ នឹងបំពេញបន្ថែមឲ្យដំណើរការធ្វើចំណាត់ថ្នាក់ដែលមានរៀបរាប់នៅក្នុងផ្នែក ២.៣.៣ ដែលនឹងកំណត់ថាតើសាលារៀននោះ នឹងត្រូវបានចាត់ទុកថា "ជួបការលំបាក" ឬ "ធម្មតា"។ ចំណាត់ថ្នាក់នេះ នឹងមានការជាប់ទាក់ទិនសម្រាប់សកម្មភាពមួយចំនួន ដែលសាលារៀននោះត្រូវបានអនុញ្ញាតឲ្យអនុវត្ត ដោយប្រើថវិកាជំនួយសាលារៀនរបស់ខ្លួន ព្រមទាំងការកែប្រែដែលអាចធ្វើបានចំពោះការចូលរួមនៅក្នុងអន្តរាគមន៍ធ្វើឲ្យប្រសើរឡើង ដូចជា សមត្ថភាពធ្វើការងារជាដើម។ ការស្ទង់មតិនេះ នឹងផ្ដោតទៅ

លើវង្វាយតម្លៃកត្តាស្ថានភាពគន្លឹះចំនួនប្រាំបីនៅក្នុងបរិបទសាលារៀន។ ការជាប់ទាក់ទិននៃកត្តាទាំងនេះទៅលើការអនុវត្ត និងកម្រិតនៃកត្តាទាំងនេះដែលស្ថិតក្នុងន័យភាពធ្ងន់ធ្ងរ មានចែងនៅក្នុងតារាង ២.៤ ខាងក្រោម៖

**តារាង ២.៤ ៖ កត្តាស្ថានភាពសម្រាប់ប្រមើលមើល ដែលអាចសម្រុះសម្រួលការអនុវត្តគម្រោង**

| កត្តាស្ថានភាព | កម្រិត | ការជាប់ទាក់ទិនសម្រាប់ការអនុវត្ត |
|---|---|---|
| ១. លទ្ធភាពប្រើប្រាស់គ្រូបង្រៀន | ខ្លាំង | ○ កម្សោយលទ្ធភាពប្រើប្រាស់គ្រូបង្រៀន នឹងធ្វើឲ្យអន្តរាយដល់សមត្ថភាពរបស់សាលារៀន ក្នុងការបង្រៀនបំណិនសមត្ថភាពធ្វើការ បណ្តាញប្រឹក្សាអាជីពសម្រាប់ការរស់នៅ ។ល។<br>○ កម្សោយលទ្ធភាពប្រើប្រាស់គ្រូបង្រៀន តម្រូវឲ្យនាយកសាលាត្រូវបង្រៀន ដែលធ្វើឲ្យលទ្ធភាពប្រើប្រាស់សម្រាប់ការគ្រប់គ្រងជំនួយរបស់គាត់នៅមានកម្រិត |
| ២. វត្តមានគ្រូបង្រៀន | ខ្លាំង | ○ អវត្តមាននិយមខ្ពស់របស់គ្រូបង្រៀន នឹងធ្វើឲ្យអន់ថយដល់ឥទ្ធិពលរបស់ធាតុចូលសម្រាប់ការបង្រៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្រ្ត<br>○ អវត្តមាននិយមខ្ពស់របស់គ្រូបង្រៀន នឹងធ្វើឲ្យអន្តរាយដល់អន្តរាគមន៍ដទៃទៀត ដែលបានបង្កើតឡើងដើម្បីបង្ការការបោះបង់ចោលការសិក្សា |
| ៣. សមត្ថភាពគ្រប់គ្រងរបស់នាយកសាលា | ខ្លាំង | ○ សមត្ថភាពក្នុងការគ្រប់គ្រងទាប ធ្វើឲ្យមានកំណើនហានិភ័យនៃការប្រើប្រាស់ថវិកាជំនួយដោយមិនត្រឹមត្រូវ និងធ្វើឲ្យការជឿទុកចិត្ត/ការចូលរួមពីសំណាក់សហគមន៍ មានការធ្លាក់ចុះ<br>○ សមត្ថភាពក្នុងការគ្រប់គ្រងទាប ធ្វើឲ្យមានកំណើនហានិភ័យដែលអន្តរាគមន៍ផ្សេងៗជាច្រើន នឹងមិនត្រូវបានអនុវត្តដោយប្រសិទ្ធភាព |
| ៤. សមត្ថភាពប្រតិបត្តិការរបស់ក្រុមប្រឹក្សាសិស្ស | ធ្ងន់ធ្ងរមធ្យម | ○ ដោយសារក្រុមប្រឹក្សាសិស្ស ត្រូវបានរំពឹងថាមានការចូលរួមដើម្បីធ្វើឲ្យសកម្មភាពជាច្រើនមានភាពរស់រវើក (ឧ. បណ្តាញប្រឹក្សាអាជីព បំណិនជីវិត។ល។ អវត្តមាននៃតួអង្គទាំងនេះនឹងធ្វើឲ្យអន្តរាយដល់សមិទ្ធិលទ្ធភាព នៃការអនុវត្តអន្តរាគមន៍ជាច្រើនប្រកបដោយជោគជ័យ |
| ៥. លទ្ធភាពប្រើប្រាស់ថ្នាក់រៀន | ធ្ងន់ធ្ងរមធ្យម | ○ កង្វះថ្នាក់រៀន នឹងបង្កជាឧបសគ្គដល់ផ្នែកភស្តុភារនៃការរៀបចំការបង្រៀនឯកទេស នៅក្នុងសមត្ថភាពធ្វើការងារ |

| | | |
|---|---|---|
| | | បំណិនជីវិត ។ល។ |
| ៦. គុណភាពនៃហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន | ធ្ងន់ធ្ងរមធ្យម | ○ កម្សោយហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន នឹងបង្កជាឧបសគ្គដល់ផ្នែកភស្តុភារនៃការរៀបចំការបង្រៀនឯកទេស នៅក្នុងសមត្ថភាពធ្វើការងារ បំណិនជីវិត ។ល។<br>○ កម្សោយហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន នឹងកម្រិតសមត្ថភាពនៃសាលារៀនក្នុងការស្តុកសម្ភារៈឧបទ្ទេសនៅក្នុងថ្នាក់រៀន ដោយសារកម្សោយសន្តិសុខ ដែលអាចនឹងប៉ះពាល់ដល់ធាតុចូលក្នុងការពង្រឹងមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ |
| ៧. ការចូលរួមរបស់សហគមន៍ | ធ្ងន់ធ្ងរមធ្យម | ○ កម្សោយការចូលរួមពីសំណាក់សហគមន៍ នឹងធានាថា ការអនុវត្តកម្មវិធី SBEP ត្រូវបានគ្របសង្កត់ដោយនាយកសាលា<br>○ កម្សោយការចូលរួមពីសំណាក់សហគមន៍ នឹងធ្វើឲ្យធ្លាក់ចុះភាពជាកម្មសិទ្ធិ និងនិរន្តរភាពនៃធាតុចូលរបស់គម្រោង |
| ៨. ផ្លូវចូលទៅកាន់ទីតាំងភូមិសាស្ត្រ | ធ្ងន់ធ្ងរមធ្យម | ○ ផ្លូវទៅកាន់សាលារៀនមានការលំបាក នឹងកម្រិតសមត្ថភាពរបស់សាលារៀននោះក្នុងការទទួលបានថវិកាជំនួយឲ្យបានទាន់ពេលវេលា<br>○ ផ្លូវទៅកាន់សាលារៀនមានការលំបាក នឹងកម្រិតសមត្ថភាពរបស់អ្នកសម្របសម្រួលថ្នាក់ខេត្ត និងក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ក្នុងការជួយដល់សាលារៀន ដើម្បីធ្វើឲ្យសកម្មភាពរស់រវើក |

ការស្ទង់មតិដែលបញ្ជាក់ថា សាលារៀនមួយត្រូវបានកំណត់លក្ខណៈដោយកត្តាស្ថានភាពដែលធ្វើឲ្យអន្តរាយចាប់ពីបួនកត្តាឡើងទៅ គួរតែចាត់ទុកថា "ជួបការលំបាក" ជាពិសេសនៅពេលដែលកត្តាទាំងនេះ ត្រូវបានចាត់ទុកថាមានសារៈសំខាន់ខ្លាំង។

## ២.៤.២ វិធានការដើម្បីធានានូវការអនុវត្តដែលមានសមិទ្ធិលទ្ធភាព

បន្ទាប់ពីបញ្ចប់ការស្ទង់មតិបឋម ដែលធ្វើឡើងដោយក្រុមថ្នាក់ខេត្តរួច មន្ទីរអប់រំខេត្តនីមួយៗ ត្រូវពិចារណាអំពីជម្រើសរបស់ខ្លួនសម្រាប់ដោះស្រាយកត្តាស្ថានភាព ដែលអាចធ្វើឲ្យអន្តរាយដល់ការអនុវត្តកម្មវិធី SBEP ។ កម្រិតដែលអាចដោះស្រាយ ឬយ៉ាងហោចណាស់កាត់បន្ថយកត្តាទាំងនេះបាន នឹងបង្កើននូវភាពទំនងដែលការអនុវត្តគម្រោងអាចទទួលបានជោគជ័យ នៅក្នុងសាលារៀនណាមួយ។ វិធានការដែលបានផ្តល់ជាយោបល់ ដែលមានចែងនៅក្នុងតារាង ២.៥ គឺសម្រាប់ការពិចារណាដោយអ្នកអនុវត្តគម្រោង ដែលជាផ្នែកនៃការត្រៀមបឋមសម្រាប់ការអនុវត្តគម្រោង។

មិនមែនកត្តាស្ថានភាពទាំងអស់សុទ្ធតែអាចដោះស្រាយបានទាំងស្រុងបាននោះទេ ប៉ុន្តែយ៉ាងហោចណាស់ដោះស្រាយបានផ្នែកខ្លះ។

**តារាង ២.៥ ៖ ការឆ្លើយតបដែលបានផ្ដល់ជាយោបល់ចំពោះកត្តាស្ថានភាពដែលអាចសម្រុះសម្រួលការអនុវត្តគម្រោង**

| កត្តាស្ថានភាព | កម្រិត | វិធានការដោះស្រាយ |
|---|---|---|
| ១. លទ្ធភាពប្រើប្រាស់គ្រូបង្រៀនមានទាប | ខ្លាំង | ○ កំណត់អាទិភាពសាលារៀនដែលបានកំណត់ នៅពេលកំណត់ប៉ុស្តិ៍បម្រើការសម្រាប់គ្រូបង្រៀនថ្មី ដែលទើបបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| ២. កម្សោយវត្តមានគ្រូបង្រៀន | ខ្លាំង | ○ កំណត់អាទិភាពសាលារៀនដែលបានកំណត់ នៅពេលជ្រើសរើសទីតាំងសម្រាប់ការសាងសង់កន្លែងស្នាក់នៅរបស់គ្រូបង្រៀន |
| ៣. សមត្ថភាពគ្រប់គ្រងរបស់នាយកសាលាមានកម្រិតទាប | ខ្លាំង | ○ ករណីមានការរាយការណ៍ថា សមត្ថភាពគ្រប់គ្រងមានកម្រិតទាប ហើយការមិនជឿទុកចិត្តពីសហគមន៍មានកម្រិតខ្ពស់ត្រូវពិចារណាផ្លាស់ប្តូរបុគ្គលដែលស្ថិតក្រោមការពិចារណា<br>○ ដំឡើងឋានៈគ្រូបង្រៀនដែលមានសមត្ថភាព ដើម្បីឲ្យកាន់តំណែងជានាយករង |
| ៤. ប្រតិបត្តិការរបស់ក្រុមប្រឹក្សាសិស្សមាន កម្រិតទាប | ធ្ងន់ធ្ងរមធ្យម | ○ កំណត់អាទិភាពសាលារៀនដែលបានកំណត់ សម្រាប់ការគាំទ្រផ្នែកការកសាងសមត្ថភាពដើម្បីបង្កើតក្រុមប្រឹក្សាសិស្ស |
| ៥. លទ្ធភាពប្រើប្រាស់ថ្នាក់រៀននៅមានកម្រិត | ធ្ងន់ធ្ងរមធ្យម | ○ កំណត់អាទិភាពសាលារៀនដែលបានកំណត់ សម្រាប់ការគាំទ្រការកសាងកម្មវិធី ESDP III |
| ៦. កម្សោយគុណភាពនៃហេដ្ឋារចនាសម្ព័ន្ធថ្នាក់រៀន | ធ្ងន់ធ្ងរមធ្យម | ○ កំណត់អាទិភាពសាលារៀនដែលបានកំណត់ សម្រាប់ការគាំទ្រការកសាងកម្មវិធី ESDP III |
| ៧. ការចូលរួមពីសំណាក់សហគមន៍មានកម្រិតទាប | ធ្ងន់ធ្ងរមធ្យម | ○ រៀបចំការបោះឆ្នោតជ្រើសរើសគណកម្មការទ្រទ្រង់សាលាដែលនឹងត្រូវកំណត់ភាពជាអ្នកដឹកនាំថ្មីនៅក្នុងសហគមន៍<br>○ ករណីការមិនជឿទុកចិត្តពីសំណាក់សហគមន៍មានកម្រិតខ្ពស់ត្រូវពិចារណាផ្លាស់ប្តូរនាយកសាលា<br>○ ដំឡើងឋានៈគ្រូបង្រៀនដែលមានសមត្ថភាព ដើម្បីឲ្យកាន់តំណែងជានាយករង |

| | | | |
|---|---|---|---|
| ៨. ផ្លូវចូលទៅកាន់ទីតាំងភូមិសាស្ត្រមានភាពលំបាកខ្លាំង | ធ្ងន់ធ្ងរមធ្យម | ○ -- | |

### ២.៤.៣ ការស្ទង់មតិព័ត៌មានដំបូង

ការសិក្សាព័ត៌មានដំបូងជាទូទៅនៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុក នឹងត្រូវធ្វើឡើងនៅពេលចាប់ផ្តើមគម្រោង ដើម្បីបន្ថែមទៅក្នុងម៉ាទ្រិចត្រួតពិនិត្យ និងវាយតម្លៃ ដែលមានរៀបរាប់នៅក្នុងសៀវភៅណែនាំរដ្ឋបាលគម្រោង។ ប្រព័ន្ធ និងនីតិវិធីក្នុងការត្រួតពិនិត្យ និងធ្វើកំណត់ត្រា ដែលបានអនុវត្តតាមដោយនាយកដ្ឋានផែនការ នឹងត្រូវពិនិត្យឡើងវិញ និងកែប្រែតាមតម្រូវការនៅពេលត្រួតពិនិត្យនៅថ្នាក់ខេត្ត និងនៅថ្នាក់ស្រុក។ ការត្រួតពិនិត្យការអនុវត្តការងារគម្រោង នឹងផ្តោតទៅលើផែនការ និងគោលដៅអនុវត្តគម្រោង និងការប្រតិបត្តិ និងផលសម្រេចបានរបស់ពួកគេ។ រង្វាយតម្លៃការអនុវត្តការងារ ត្រូវពិនិត្យទៅលើឥទ្ធិពលនៃអន្តរាគមន៍របស់គម្រោង បញ្ហា និងឧបសគ្គ មូលហេតុ និងដំណោះស្រាយបញ្ហាទាំងនោះ។

### ២.៥ ការអភិវឌ្ឍឯកសារ

ដើម្បីអនុវត្តដោយប្រសិទ្ធភាពនូវអនុសាសន៍ក្នុងការបង្កើត ដែលមានគូសបញ្ជាក់នៅខាងលើ កម្មវិធី SBEP ត្រូវអភិវឌ្ឍន៍ស៊េរីឯកសារបណ្តុះបណ្តាល ដែលនឹងសម្របសម្រួលដល់ការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅគ្រប់កម្រិតទាំងអស់ ដើម្បីអនុវត្តកម្រងសកម្មភាពដាច់ដោយឡែកពីគ្នា។ ឯកសារទាំងនេះ ត្រូវមានទម្រង់ជាផែនការវគ្គសម្រាប់អ្នកសម្របសម្រួល ដើម្បីធានាឲ្យបាននូវគោលវិធីសិក្ខាកាមមជ្ឈមណ្ឌល (participant-centered approach) នៅពេលផ្តល់ខ្លឹមសារបណ្តុះបណ្តាល។

**តារាង ២.៦ ៖ ឯកសារដែលត្រូវការការអភិវឌ្ឍ ឬកែសម្រួលដោយធាតុចេញរង**

| ធាតុចេញរង | ចំណងជើងឯកសារបណ្តុះបណ្តាល | ក្រុមគោលដៅ | ចំណុចចាប់ផ្តើម | ឯកសារយោង |
|---|---|---|---|---|
| ***ការសាកល្បងជំនួយកែលម្អសាលារៀន*** | ○ សិក្ខាសាលាមូលដ្ឋានគ្រឹះស្តីពីការធ្វើផែនការសាលារៀន<br>○ <u>ចំណុចដែលត្រូវកសាងសមត្ថភាព៖</u> | ○ សាលារៀន-សហគមន៍ អ្នកពាក់ព័ន្ធ | ○ ដើមឆ្នាំសិក្សា | ○ សៀវភៅណែនាំជំនួយកែលម្អសាលា |

| | | | | |
|---|---|---|---|---|
| | • វិធីសាស្ត្រសម្រាប់ការវាយតម្លៃធនធាន ដែលចាំបាច់សម្រាប់សកម្មភាពធ្វើឲ្យប្រសើរឡើង។<br>• ការគ្រោងថវិកាសម្រាប់សកម្មភាពធ្វើឲ្យប្រសើរឡើង។<br>• ការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពធ្វើឲ្យប្រសើរឡើង។ | | | រៀន<br>○ សៀវភៅណែនាំការធ្វើផែនការមូលដ្ឋានគ្រឹះ IBEC |
| ***ពង្រឹងការអប់រំគណិតវិទ្យា*** | ○ សៀវភៅណែនាំការបណ្តុះបណ្តាលគណិតវិទ្យារបស់ INSET<br>○ <u>ចំណុចដែលត្រូវកសាងសមត្ថភាព៖</u><br>• វិធីសាស្ត្រសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ និងមុខវិជ្ជា។<br>• យុទ្ធសាស្ត្រសម្រាប់គាំទ្រប្រធានក្រុមបច្ចេកទេសដើម្បីធ្វើការជាមួយគ្រូបង្រៀនក្នុងការកំណត់សកម្មភាពធ្វើឲ្យប្រសើរឡើង។<br>• បុរេតេស្ត និងតេស្តក្រោយការសិក្សារបស់សិស្ស។ | ○ គ្រូបង្រៀនគណិតវិទ្យា<br>○ ប្រធានក្រុមបច្ចេកទេស | ○ វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៅដើមឆ្នាំ<br>○ វិក្រឹត្យការគ្រូបង្រៀនទៀងទាត់ | ○ ឯកសារបណ្តុះបណ្តាលរបស់ BETT |
| ***ពង្រឹងការអប់រំវិទ្យាសាស្ត្រ*** | ○ សៀវភៅណែនាំការបណ្តុះបណ្តាលវិទ្យាសាស្ត្ររបស់ INSET<br>○ <u>ចំណុចដែលត្រូវកសាង</u> | ○ គ្រូបង្រៀនវិទ្យាសាស្ត្រ<br>○ ប្រធានក្រុមបច្ចេកទេស | ○ វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៅ | ○ សៀវភៅណែនាំរបស់ VVOB SEAL |

| | | | | |
|---|---|---|---|---|
| | <u>សមត្ថភាព៖</u><br>• វិធីសាស្ត្រសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ និងមុខវិជ្ជា។<br>• យុទ្ធសាស្ត្រសម្រាប់គាំទ្រប្រធានក្រុមបច្ចេកទេសដើម្បីធ្វើការជាមួយគ្រូបង្រៀនក្នុងការកំណត់សកម្មភាពធ្វើឲ្យប្រសើរឡើង។<br>• បុរេតេស្ត និងតេស្តក្រោយការសិក្សារបស់សិស្ស។ | | ដើមឆ្នាំ<br>○ វិក្រឹត្រការគ្រូបង្រៀនទៀងទាត់ | ○ សៀវភៅណែនាំរបស់ JICA STEPSAM |
| ***ណែនាំបំណិនសមត្ថភាពធ្វើការងារ*** | ○ សៀវភៅណែនាំស្តីពីការអនុវត្តបំណិនជីវិត<br>○ សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលបុគ្គលធនធានអាជីព | ○ គ្រូបង្រៀនបំណិនជីវិត<br>○ បុគ្គលធនធានសហគមន៍ | ○ វគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៅដើមឆ្នាំ | ○ សៀវភៅណែនាំរបស់ VOD<br>○ កម្មវិធីសិក្សាបំណិនជីវិតរបស់ EEQP<br>○ សៀវភៅណែនាំរបស់ DCD អភិវឌ្ឍន៍ជាមួយ IBEC |
| ***ពង្រឹងការគ្រប់គ្រងនៅតាមសាលារៀន*** | ○ សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ<br>○ ចំណុចដែលត្រូវកសាងសមត្ថភាព៖ | ○ នាយកសាលា<br>○ នាយករង<br>○ សមាជិក SSC | ○ សិក្ខាសាលា ៤ លើកក្នុងរយៈពេលពីរឆ្នាំ | ○ សៀវភៅណែនាំរបស់ IBEC SMLTC<br>○ សៀវភៅណែនាំ |

| | | |
|---|---|---|
| | • ភាពជាអ្នកដឹកនាំសាលារៀន<br>• ការចូលរួមរបស់គណកម្មការទ្រទ្រង់សាលា (SSC) | សម្រាប់ការបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំរបស់ CESSP |

## ៣. បទបញ្ញត្តិនៃការត្រួតពិនិត្យ

កម្មវិធី SBEP ដែលបានស្នើ រៀបចំគម្រោងសម្រាប់កម្រិតនៃសកម្មភាពត្រួតពិនិត្យចំនួនបួនខុសៗគ្នា ឆ្លើយតបទៅនឹងថ្នាក់សាលារៀន ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ បទបញ្ញត្តិនៃការត្រួតពិនិត្យបានចាប់បដិសន្ធិឡើង ដើម្បីដាក់បញ្ចូលនូវកម្រិតខ្លះនៃស្វ័យត្រួតពិនិត្យ ដើម្បីលើកកម្ពស់ភាពជាកម្មសិទ្ធិ និងតម្លៃខាងក្នុងនៃការផ្តល់សេវាអប់រំប្រកបដោយគុណភាពខ្ពស់ ក៏ដូចជាគោលវិធីដែលកាន់តែងាយស្រួល រួមទាំងការត្រួតពិនិត្យពីខាងក្រៅ។ សាលារៀនដែលគាំទ្រដោយកម្មវិធី SBEP នឹងតម្រូវឲ្យចុះហត្ថលេខាលើ **ទម្រង់ប្តេជ្ញាចិត្តមួយ** ដែលលាតត្រដាងអំពីការទទួលខុសត្រូវរបស់ពួកគេចំពោះការទទួលបានថវិកា ការចំណាយ និងសកម្មភាពត្រួតពិនិត្យឲ្យបានត្រឹមត្រូវ។ ទម្រង់ទាំងនេះ នឹងត្រូវចារដោយការិយាល័យអប់រំស្រុក (DoEYS) និងអនុម័តដោយមន្ទីរអប់រំខេត្ត (PoEYS) (សូមមើលទម្រង់ ឈ / ឧបសម្ព័ន្ធ ៦)។ សេចក្តីលម្អិតជាក់លាក់សម្រាប់បទបញ្ញត្តិនៃការត្រួតពិនិត្យ ត្រូវបានគ្រោងដូចខាងក្រោម៖

### ៣.១. បទបញ្ញត្តិនៃការត្រួតពិនិត្យនៅថ្នាក់សាលារៀន

គណកម្មការទ្រទ្រង់សាលា (SSC) ទទួលខុសត្រូវចំពោះការអនុវត្តសកម្មភាពជំនួយ។ គណកម្មការទ្រទ្រង់សាលា ត្រូវធ្វើផែនការត្រួតពិនិត្យផ្ទាល់ខ្លួនដោយប្រើ *ទម្រង់ ជ ៖ ផែនការតាមដានការត្រួតពិនិត្យ និងវាយតម្លៃ* ដើម្បីធ្វើកិច្ចការនេះ (សូមមើល ឧបសម្ព័ន្ធ ២)។ ទម្រង់នេះ គ្រោងនូវអ្វីដែលសាលារៀនត្រូវត្រួតពិនិត្យសម្រាប់សកម្មភាពនីមួយៗដែលបានកំណត់នៅក្នុងផែនការ ព្រមទាំងបុគ្គលដែលនឹងត្រូវធ្វើកិច្ចការនេះ។ ស្វ័យតាមដានតាមវិធីនេះ នឹងជួយដល់ការធ្វើមជ្ឈន្តិកៈតម្លៃនៃគណនេយ្យភាព និងការផ្តល់សេវាអប់រំជាលក្ខណៈអាជីព ដូចដែលបានកត់សម្គាល់នៅខាងលើ។ ការបំពេញសកម្មភាពត្រួតពិនិត្យ ត្រូវកត់ត្រាដោយប្រើ ***ទម្រង់របាយការណ៍អំពីស្វ័យវាយតម្លៃ*** ដែលបានបង្កើតដោយក្រសួងអប់រំ ដែលជាផ្នែកមួយនៃគោលនយោបាយសាលាកុមារមេត្រី។

ការបង្កើតបុរេតេស្ត និងតេស្តក្រោយពេលសិក្សានៅក្នុងមុខវិជ្ជាសំខាន់ៗមួយចំនួនដូចជា គណិតវិទ្យា និងវិទ្យាសាស្ត្រ នឹងបង្ហាញជារូបរាងច្បាស់លាស់ក្នុងការត្រួតពិនិត្យសាលារៀន។ សាលារៀននឹងត្រូវបានគាំទ្រនៅក្នុងការបង្កើត *តារាងលក្ខណៈបច្ចេកទេស* សម្រាប់មុខវិជ្ជាជាក់លាក់ ដើម្បីឲ្យតេស្តដែលបានបង្កើតឡើង សម្តែងឲ្យឃើញនូវលក្ខណៈសុពលភាពទាំងខ្លឹមសារ និងជំនាញ។ **តេស្តគំរូ** នឹងត្រូវបានផ្តល់ទៅឲ្យសាលារៀន ដើម្បីឲ្យពួកគេអាចបង្កើតឧបករណ៍វាយតម្លៃដោយខ្លួនឯង ដែលលើកជាតួយ៉ាងអំពីបំណងរបស់គម្រោងក្នុងការលើកកម្ពស់ និងវាស់ស្ទង់ការវាយតម្លៃជំនាញក្នុងការគិតកម្រិតខ្ពស់។ សម្រាប់ការត្រួតពិនិត្យភាពរីកចម្រើនរបស់សិស្ស នៅក្នុងការទទួលបានបំណិនដែលអាចរកការងារបាន សាលារៀនត្រូវប្រើក្របខណ្ឌវង្វាយតម្លៃសិស្សដែលបានផ្តល់ជូននៅក្នុងសៀវភៅណែនាំ ដែលបានបង្កើតដោយនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា។

រាល់ការទិញទំនិញ និងសេវាដោយគណកម្មការទ្រទ្រង់សាលា ត្រូវគោរពតាមនីតិវិធីលទ្ធកម្មត្រឹមត្រូវដែលបានចែងដោយនាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងអប់រំ។ បង្កាន់ដៃសម្រាប់ការទិញទំនិញ និងសេវាទាំងអស់អាចមានលទ្ធភាពប្រើប្រាស់បានសម្រាប់អ្នកត្រួតពិនិត្យ និងអ្នកចុះអធិការកិច្ចគម្រោង។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនអំពីការត្រួតពិនិត្យនៅថ្នាក់សាលារៀន និងភ្នាក់ងារត្រួតពិនិត្យខុសៗគ្នាដែលស្ថិតនៅក្នុងថ្នាក់នោះ៖

- *នាយកសាលា* អនុវត្តការត្រួតពិនិត្យប្រចាំថ្ងៃនៅតាមសាលារៀនរបស់ខ្លួន ឧ. ការអនុវត្តការងាររបស់គ្រូបង្រៀន វត្តមានរបស់គ្រូបង្រៀន និងសិស្ស ការប្រើប្រាស់បណ្ណាល័យ ការប្រជុំក្រុមបច្ចេកទេសប្រចាំសប្តាហ៍។
- *អ្នកសម្របសម្រួលថ្នាក់ខេត្ត (PFs) និងក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក (DTMTs)* ចុះត្រួតពិនិត្យការបង្រៀន និងការរៀន។
- *សមាជិកសហគមន៍* ទស្សនកិច្ចសាលារៀន អង្កេតមើលវត្តមានរបស់គ្រូបង្រៀន ការអនុវត្តសកម្មភាពរបស់សាលារៀន និងតាមដានមើលអវត្តមានរបស់សិស្សដល់ផ្ទះរបស់ពួកគេ។
- *បណ្ណារក្ស* មានសៀវភៅចុះឈ្មោះអ្នកចូលអាន និងប្រព័ន្ធតាមដានការប្រើប្រាស់បណ្ណាល័យក្នុងម៉ោងចេញលេង និងនៅម៉ោងផ្សេងៗក្នុងរយៈពេលមួយថ្ងៃ។
- *គណកម្មការទ្រទ្រង់សាលា (SSC)* រក្សាកំណត់ត្រាអំពីកំណត់ហេតុ និងរបៀបវារៈនៃការប្រជុំរបស់ខ្លួន។

ដោយមានជំនួយពីអ្នកផលិតគំនូរជីវចល គណកម្មការទ្រទ្រង់សាលា ត្រូវទទួលខុសត្រូវចំពោះការដាក់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ (MFR) ជូនការិយាល័យអប់រំស្រុក។ របាយការណ៍នេះ ត្រូវវាយមុខចំណាយទាំងអស់នៃជំនួយសម្រាប់ខែនោះ និងដាក់បញ្ចូលឯកសារពាក់ព័ន្ធទាំងអស់។

## ៣.២. បទបញ្ញត្តិនៃការត្រួតពិនិត្យនៅថ្នាក់ស្រុក

*អ្នកសម្របសម្រួលថ្នាក់ខេត្ត៖* អ្នកសម្របសម្រួលថ្នាក់ខេត្ត មានទំនួលខុសត្រូវជាគោលការណ៍ចំពោះវឌ្ឍនភាពនៃការត្រួតពិនិត្យទៅលើការអនុវត្តកម្មវិធី SBEP ។ នៅពេលពួកគេចុះទស្សនកិច្ចសាលារៀន ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពរបស់ជំនួយ ទាំងអ្នកសម្របសម្រួលថ្នាក់ខេត្ត និងក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ត្រូវធ្វើការឲ្យបានជិតស្និទ្ធជាមួយគ្នា ដើម្បីរក្សាកំណត់ត្រាជាលាយលក្ខណ៍អក្សរអំពីការចុះទស្សនកិច្ចរបស់ខ្លួន ដោយកត់សម្គាល់អំពី (ឧទាហរណ៍)៖

- បញ្ហាដែលត្រូវការវិធានការបន្ថែម
- មេរៀនពិសោធន៍ (lessons learned)
- ការចាត់វិធានការរបស់ពួកគេ និង/ឬសាលារៀន/កម្រង
- លទ្ធផលសម្រេចរបស់សាលារៀន/កម្រង

ព័ត៌មាននេះ នឹងត្រូវយកមកប្រើជាធាតុចូលសម្រាប់របាយការណ៍របស់ពួកគេ។
នៅចុងឆមាសទីមួយ (មករា-កុម្ភៈ) អ្នកសម្របសម្រួលថ្នាក់ខេត្ត ត្រូវចងក្រងព័ត៌មាន និងដាក់ជូននូវ **របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តជំនួយ។** អ្នកសម្របសម្រួលថ្នាក់ខេត្ត ត្រូវធ្វើរបាយការណ៍សម្រាប់ខេត្តទាំងមូល ចំណែកក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ត្រូវចងក្រងរបាយការណ៍សម្រាប់ស្រុករបស់ពួកគេរៀងៗខ្លួន ជាមួយអ្នកដែលពួកគេធ្វើការជិតស្និទ្ធជាមួយ (សូមមើលខាងក្រោម)។ របាយការណ៍ស្តីពី

ការអនុវត្តទាំងនេះ ត្រូវពឹងផ្អែកភាគច្រើនទៅលើព័ត៌មានដែលបានបង្កើតដោយ របាយការណ៍ស្តីពីការត្រួតពិនិត្យសាលារៀន ដែលបានបង្កើតដោយក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក (សូមមើលខាងក្រោម)។

*ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក៖* ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ត្រូវដាក់**របាយការណ៍ស្តីពីការត្រួតពិនិត្យសាលារៀន** (សូមមើល ទម្រង់ ៣ / ឧបសម្ព័ន្ធ ៦) ស្តីពីការអនុវត្តជំនួយ ជូនការិយាល័យអប់រំស្រុកប្រចាំឆមាសនីមួយៗ។ មាតិកានៃរបាយការណ៍នេះ នឹងត្រូវពិភាក្សានៅក្នុងការប្រជុំក្រុមគំនូរជីវចលថ្នាក់ស្រុក។ ប្រធានគណកម្មការទ្រទ្រង់សាលា ត្រូវផ្តល់ព័ត៌មាននេះត្រឡប់ទៅកាន់គណកម្មការទាំងមូល ដែលជាអ្នកត្រូវធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើបញ្ហាទាំងនេះ។ ក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក មានទំនួលខុសត្រូវក្នុងការមើលការខុសត្រូវការបង្កើតផែនការកែលម្អសាលារៀន ធ្វើការជិតស្និទ្ធជាមួយអ្នកសម្របសម្រួលថ្នាក់ខេត្ត ដើម្បីធានានូវការអនុវត្តគ្រោងការណ៍ដោយរលូន និងកសាងសមត្ថភាពរបស់ខ្លួន ដើម្បីគ្រប់គ្រងដំណើរការពីអ្នកសម្របសម្រួលថ្នាក់ខេត្ត សម្រាប់ការបង្កើត និងការអនុវត្តផែនការសាលារៀននាពេលអនាគត។

## ៣.៣. ថ្នាក់ខេត្ត

នៅចុងឆ្នាំវដ្តគម្រោង អ្នកសម្របសម្រួលថ្នាក់ខេត្ត ត្រូវបំពេញ**របាយការណ៍ស្តីពីការត្រួតពិនិត្យ និងតាមដានគម្រោង** សម្រាប់សាលារៀនទាំងអស់រួមគ្នា ក្រោមការទទួលខុសត្រូវ និង**របាយការណ៍ស្តីពីការត្រួតពិនិត្យសាលារៀន**ប្រចាំឆ្នាំ (ដែលចងក្រងដោយក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក) សម្រាប់សាលារៀននីមួយៗ។ ពួកគេត្រូវផ្ញើឯកសារទាំងនេះជាមួយនឹងសន្លឹកសង្ខេបអំពីសាលារៀនជូនមន្ទីរអប់រំខេត្ត។ ពួកគេក៏ត្រូវជួបជាមួយមន្ត្រីនៅការិយាល័យអប់រំស្រុក និងមន្ទីរអប់រំខេត្ត ដើម្បីពិភាក្សាអំពីលទ្ធផលសម្រេចនៃសកម្មភាពនីមួយៗ និងមេរៀនពិសោធន៍ផងដែរ។ លទ្ធផលរបស់ពួកគេ នឹងត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់មន្ទីរអប់រំខេត្ត ហើយមាតិកានៃរបាយការណ៍នោះ ត្រូវបានពិភាក្សាគ្នានៅក្នុងកិច្ចប្រជុំជាទៀងទាត់នៅមន្ទីរអប់រំខេត្ត។

គណនេយ្យករនៅមន្ទីរអប់រំខេត្ត ត្រូវផ្ទៀងផ្ទាត់**របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ**របស់សាលារៀន។ ប្រសិនបើមានបញ្ហាពួកគេត្រូវចុះទស្សនកិច្ចសាលារៀន និងពិនិត្យមើលដំណើរការនិងកំណត់ត្រាហិរញ្ញវត្ថុ។

របាយការណ៍ចុងក្រោយដែលរៀបចំដោយអ្នកសម្របសម្រួលថ្នាក់ខេត្ត **របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ** ប្រមូលផ្តុំព័ត៌មាន ការអង្កេត អនុសាសន៍ មេរៀន និងបញ្ហាពីឆ្នាំគម្រោងពេញលេញ។ របាយការណ៍នេះ ត្រូវដាក់ជូនមន្ទីរអប់រំខេត្ត ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍ និងអនុសាសន៍របស់មន្ទីរអប់រំ ដើម្បីដាក់ជូននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ សមាជប្រចាំឆ្នាំរបស់ក្រសួងអប់រំ។

មន្ទីរអប់រំខេត្ត សម្របសម្រួលការរៀបចំផែនការប្រចាំត្រីមាសជាមួយអ្នកសម្របសម្រួលថ្នាក់ខេត្ត និងក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ដើម្បីធានាឲ្យបាននូវការគ្របដណ្តប់ទូលំទូលាយនៃសកម្មភាពរបស់សាលារៀនទាំងអស់។ គោលបំណងនៃផែនការនេះគឺ ដើម្បីចៀសវាងភាពត្រួតស៊ីគ្នានៃការចុះអធិការកិច្ចដោយក្រុមផ្សេងៗគ្នា និងដើម្បីបង្កើតនូវភាពខុសគ្នានៃទំនួលខុសត្រូវឲ្យបានច្បាស់លាស់។

ការិយាល័យគណនេយ្យ និងផែនការនៃមន្ទីរអប់រំខេត្ត ត្រូវដាក់**របាយការណ៍ហិរញ្ញវត្ថុប្រចាំខែ**ជូននាយកដ្ឋានហិរញ្ញវត្ថុ ដែលត្រូវដាក់បញ្ចូលនូវជំនួយ និងចំណាយដែលពាក់ព័ន្ធនឹងគម្រោងដទៃទៀត ដែលកើតឡើងនៅថ្នាក់ខេត្ត។ ការិយាល័យគណនេយ្យ និងផែនការនៃមន្ទីរអប់រំខេត្ត ក៏ត្រូវរៀបចំការផ្ទៀងផ្ទាត់សម្រាប់ជំនួយនីមួយៗនៅចុងវដ្តថវិកាផងដែរ ហើយត្រូវរាយការណ៍/ពិភាក្សាអំពីភាពមិនប្រក្រតីណាមួយជាមួយប្រធានមន្ទីរអប់រំខេត្ត។

ប្រធានមន្ទីរអប់រំខេត្ត ដោយមានធាតុចូលពីអ្នកសម្របសម្រួលថ្នាក់ខេត្ត និងក្រុមបណ្តុះបណ្តាល និងត្រួតពិនិត្យថ្នាក់ស្រុក ក៏ត្រូវអនុវត្តការវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់អ្នកផលិតគំនូរជីវចលផងដែរ។ ក្នុងន័យនេះ អ្នកសម្របសម្រួលថ្នាក់ខេត្ត គឺជាភ្នាក់ងារផ្លាស់ប្តូរដ៏សំខាន់នៅក្នុងការសម្របសម្រួលការអនុវត្ត កម្មវិធី SBEP ។ ការអនុវត្តការងាររបស់ពួកគេ ត្រូវបានរំពឹងថានឹងមានឥទ្ធិពលដែលមានសារៈសំខាន់ទៅលើលទ្ធផលសម្រេចរបស់គម្រោង។ ប្រធានមន្ទីរអប់រំខេត្ត អនុវត្តការវាយតម្លៃការអនុវត្តការងាររបស់ពួកគេ ដោយមានការគាំទ្របច្ចេកទេសពីការិយាល័យផ្សេងៗរបស់មន្ទីរអប់រំខេត្ត។ ដំណើរការនៃការវាយតម្លៃ ត្រូវចាប់ផ្តើមជាដំបូងជាមួយនឹងអ្នកសម្របសម្រួលថ្នាក់ខេត្ត ដោយអនុវត្តស្វ័យវាយតម្លៃ។ ក្នុងការធ្វើកិច្ចការនេះ ពួកគេអាចប្រមូលភស្តុតាង (ពីរបាយការណ៍ជាលាយលក្ខណ៍អក្សរ លំដាប់លំដោយនៃព្រឹត្តិការណ៍ ឧទាហរណ៍អំពីការងារដែលបានបំពេញ) នៃការអនុវត្តភ្ជាប់នឹងការងារ។ នៅអំឡុងពេលវាយតម្លៃ អ្នកសម្របសម្រួលថ្នាក់ខេត្ត និងអ្នកវាយតម្លៃ ត្រូវប្រើស្វ័យវាយតម្លៃជាមូលដ្ឋានសម្រាប់ការពិភាក្សា ហើយត្រូវចរចារគ្នាអំពីកម្រិតនៃការអនុវត្តការងារដែលមានការឯកភាពគ្នា។ តារាង "ដែលផ្អែកលើស្តង់ដារ" ដែលមានយ៉ាងហោចណាស់ប្រាំកម្រិតនៃអ្នកបរិយាយ ដែលទាក់ទងនឹងលក្ខណៈវិនិច្ឆ័យនៃការអនុវត្តការងារដែលបានផ្តល់ជូន នឹងត្រូវបានបង្កើតឡើង ដើម្បីសម្របសម្រួលការវាយតម្លៃការអនុវត្តការងាររបស់អ្នកសម្របសម្រួលថ្នាក់ខេត្ត។

## ៣.៤. ថ្នាក់ជាតិ

| សមាសភាគ | ល.រ | បញ្ហា | សកម្មភាព | ធនធាន | រូបភាព |
| --- | --- | --- | --- | --- | --- |
| | ៣១ | ○ ការប្រជុំបច្ចេកទេសពុំបានទៀងទាត់ នឹងពុំសូវមានប្រសិទ្ធិភាព។ | ការគាំទ្រការប្រជុំបច្ចេកទេសប្រចាំខែ:សាលារៀនធ្វើការប្រជុំបច្ចេកជារៀងរាល់ខែដើម្បីជម្រុញការងារបង្រៀននិងរៀនឱ្យទទួលបានប្រសិទ្- ភាពខ្ពស់។ ប្រធានបទសិក្ខាសាលាត្រូវរួមបញ្ចូល “របៀបបង្រៀន ការផ្តល់ព័ត៌មានត្រឡប់កំឡុងពេលជជែកមួយទល់និងមួយ ប្រសិទ្ធភាពនៃការប្រើសម្ភារឧបទេសជំនួយ និងប្រធានបទផ្សេងៗទៀត”។ | ○ ប្រធានបទវគ្គបណ្តុះបណ្តាលសម្រាប់វិធីស្តីពីការរៀបចំការប្រជុំបច្ចេកទេសឲ្យមានប្រសិទ្ធភាព<br>○ សោហ៊ុយប្រចាំថ្ងៃសម្រាប់អ្នកចូលរួមសិក្ខាសាលា និងអ្នកណែនាំ<br>○ សម្ភារសិក្ខាសាលា និងអាហារសម្រន់ |  |
| | ៣២ | ○ អ្នកពាក់ព័ន្ធនៅមូលដ្ឋានមិនបានធ្វើផែនការដោយចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ<br>○ កង្វះគំនិតនិងបទពិសោធន៍លើសកម្មភាពសម្រាប់ការអភិវឌ្ឍសាលា។ | ការធ្វើផែនការអភិវឌ្ឍន៍សាលារៀន:សាលារៀនធ្វើផែនការអភិវឌ្ឍសាលារៀនដោយប្រើប្រាស់បញ្ជីសកម្មភាពដើម្បីជួយដោះស្រាយតម្រូវការដែលលើកឡើងដោយសិស្សគ្រូបង្រៀនតំណាងសហគមន៍។ ការជ្រើសរើសសកម្មភាពគឺធ្វើតាម គោលការណ៍ស្ម័គ្រចិត្ត និងដឹកនាំដោយអ្នកពាក់ព័ន្ធ។ | ○ ថវិកាឧបត្ថម្ភសិក្ខាកាម<br>○ បញ្ជីសកម្មភាព<br>○ សម្ភារដំណើរការផែនការ |  |

*<u>ចំណាំ៖</u>* សាលអាចបន្ថែមសកម្មភាពជាច្រើនទៀតលើផែនការរបស់ពួកគេជាមួយនិងយុត្តិកម្មដ៏ល្អ។

# ឧបសម្ព័ន្ធ ទី៥៖ បញ្ជីរខ្លឹមសារកម្មវិធីបំណិនជីវិតរបស់ MoEYS

**( យល់ព្រមដោយ DCD និងបច្ចុប្បន្នស្ថិតនៅក្រោមត្រួតពិនិត្យដោយក្រុមប្រឹក្សាឯកភាពសៀវភៅសិក្សាសម្រាប់ការលំនាំតាមជាផ្លូវការ )**

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| **ប្រភេទ១: បំណិនទាក់ទងបញ្ហាសង្គមក្នុងមូលដ្ឋាន** | ១ | ការយល់ដឹងពីពលរដ្ឋវិជ្ជា: ប្រធានបទនេះទាក់ទងទៅនឹងទម្រង់គ្រប់គ្រងរដ្ឋ (ឧ. កម្រិតខេត្តស្រុកឃុំ)។ ការស្វែងយល់ពីតួនាទីយុវជនស្ត្រីនិងក្រុមភាគតិចនៅក្នុងសង្គមនិងការស្វែងយល់ពីសិទ្ធិមនុស្សផងដែរ។ | ○ សៀវភៅណែនាំគ្រូ<br>○ បូស្ទ័រ (តើនរណាគ្រប់គ្រង?<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ២០ ម៉ោង<br>○ ត្រូវជាមួយថ្នាក់ខ្ពស់<br>○ គ្រប់រដូវកាល |  |
| | ២ | ចំណាកស្រុកដោយសុវត្ថិភាព: ប្រធានបទនេះជួយយុវជនឲ្យស្គាល់ ពីគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុងនិងទទួលបានការយល់ដឹងពីមធ្យោបាយដែលមានសុវត្ថិភាពបំផុតក្នុងការស្វែងរកការងារធ្វើនៅខាងក្រៅភូមិស្រុករបស់ខ្លួន។ យុវជនដឹងអំពីគុណសម្បត្តិនិងគុណវិបត្តិនៃ ការធ្វើចំណាកស្រុកដើម្បីធ្វើការសំរេចចិត្តឲ្យបានត្រឹមត្រូវពីជីវិតរស់នៅក្នុងទីក្រុង។ ប្រធានបទនេះធ្វើការពិភាក្សាផងដែរទៅលើច្បាប់ ជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ចំណាកស្រុក)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ៣ | ការទប់ស្កាត់ការញៀនគ្រឿងស្រវឹងៈ ប្រធានបទនេះជួយឲ្យសិស្សយល់ដឹងពីផលប៉ះពាល់នៃជាតិសុរាទៅលើរាងកាយនឹងផ្លូវចិត្តនិតឥទ្ធិពលរបស់វាក្នុងរយៈពេលខ្លីនិងវែង។ សិស្សនឹងសិក្សាសផងដែរអំពីផលវិបាកនៃសុរាចំពោះគ្រួសារនិងមិត្តភក្តិនិងវិធានការក្នុងការទប់ស្កាត់ការញៀនគ្រឿងស្រវឹង។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ចូរគិតសារជាថ្មី...)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ក្រដាសផ្ទាំងធំហ្វឹត | ○ ១២ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | | | | • | |
| | ៤ | ការទប់ស្កាត់គ្រឿងញៀនៈប្រធានបទនេះជួយសិស្សឱ្យយល់ដឹងពីប្រភេទគ្រឿងញៀនផ្សេងៗនៅក្នុងប្រទេសកម្ពុជានិងស្វែងយល់ពីផលប៉ះពាល់នៃគ្រឿងញៀនទៅលើរាងកាយនិងផ្លូវចិត្តរបស់ អ្នកប្រើប្រាស់រយៈពេលខ្លីនិងវែង។ ក្នុងមេរៀននេះនឹងសិក្សាផងដែរពីមូលហេតុដែលធ្វើឱ្យយុវជនក្លាយជាអ្នកញៀនថ្នាំ (ឧ.សម្ពាធពីមិត្តភក្តិអារម្មណ៍មិននឹងនរបស់ មនុស្ស...)និងវិធីផ្សេងៗដែលសហគមន៍ មូលដ្ឋានប្រើប្រាស់ដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (គ្រឿងញៀននៅ...)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ សម្ភារៈលេងល្បែងសិក្សា<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឯកសារធនធានៈ គ្រោះថ្នាក់គ្រឿងញៀន ចម្រៀងជៀសវាងពីថ្នាំញៀន | ○ ១២ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ៥ | ទឹកស្អាតនិងអនាម័យផ្ទាល់ខ្លួនៈប្រធានបទនេះពន្យល់ពី សារៈសំខាន់របស់ទឹកនៅក្នុងបរិស្ថានធម្មជាតិ ទម្រង់ផ្សេងៗនៃប្រភព ទឹក (ភ្លៀងទន្លេ...) និងរបៀបប្រើប្រាស់ទឹកឱ្យមានសុវត្ថិភាព។ មេរៀននេះនឹងពិភាក្សាផងដែរទៅលើមូលហេតុធ្វើឱ្យកង្វក់ទឹកនិងផលប៉ះពាល់ដល់សុខភាពមនុស្សនិងបរិស្ថានធម្មជាតិ។ ជាចុងក្រោយសិស្សរៀនពីការប្រើប្រាស់ទឹកដើម្បីសុខភាពផ្ទាល់ខ្លួន និងអនាម័យគ្រួសារ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (លាងសម្អាតដៃ/ការបំពុលទឹក)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ៦ | ការយល់ដឹងពីវប្បធម៌ផ្សេងៗៈប្រធានបទនេះធ្វើឱ្យសិស្សយល់ដឹងពីអត្ថន័យនៃពាក្យវប្បធម៌ ចរិតលក្ខណៈនៃវប្បធម៌នីមួយៗ មានឥទ្ធិពលទៅលើការប្រព្រឹត្តរបស់បុគ្គល។ មេរៀននេះនឹងលើក ឡើងពីការយល់ដឹងពីគ្នាទៅវិញទៅមកនៃវប្បធម៌ផ្សេងៗគ្នា ដូចជាខ្មែរ ចាម គួយព្នងចិនវៀតណាម ដើម្បីយោគយល់គ្នារស់នៅក្នុងសង្គមតែមួយ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ប្រជាជនក្នុងប្រទេសកម្ពុជា)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាកម៉ោងបន្ថែមរបស់គ្រូ<br>○ អ្នកជំនាញតាមសហគមន៍ | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ មិនដាក់កម្រិតចំពោះរដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ៧ | ការយល់ដឹងពីបរិស្ថានធម្មជាតិ: ប្រធានបទនេះជួយសិស្សឱ្យយល់ដឹងពីបរិស្ថានសង្គមនិងបរិស្ថានធម្មជាតិព្រមទាំងអន្តរ- កម្មរវាងគ្នាទៅវិញទៅមកដែលផ្តល់ផលវិជ្ជមាននិងផលអវិជ្ជមាន។ មេរៀននេះនឹងពិភាក្សាគោលការណ៍ចម្បងនៃធម្មជាតិ សារៈសំខាន់ របស់ធម្មជាតិនិងតុល្យភាពរវាងតម្រូវការរបស់មនុស្សនិងបរិស្ថានសង្គមនៅគ្រប់ទិដ្ឋភាពទាំងអស់ រួមមានទឹកដីព្រៃខ្យល់អាកាសថាមពល...។ សិស្សដឹងពីសកម្មភាពក្នុងការការពារបរិស្ថានធម្មជាតិដូចជាការច្នៃវត្ថុប្រើប្រាស់ឡើងវិញនិងការគ្រប់គ្រងកាកសំណល់។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ប្រើប្រាស់ម្តងទៀត/ថាមពល/កាកសំណល់/កង្វក់ខ្យល់/បរិស្ថាន)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឯកសារធនធានបរិស្ថានយើង (ស៊ីប៉ា) | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ៨ | ការយល់ដឹងផ្ទាល់ខ្លួន និងទំនាក់ទំនងសង្គមៈប្រធានបទនេះជួយសិស្សឱ្យយល់ដឹងអំពីសេចក្តីត្រូវការនិងអារម្មណ៍ផ្ទាល់ខ្លួន ។ សិស្សសិក្សាអំពីវិធីសហការគ្នាដែលសមស្របនិងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព។ សិស្សដឹងពីការប្រាស្រ័យទាក់ទងជាមួយ មនុស្សដែលមានអារម្មណ៍ផ្សេងៗគ្នា ដូចជាខឹងសប្បាយខ្លាចទុក្ខព្រួយនិងបញ្ហាសង្គមដែលពួកគេអាចធ្វើការជាមួយបាន។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (អារម្មណ៏ដូចម្តេច)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ៩ | ការយល់ដឹងពីយេនឌ័រៈប្រធានបទនេះជួយសិស្សអោយមានការយល់ដឹងទៅលើក្រមវប្បធម៌អំពីយេនឌ័រ។ សិស្សនឹងយល់គ្នាពីវប្បធម៌មួយទៅមួយទៀតនូវភាពខុសគ្នារវាងបុរសនិងស្ត្រី។ សិស្ស នឹងវិភាគទៅលើទម្លាប់យេនឌ័រ និងផ្លាស់ប្តូរទស្សនៈរបស់ខ្លួនទៅលើ តួនាទីយេនឌ័រក្នុងសង្គម។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (អារម្មណ៍ដូចម្តេច)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ២០ ម៉ោង<br>○ ត្រូវគ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ១០ | តន្ត្រីនិងរបាំៈប្រធានបទនេះពិភាក្សាអំពីចរិតលក្ខណៈរបស់ទម្រង់សិល្បៈផ្សេងៗផ្នែកតន្ត្រីនិងរបាំ តាមរយៈការសង្កេត និង ប្រតិបត្តិ (ឧ. របាំប្រពៃណីដូចជារាមកេរ្តិ៍ល្ខោនខោល )។ សិស្សនឹងរៀនអំពីប្រភេទ ឧបករណ៍ភ្លេងបុរាណនិងប្រភេទរបាំប្រពៃណី ផ្សេងៗ។ សិស្សនឹងរៀនសំដែងសិល្បៈដែលពួកគេជ្រើសរើសជាមួយ គ្រូរបស់ពួកគេដូចជារឿងរាមកេរ្តិ៍ជាដើម។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (របាំប្រជាប្រិយ/ក្បាច់របាំ/ពិណពាទ្យ/រាមកេរ្តិ៍)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ អ្នកជំនាញសិល្បក្នុងសហគមន៍<br>○ ស៊ីឌីចម្រៀងនិងតន្ត្រី | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| **ប្រភេទទី២: បំណិនទាក់ទងនឹងអាជីវកម្ម សេដ្ឋកិច្ច និងការងារ** | ១១ | ជំនាញទីផ្សារខ្ញុំ:ប្រធានបទនេះធ្វើឱ្យសិស្សយល់ដឹងនូវមូល-ដ្ឋានកំណត់ត្រាបញ្ជីចំណូលចំណាយនិងវិធីប្រើប្រាស់បំណិនទាំងនេះនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ សិស្សសិក្សាអំពីការស្រាវជ្រាវពីវិធីកំណត់ថ្លៃទំនិញនិងឥរិយាបថរបស់អ្នកលក់និងអ្នកទិញផងដែរ។ | ○ សៀវភៅណែនាំគ្រូ<br>○ សៀវភៅសិស្ស<br>○ ប៉ុស្ទ័រ (ជំនាញទីផ្សារងាយៗ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ ១២ ម៉ោង<br>○ សម្រាប់ថ្នាក់ទី៧ ដោយសារវាជាកម្រិតមូលដ្ឋាន<br>○ គ្រប់រដូវកាល |  |
| | ១២ | អនាគតខ្ញុំ:ប្រធានបទនេះពិភាក្សាអំពីរបៀបដែលសិស្សអាចរៀបចំផែនការអនាគតទៅតាមជម្រើសអាចធ្វើបានសម្រាប់ការងារទៅថ្ងៃអនាគតជាពិសេសសិក្សាអំពីមុខរបរនៅក្នុងសហគមន៍។ សិស្សរៀនអំពីការធ្វើសេចក្តីសំរេចចិត្តដោយផ្អែកទៅលើការគិតគ្រប់ ជ្រុងជ្រោយតាមជម្រើសដែលអាចទៅរួច។ | • ឯកសារគ្រូ<br>• សៀវភៅសិស្ស<br>• ប៉ុស្ទ័រ<br>⇒ *ការប្រថុយប្រថាន* គ្រូអាចបង្រៀនពេញម៉ោង | ○ ២០ ម៉ោង<br>○ សម្រាប់ថ្នាក់ទី ៨ និង៩<br>○ គ្រប់រដូវកាល |  |
| | ១៣ | កាគ្រប់គ្រងប្រាក់:ប្រធានបទនេះជួយសិស្សឱ្យពិនិត្យមើលនូវទម្លាប់ចំណាយរបស់ខ្លួននិងក្រុមគ្រួសារកន្លងមកថាតើការចំណាយណាខ្លះជាតម្រូវការនិងការចំណាយណាខ្លះជាចំណង់។ សិស្សនឹងរៀនរៀបចំផែនការថវិកាវិភាគនិងកត់ត្រាការចំណាយប្រចាំថ្ងៃរបស់ ខ្លួន។ សិស្សនឹងយល់ដឹងពី | ○ សៀវភៅណែនាំគ្រូ<br>○ សៀវភៅសិស្ស<br>○ ប៉ុស្ទ័រ (ចំណង់និងតម្រូវការ)<br>○ ឯកសារក្រុមសិស្ស | ○ ២០ ម៉ោង<br>○ សម្រាប់ថ្នាក់ទី ៨ និង៩<br>○ គ្រប់រដូវកាល | |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | | ពាក្យថាចំណាយនិងចំណូលនិងរបៀបកត់ ត្រាលំហូរថវិកាចំពោះខ្លួនគេផ្ទាល់និងក្រុមគ្រួសារ។ | ○ ឯកសារចែកសិស្ស | |  |
| | ១៤ | ពិភពការងារ:ប្រធានបទនេះផ្តល់ឱ្យសិស្សនូវចំណេះដឹងបំណិននិងបទពិសោធក្នុងការរៀបចំខ្លួនដើម្បីចូលទៅក្នុងពិភពការងារ។ សិស្សនឹងរៀនអំពីរបៀបដាក់ពាក្យសុំធ្វើការងារ (បំពេញពាក្យសុំចូលធ្វើការសរសេរប្រវត្តិរូបសង្ខេប) ព្រមទាំងរបៀបរៀបចំឥរិយាបថនៅកន្លែងធ្វើការងារ (ឧ. របៀបដោះស្រាយជម្លោះនៅកន្លែងធ្វើការ)។ មេរៀននេះផ្តល់ឱ្យសិស្សនូវបញ្ជីមុខរបរផ្សេងៗជាច្រើន ក្នុងការពិចារណាផែនការការងារទៅថ្ងៃអនាគត។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ចរិតលក្ខណៈអ្នកធ្វើការ/ប្រភេទការងារ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ សៀវភៅវចនានុក្រមមុខរបរ (ស៊ីប៉ា) | ○ ២០ ម៉ោង<br>○ សម្រាប់ថ្នាក់ទី៨ និង៩<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ១៥ | សហគ្រាសសង្គម និងកុមារៈប្រធានបទនេះផ្ដល់ឱ្យសិស្សពីរបៀបបង្កើតសហគ្រាសខ្នាតតូចក្នុងក្រុមមួយសិស្សនឹងពិនិត្យមើល នូវជម្រើសផ្សេងៗក្នុងក្រុមរបស់ពួកគេ ក្នុងការបង្កើតសហគ្រាសនៅខាងក្រៅសាលារៀនដើម្បីរកប្រាក់ចំណូល។ សិស្សនឹងរៀនពីរបៀបចាត់ចែងផែនការជំនួញនិងវិធីធ្វើការឱ្យមានប្រសិទ្ធភាព (ការចែករំលែកការទទួលខុសត្រូវបែងចែកកម្លាំងពលកម្ម និងគោលការណ៍ភាពជាអ្នកដឹកនាំសម្រាប់កុមារ)។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (សិទ្ធិកុមារ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ប្រធានភូមិ | ○ ២០ ម៉ោង<br>○ សម្រាប់ថ្នាក់ទី៨ និង៩<br>○ គ្រប់រដូវកាល |  |
| | ១៦ | ការសន្សំ និងការចំណាយៈប្រធានបទនេះ ពិភាក្សាអំពីបរិបទនៃការសន្សំនិងការចំណាយរួមមានគំនិតនៃការសន្សំមិនមែនសំដៅទៅលើតែលុយប៉ុណ្ណោះនោះទេ មានទាំងសម្ភារៈផ្សេងៗក្រៅពីលុយ ផងដែរដូចជាពេលវេលាធនធានមនុស្សមិត្តភាព។ សិស្សនឹងសិក្សាថាហេតុអ្វីបានជាយើងត្រូវសន្សំ វាព្រមទាំងផលប្រយោជន៍ នៃយុទ្ធសាស្ត្រផ្សេងៗគ្នា ក្នុងការសន្សំ (ឧ.ផ្ញើលុយនៅធនាគារទិញមាស ទុកទិញគោបង្កើតក្រុមសន្សំ )។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ការសន្សំនិងការចំណាយ/រូបិយវត្ថុកម្ពុជ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ បុគ្គលិកធនាគារ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ១៧ | បច្ចេកវិទ្យាសារគមនាគមន៍ៈប្រធានបទនេះផ្ដល់ឱ្យសិស្សនូវ | ○ សៀវភៅណែនាំគ្រូ<br>○ សៀវភៅសិស្ស | ○ ២០ ម៉ោង<br>○ ត្រូវមានបន្ទប់កុំព្យូទ័រ | |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | | ការប្រើប្រាស់កុំព្យូទ័រ រួមមានមូលដ្ឋានថែទាំការប្រើប្រាស់ក្តារចុចកម្មវិធីណែនាំដោយក្រសួងអប់រំយុវជននិងកីឡាខ្មែរនិងកម្មវិធីវិភាគ ទិន្នន័យ។ | ○ ប៉ូស្ទ័រ (ម្រាមដៃ/ក្តារចុច/យូនីកូដខ្មែរ/កណ្តុរ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ | ○ គ្រប់កម្រិត (អាទិភាពថ្នាក់ទី ១០-១២)<br>○ គោលនយោបាយក្រសួងអយក |  |
| ប្រភេទទី ៣: បំណិនអាជីពងាយ | ១៨ | ការដាំស្រូវៈប្រធានបទនេះជួយសិស្សឱ្យយល់ដឹងពីវដ្តនៃដំណាំស្រូវការរៀបចំដីសម្រាប់ដាំស្រូវដំណាក់លាកលូតលាស់របស់ស្រូវសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតបំផ្លាញស្រូវការវិភាគបរិស្ថានក្បេតសាស្ត្រ។ បន្ថែមពីនេះទៀតសិស្សរៀនអំពីរបៀបធ្វើជីកំប៉ុស្តនិងវិធីប្រើប្រាស់ឱ្យមានប្រសិទ្ធភាព។ សិស្សសិក្សាទ្រឹស្តីនៅក្នុងថ្នាក់ រៀនដោយផ្សារភ្ជាប់ជាមួយវាលស្រែនិងការធ្វើបទបង្ហាញលទ្ធផលដល់សហគមន៍ក្នុងការធ្វើឱ្យកាន់តែប្រសើរនូវវិធីដាំស្រូវដែលឆ្លងតាមការពិសោធន៍ផ្ទាល់។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (លំនាំធ្វើស្រែ/ប្រភេទសត្វល្អិត)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ វាលស្រែពូជស្រូវសម្ភារកសិកម្ម | ○ ២០ម៉ោង<br>○ គ្រប់កម្រិត<br>○ រដូវខែតុលា ដល់ខែមករា ប្រសិនបើមានទឹកគ្រប់គ្រាន់អាចធ្វើគ្រប់រដូវ |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ១៩ | ការដាំបន្លែៈប្រធានបទនេះផ្ដល់ឱ្យសិស្សនូវទិដ្ឋភាពរួមនៃប្រភេទបន្លែផ្សេងៗដែលមាននៅក្នុងប្រទេសកម្ពុជាជម្ងឺទូទៅរបស់ បន្លែនិងប្រភេទសត្វល្អិតបំផ្លាញបន្លែព្រមទាំងវិធីរៀបចំដីក្នុងការដាំបន្លែ។ ការសិក្សាទ្រឹស្ដីនៅក្នុងថ្នាក់រៀនដោយផ្សារភ្ជាប់ការអនុវត្តជាមួយសួនបន្លែនិងការធ្វើបទបង្ហាញលទ្ធផលដល់សហគមន៍ក្នុងការធ្វើឱ្យកាន់តែប្រសើរនូវវិធីដាំបន្លែដែលឆ្លងតាមការពិសោធន៍ ផ្ទាល់។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ជម្ងឺលើដំណាំ/ប្រភេទបន្លែ/ដំណាំសណ្ដែកទ្រើង)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ សួនបន្លែគ្រាប់ពូជសម្ភារសាងសង់សួន។ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ តាមរដូវកាល<br>○ រដូវខែតុលាដល់ខែមករា |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២០ | ការចិញ្ចឹមត្រី: ប្រធានបទនេះផ្តល់ឱ្យសិស្សនូវការយល់ដឹងពីប្រភេទត្រីទឹកសាបនៅក្នុងប្រទេសកម្ពុជា។ សិស្សរៀនពីរបៀបជ្រើសរើសទីតាំងជីករណ្តៅចិញ្ចឹមត្រី ព្រមទាំងដំណាក់កាលផ្សេងៗក្នុងការ ចិញ្ចឹមត្រី (ការជីករណ្តៅរបៀបក្រាលកម្រាលកៅស៊ូ)។ មេរៀននេះនឹងផ្តល់នូវវិធីទប់ស្កាត់ជម្ងឺត្រី វិធីផ្តល់ចំណីដល់ត្រីនិងតាមដានការលូតលាស់របស់ត្រី។ បន្ថែមពីនេះទៀតសិស្សនឹងសិក្សាពីការវិភាគសេដ្ឋកិច្ចទៅលើការចិញ្ចឹមត្រីដើម្បីឱ្យសិស្សយល់ដឹងពីផលចំណេញនៃការចិញ្ចឹមត្រីនេះ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (លំនាំចិញ្ចឹមត្រី/ប្រភេទត្រីទឹកសាប)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ រណ្តៅចិញ្ចឹមត្រីចង់កៅស៊ូ កូនត្រីចំណីនិងដើមរុក្ខជាតិ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២១ | ការចិញ្ចឹមកង្កែបៈប្រធានបទនេះផ្តល់ឱ្យសិស្សនូវការយល់ដឹងពីប្រភេទកង្កែបនៅក្នុងប្រទេសកម្ពុជា។ សិស្សរៀនពីរបៀបជ្រើសរើសទីតាំងជីករណ្តៅចិញ្ចឹមកង្កែប ព្រមទាំងដំណាក់កាលផ្សេងៗក្នុង ការចិញ្ចឹម (ការជីករណ្តៅរបៀបក្រាលកម្រាលកៅស៊ូ)។ មេរៀននេះនឹងផ្តល់នូវវិធីទប់ស្កាត់ជម្ងឺវិធីផ្តល់ចំណីនិងតាមដានការលូតលាស់ របស់កង្កែប។ បន្ថែមពីនេះទៀតសិស្សនឹងសិក្សាពីការវិភាគសេដ្ឋកិច្ច ទៅលើការចិញ្ចឹមកង្កែបដើម្បីឱ្យសិស្សយល់ដឹងពីផលចំណេញនៃការចិញ្ចឹមនេះ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (លំនាំចិញ្ចឹមកង្កែប/វដ្តជីវិតសត្វកង្កែប)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ រណ្តៅចិញ្ចឹមកង្កែបចង់កៅស៊ូកូនកង្កែបចំណីដើមរុក្ខជាតិនិងអំពូលភ្លើងទាក់សត្វល្អិត | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ២២ | សួនជីវៈចំរុះ៖ សិស្សនឹងសិក្សាពីវិធីសាងសង់សួនរបៀបដាំដុះរុក្ខជាតិស្គាល់ប្រភេទរុក្ខជាតិវិធីបណ្តុះដោយគ្រាប់ វិធីកាត់ដើមដាំវិធីតដើមវិធីសាកមែកនិងបច្ចេកទេសថែទាំរុក្ខជាតិដើម្បីធានាថាសាលារៀននឹងមានរុក្ខជាតិដាំនៅក្នុងបរិវេណសាលារៀនគ្រប់គ្រាន់។ បន្ថែមពីនេះទៀតសិស្សនឹងរៀនពីវិធីធ្វើជីកំប៉ុស្តដើម្បីទុកប្រើប្រាស់ នៅក្នុងសួនជីវៈចម្រុះនេះ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ការបណ្តុះស្រូវ/ ការបណ្តុះរុក្ខជាតិ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ សម្ភារសាងសង់រុក្ខជាតិទឹកអ័រម៉ូន ជីកំប៉ុស្តចង់បណ្តុះកាំបិត | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២៣ | ការបណ្តុះផ្សិតៈ សិស្សនឹងរៀនពីការកំណត់រដូវក្នុងការបណ្តុះផ្សិតនិងការជ្រើសរើសទីកន្លែងសមស្រប។ យល់ដឹងពីលំនាំក្នុងការបណ្តុះផ្សិតនិងវិធីរៀបចំរងបណ្តុះផ្សិតដើម្បីងាយស្រួលប្រមូល ផល។ ក្រោយពីប្រមូលផលសិស្សនឹងសិក្សាពីការវិភាគសេដ្ឋកិច្ច ដើម្បីចេះគណនារកប្រាក់ខាតនិងចំណេញពីការបណ្តុះផ្សិតនេះ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ការបណ្តុះផ្សិត)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ សម្ភារៈសាងសង់សួនម្សៅផ្សិតចំបើងថង់គ្រប | ○ ២០ ម៉ោង<br>○ គ្រប់កម្រិត<br>○ ខែតុលាដល់មករា |  |
| | ២៤ | ការចិញ្ចឹមមាន់ៈ សិស្សយល់ដឹងពីការជ្រើសរើសទីកន្លែងចិញ្ចឹមរបៀបសាងសង់ទ្រុងមាន់ វិធីថែទាំវិធីផលិតចំណីនិងការយល់ដឹងពីប្រភេទជម្ងឺរបស់មាន់និងការចាក់ថ្នាំបង្ការដល់មាន់។ ផ្នែកផ្សេងទៀតសិស្សនឹងសិក្សាពីដំណាក់កាលធំធាត់របស់មាន់ និងរបៀបជ្រើសរើសពូជមាន់សម្រាប់ចិញ្ចឹមបន្ត។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (លំនាំចិញ្ចឹមមាន់/វដ្តជីវិតសត្វមាន់)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ សម្ភារៈសាងសង់ទ្រុងមាន់ ចំណីមាន់ និងកូនមាន់ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២៥ | ការជួសជុលកង់: សិស្សនឹងរៀនពីឈ្មោះផ្នែកផ្សេងៗរបស់កង់ និងមុខងារនីមួយៗរបស់វា ព្រមទាំងស្គាល់ពីឧបករណ៍ផ្សេងៗសម្រាប់ ប្រើក្នុងការជួសជុលកង់។ តាមរយៈការអនុវត្តផ្ទាល់ សិស្សនឹងអាចតម្លើងកង់បានត្រឹមត្រូវនិងចេះវិធីប៉ះកង់។ បន្ថែមពីនេះទៀតសិស្សនឹងចេះពីរបៀបទុកដាក់កង់ និងវិធីថែទាំកង់ឱ្យបានល្អ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ឧបករណ៍ជាងជួសជុលកង់/តូកង់)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ កង់ ឧបករណ៍ជួសជុលជាងជួសជុលកង់ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ២៦ | ការកាត់សក់: សិស្សនឹងរៀនស្គាល់នូវសម្ភាររបស់ជាងកាត់សក់ វិធីប្រើប្រាស់ និងការថែទាំ។ សិស្សនឹងអនុវត្តការកាត់សក់ ដោយរៀបប្រើប្រាស់កន្ត្រៃក្រាសសិតសក់ របៀបរុំក្រណាត់ វិធីកោរសំអាតនិងរៀបចំឥរិយាបថក្នុងការទំនាក់ទំនងជាមួយភ្ញៀវ។ តាមរយៈការអនុវត្តផ្ទាល់ សិស្សនឹងយល់ដឹងពីម៉ូតសក់ វិធីថែទាំសក់ និងវិធីលាបសក់។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (សម្ភារជាងកាត់សក់)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឧបករណ៍ជាងកាត់សក់ កន្ត្រៃក្រាសកញ្ចក់... | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២៧ | ជាងកំបោរៈ សិស្សរៀនពីរបៀបវាស់និងប្រើប្រាស់ កូនប្រយោលរៀនស្គាល់ឈ្មោះឧបករណ៍ប្រើប្រាស់របស់ជាងកំបោរនិងវិធីប្រើ ឧបករណ៍ទាំងនេះ។ សិស្សរៀនពីរបៀបលាយបាយអរវិធីរៀបជញ្ជាំងដោយប្រើប្រាស់ឥដ្ឋ១០ និងឥដ្ឋ ២០ ដោយអនុវត្តផ្ទាល់ការរៀបសួនច្បារក្នុងសាលារៀននិងវិធីថែទាំជញ្ជាំងនៅពេលរៀបហើយ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ឧបករណ៍ជាងកំបោរ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឧបករណ៍ជាងកំបោរ ឥដ្ឋ ស៊ីម៉ង់ទឹកនិងជាង កំបោរសហគមន៍ | ○ ២០ ម៉ោង<br>○ សម្រាប់ថ្នាក់ទី ៨ និង៩<br>○ គ្រប់រដូវកាល |  |
| | ២៨ | ការដាំស្លៈ សិស្សនឹងរៀនពីរបៀបចំអិនម្ហូបគ្រឿងផ្សំរូបមន្តធ្វើម្ហូបនិងធ្វើផែនការទិញសម្ភារធ្វើម្ហូបព្រមទាំងការស្រាវជ្រាវពីប្រភេទម្ហូបនៅក្នុងសហគមន៍ ហើយធ្វើបទបង្ហាញដល់ក្រុមសិស្សក្នុងថ្នាក់។ សិស្សសិក្សាពីរបៀបរៀបចំកន្លែងធ្វើម្ហូប ការបង្ការគ្រោះថ្នាក់ ផ្សេងៗ និងយល់ដឹងពីប្រភេទអាហារមូលដ្ឋានសម្រាប់ទ្រទ្រង់រាងកាយ។ នៅមេរៀនចុងក្រោយ សិស្សនឹងអនុវត្តការធ្វើម្ហូបតាមក្រុម នីមួយៗ ដូចជាម្ហូបប្រភេទស្ងោរឆា ចៀន ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ដល់ពេលចម្អិនឬ? / ពីរ៉ាមីតអាហារ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឧបករណ៍ដាំស្លរគ្រឿងផ្សំ ចង្រ្កានថាមពលចុងភៅសហគមន៍ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |

| ប្រភេទបំណិនជីវិត | ល.រ | ប្រធានបទ | ធនធាន | កំណត់សម្គាល់ | រូបភាព |
|---|---|---|---|---|---|
| | ២៩ | វិជ្ជាដេរប៉ាក់:សិស្សនឹងរៀនស្គាល់នូវសម្ភាររបស់ជាងកាត់ដេរពីរបៀបដេរអាវដៃខ្លីដោយប្រើប្រាស់ថ្មេដៃ ប្រភេទផ្សេងៗរបស់ថ្មេរ ដៃវិធីវាស់ ស្នា ក សម្រុងរបៀបកាត់ពុម្ព វិធីភ្ជាប់ផ្នែកផ្សេងៗដើម្បី បានជាអាវមួយ។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (សម្ភារជាងកាត់ដេរ)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ឧបករណ៍ជាងកាត់ដេរម្មូលក្រណាត់ អំបោះគ្រូជំនាញដេរប៉ាក់ | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ គ្រប់រដូវកាល |  |
| | ៣០ | ដំណាប់ផ្លែឈើ:ប្រធានបទនេះសិស្សនឹងសិក្សាពីវិធីកែច្នៃផ្លែមើមរុក្ខជាតិដើម្បីទុកហូបបានរយៈពេលយូរ។ សិស្សនឹងយល់ដឹងពី អនាម័យក្នុងការរៀបចំ ឧបករណ៍ និងសម្ភារៈត្រូវប្រើប្រាស់គ្រឿងផ្សំ លំនាំធ្វើដំណាប់ផ្សេងៗ ដូចជាដំណាប់ផ្លែស្វាយចេកដូងល្ពង។ បន្ថែមពីនេះទៀតសិស្សរៀនពីវិធីថែទាំសំអាត ឧបករណ៍និងសម្ភារៈ ដែលបានប្រើប្រាស់រួច។ | ○ សៀវភៅណែនាំគ្រូ<br>○ ប៉ូស្ទ័រ (ផ្លែឈើនៅកម្ពុជា)<br>○ ឯកសារក្រុមសិស្ស<br>○ ឯកសារចែកសិស្ស<br>○ ប្រាក់ម៉ោងបន្ថែមរបស់គ្រូ<br>○ ផ្លែឈើចង្រ្កានកាំបិត ចាន … | ○ ២០ ម៉ោង<br>○ សម្រាប់គ្រប់កម្រិត<br>○ តាមរដូវកាលអាស្រ័យលើបន្លែដែលជ្រើសរើស |  |

# ឧបសម្ព័ន្ធទី ៦: ទម្រង់របាយការណ៍ត្រួតពិនិត្យ និងតាមដាន

## ទម្រង់ ឈ៖ សហគមន៍ និងសាលាទទួលយកការទទួលខុសត្រូវ

គណៈកម្មការទ្រទ្រង់សាលា (SSC) បានប្តេជ្ញាចិត្តដើម្បីគ្រប់គ្រងនូវដំណើរការកែលម្អថវិកាសាលារៀននិងដើម្បី ធានានូវការរីកចម្រើនរបាយការណ៍លើការចំណាយថវិកាសាលារៀនតាមរយៈសាលារៀន។

SSC នឹង៖

១. រៀបចំរបាយការណ៍ត្រួតពិនិត្យតាមដានដំណើរការចំណាយ (ទម្រង់ ខ) សម្រាប់ការចំណាយថវិកាសាលារៀន ។
ប្រចាំឆ្នាំ និងចែកចាយផែនការត្រួតពិនិត្យតាមដានទៅដល់មន្ត្រីអប់រំស្រុកនៅថ្ងៃទី ៣១ខែតុលារៀងរាល់ឆ្នាំ។

២. ផ្តល់របាយការណ៍ហរិញ្ញវត្ថុប្រចាំខែ (MFR) បញ្ចប់ និងត្រឹមត្រូវទៅមន្ត្រីអប់រំស្រុកនៅថ្ងៃទី ១៥រៀងរាល់ខែ (ថ្ងៃទី ១៥ខែមករា មេសា កក្កដា និងតុលា)។
៣. យកចិត្តទុកលើប្រធានការិយាល័យអប់រំស្រុក និងមន្ត្រីអប់រំស្រុករាល់បញ្ហាដែលបានលើកឡើងជាមួយនឹងដំណើរការកម្មវិធីនេះ។

| ______________ | ______________ | ________ |
|---|---|---|
| ឈ្មោះនាយកសាលា | ហត្ថលេខា | កាលបរិច្ឆេទ |
| ______________ | ______________ | ________ |
| ឈ្មោះនាយករង | ហត្ថលេខា | កាលបរិច្ឆេទ |
| ______________ | ______________ | ________ |
| ឈ្មោះអ្នកតំណាងគ្រូ | ហត្ថលេខា | កាលបរិច្ឆេទ |
| ______________ | ______________ | ________ |
| ឈ្មោះអ្នកតំណាងសហគមន៍ | (ប្រធាន SCC)ហត្ថលេខា | កាលបរិច្ឆេទ |

***ឯកភាពដោយ:***

| ______________ | ______________ | ________ |
|---|---|---|
| ឈ្មោះអ្នកគ្រប់គ្រង<br>មន្ត្រីអប់រំស្រុក | ហត្ថលេខា | កាលបរិច្ឆេទ |

***មូលវិចារដោយមន្ត្រីអប់រំស្រុក និងអនុម័តដោយ:***

| ______________ | ______________ | ________ |
|---|---|---|
| ឈ្មោះអ្នកគ្រប់គ្រង<br>មន្ត្រីអប់រំស្រុក | ហត្ថលេខា | កាលបរិច្ឆេទ |

**អនុម័តសរុបលើថវិកាមូលនិធិប្រចាំឆ្នាំ:** $___________

(មើលការពណ៌នាផែនការ សំណើរសុំ និងសកម្មភាពជាក់លាក់ ថវិកា និងផែនការសម្រាប់ការចំណាយរាល់សកម្មភាព)

i.

# ឧបសម្ព័ន្ធ ៣៖ របាយការណ៍ត្រួតពិនិត្យសាលារៀន

ii. ក្រដាសសង្ខេប

ឈ្មោះសាលា: ........................................... កាលបរិច្ឆេទ: ..............

ស្រុក/ខេត្ត: ................................................

ឈ្មោះអ្នកគ្រប់គ្រង/តួនាទី: ...............................................................

| | | | ការពណ៌នាចំនួន | | | | |
|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ៥ |
| ១. ភាពជាអ្នកដឹកនាំ | | | | | | | |
| ២. ការគ្រប់គ្រង | | | | | | | |
| ៣. បរិស្ថានសិក្សា | | | | | | | |
| ៤. ទំនាក់ទំនងរវាងសាលា និងសហគមន៍ | | | | | | | |
| ៥. ការចូលរួមរបស់មាតាបិតាសិស្ស | | | | | | | |
| ៦. ការចូលរួមរបស់កុមារី | | | | | | | |
| ៧. បណ្ណាល័យ | | | | | | | |
| ៨. ការបង្រៀន និងការរៀន | ថ្នាក់រៀន | ការតាំងបង្ហាញ | | | | | |
| | | អនាម័យ | | | | | |
| | | សម្ភារ | | | | | |
| | | សៀវភៅសិក្សា | | | | | |
| | | ការរៀបចំថ្នាក់រៀន | | | | | |
| | | បញ្ជីស្រង់វត្តមាន | | | | | |
| | ការបង្រៀន | វត្ថុបំណងមេរៀន | | | | | |
| | | កិច្ចតែងការបង្រៀន | | | | | |
| | | សិស្សរៀនយឺត | | | | | |
| | | សម្ភារបង្រៀន ( គ្រូប្រើប្រាស់ ) | | | | | |
| | | លំហាត់ធ្វើក្នុងថ្នាក់ | | | | | |
| | | សំណួររបស់គ្រូ | | | | | |
| | | ការរំពឹងទុក/ចំណាប់អារម្មណ៍ | | | | | |
| | ៣ | សម្ភារសិក្សា ( សិស្សប្រើប្រាស់ ) | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ការងារក្រុម | | | | | |
| | | សំណួររបស់សិស្ស | | | | | |
| | | ការចូលរួម | | | | | |
| | | ការផ្តល់ព័ត៌មានត្រឡប់ទៀងទាត់អំឡុងម៉ោងសិក្សា | | | | | |
| | | សៀវភៅសរសេររបស់សិស្ស | | | | | |
| | | លំហាត់ធ្វើនៅផ្ទះ | | | | | |

# *របាយការណ៍ត្រួតពិនិត្យតាមដានសាលារៀន*

**ឈ្មោះសាលាៈ**.............................................................. **កាលបរិច្ឆេទៈ** .........................

**ស្រុក/ខេត្តៈ** ........................................................

**ឈ្មោះអ្នកគ្រប់គ្រង/តួនាទីៈ** ..............................................................................

**១. ភាពជាអ្នកដឹកនាំ**

| |
|---|
| ☐ ៥. អ្នកគ្រប់គ្រងលើកទឹកចិត្តបុគ្គលិកដើម្បីផ្តួចផ្តើមគំនិត និងអបអរចំពោះភាពជោគជ័យរបស់ពួកគេ។ |
| ☐ ៤. អ្នកគ្រប់គ្រងចូលរួមជាមួយបុគ្គលិកនៅក្នុងការកែលម្អផែនការ និងការផ្តួចផ្តើមគំនិត។ |
| ☐ ៣. អ្នកគ្រប់គ្រងផ្តួចផ្តើមគំនិត និងចូលរួមជាមួយបុគ្គលិកនៅក្នុងការពិភាក្សា។ |
| ☐ ២. អ្នកគ្រប់គ្រងផ្តួចផ្តើមគំនិតខ្លះៗ ប៉ុន្តែបុគ្គលិកគ្មានការឆ្លើយតប។ |
| ☐ ១. អ្នកគ្រប់គ្រងរង់ចាំសេចក្តីណែនាំ។ |

**២. ការគ្រប់គ្រង**

| |
|---|
| ☐ ៥. អ្នកគ្រប់គ្រង និងបុគ្គលិកប្រើបញ្ជីស្រង់វត្តមានជាគោលសម្រាប់ការធ្វើផែនការ។ |
| ☐ ៤. អ្នកគ្រប់គ្រង និងបុគ្គលិកអាចធ្វើមូលវិចារលើបញ្ជីនោះបាន។ |
| ☐ ៣. បញ្ជីស្រង់វត្តមានបានប្រើភ្លាមៗ។ អ្នកគ្រប់គ្រងមិនអាចធ្វើមូលវិចារលើបញ្ជីនោះបានទេ។ |
| ☐ ២. សាលាមានបញ្ជីស្រង់វត្តមានប៉ុន្តែពួកគេមិនអាចប្រើវាភ្លាមៗនោះទេ។ |
| ☐ ១. សាលាគ្មានបញ្ជីស្រង់វត្តមាន (កត្តាចង្អុលបង្ហាញហរិញ្ញវត្ថុ និងការបំពេញការងារ)។ |

**៣. បរិស្ថានសិក្សា**

| |
|---|
| ☐ ៥. បង្គន់បើកទ្វារ និងមានអនាម័យស្អាត។ <u>ហើយ</u>មានទឹកសម្រាប់លាងដៃ។ <u>ហើយ</u>ទីធ្លាសាលាគ្មានសម្រាមទេ។ នេះជាលទ្ធផលដ៏មានប្រសិទ្ធិភាពនៃតំហែទាំ ត្រួតពិនិត្យតាមដាន និងអប់រំអំពីសុខភាព និងបរិស្ថានសិក្សាស្អាត។ |
| ☐ ៤. បង្គន់បើកទ្វារ និងមានអនាម័យស្អាត។ <u>ហើយ</u>មានទឹកសម្រាប់លាងដៃ។ <u>ហើយ</u>ទីធ្លាសាលាគ្មានសម្រាមទេ។ ទាំងនេះជាប្រព័ន្ធតំហែទាំ និងត្រួតពិនិត្យតាមដានសុខភាព និងបរិស្ថានសិក្សាស្អាត។ |
| ☐ ៣. បង្គន់បើកទ្វារ និងមានអនាម័យស្អាត។ <u>ហើយ</u>មានទឹកសម្រាប់លាងដៃ។ <u>ហើយ</u>ទីធ្លាសាលាគ្មានសម្រាមទេ។ ទាំងនេះជាប្រព័ន្ធតំហែទាំសុខភាព និងបរិស្ថានសិក្សាស្អាត។ |
| ☐ ២. បង្គន់បើកទ្វារ និងមានអនាម័យស្អាត។ <u>ហើយ</u>មានទឹកសម្រាប់លាងដៃ។ <u>ហើយ</u>ទីធ្លាសាលាគ្មានសម្រាមទេ។ |
| ☐ ១. សាលាគ្មានបង្គន់។ <u>ឬ</u> បង្គន់ចាក់សោរ។ <u>ឬ</u> បង្គន់មានអនាម័យ។ <u>ឬ</u> សិស្សគ្មានទឹកសម្រាប់លាងដៃ។ <u>ឬ</u>ទីធ្លាសាលាមានសម្រាម។ |

**៤. ទំនាក់ទំនងរវាងសាលា និងសហគមន៍**

| |
|---|
| ☐ ៥. ការចូលរួមរបស់សហគមន៍នៅរាល់ទិដ្ឋភាពនៃជីវិតនៅសាលារៀនៈ ការគ្រប់គ្រង ផែនការ សកម្មភាពសាលា ការបង្រៀន និងការរៀន។ |
| ☐ ៤. សមាជិកសហគមន៍ធ្វើទស្សនៈកិច្ចសាលារៀនញឹកញាប់។ សហគមន៍បានចូលរួមនៅក្នុងដំណើរការសកម្មភាពខ្លះៗរបស់សាលារៀន។ |
| ☐ ៣. សមាជិកសហគមន៍បានចូលរួមប្រជុំខ្លះៗនៅសាលារៀន។ |
| ☐ ២. សហគមន៍ផ្តល់ជំនួយថវិកាមួយចំនួនដល់សាលារៀន និងឧបត្ថម្ភគម្រោងសាងសង់អគារនៅសាលារៀន។ |
| ☐ ១. សហគមន៍មានការចូលរួមតិចតួចនៅក្នុងសាលា។ |

**៥. ការចូលរួមរបស់មាតាបិតាសិស្ស និងសិស្សានុសិស្ស**

| |
|---|
| ☐ ៥. សាលាបានអញ្ជើញមាតាបិតាសិស្សជាផ្លូវការដើម្បីពិភាក្សាការរីកចំរើនរបស់សិស្ស។ |
| ☐ ៤. សាលាបានផ្តួចផ្តើមគំនិតការចូលរួមរបស់មាតាបិតានៅពេលចាំបាច់។ |
| ☐ ៣. នេះជាភស្តុតាងមួយចំនួនចំពោះការចូលរួមរបស់មាតាបិតាសិស្សនៅក្នុងកិច្ចការសាលារៀន។ |
| ☐ ២. សាលាមានការប្រជុំប្រចាំឆ្នាំ ឬសកម្មភាពដែលលើកទឹកចិត្តការចូលរួមរបស់មាតាបិតាសិស្ស។ |
| ☐ ១. សាលាគ្មានសកម្មភាពពិសេសដើម្បីផ្សព្វផ្សាយការចូលរួមរបស់មាតាបិតាសិស្សទេ។ |

**៦. ការចូលរួមរបស់កុមារី**

| |
|---|
| ☐ ៥. សាលាមានវិធីសាស្រ្ត និងសកម្មភាពដើម្បីផ្សព្វផ្សាយការចូលរួមរបស់កុមារី ទាំងនេះជាភស្តុតាង និងការវាយតម្លៃ។ |
| ☐ ៤. សាលាប្រើសកម្មភាពផ្សេងៗដើម្បីផ្សព្វផ្សាយការចូលរួមរបស់កុមារី។ |
| ☐ ៣. សាលាគ្មានសកម្មភាពពិសេសដើម្បីផ្សព្វផ្សាយការចូលរួមរបស់កុមារី។ |
| ☐ ២. សាលាមានផែនការដើម្បីបង្កើនការចូលរួមរបស់កុមារី។ |
| ☐ ១. សាលាគ្មានសកម្មភាពពិសេសដើម្បីផ្សព្វផ្សាយការចូលរួមរបស់កុមារីទេ។ |

**៧. បណ្ណាល័យ**

| |
|---|
| ☐ ៥. បណ្ណាល័យត្រូវបានប្រើប្រាស់ល្អ និងមានការថែទាំល្អ។ សាលាមានផែនការអភិវឌ្ឍន៍បណ្ណាល័យ។ |
| ☐ ៤. បណ្ណាល័យត្រូវបានប្រើប្រាស់អំឡុងម៉ោងសិក្សាសម្រាប់សកម្មភាពសិក្សាផ្សេងៗ។ |
| ☐ ៣. នេះជាបណ្ណាល័យ និងនេះជាភ័ស្តុតាងដែលត្រូវបានប្រើប្រាស់អំឡុងម៉ោងសិក្សា។ |
| ☐ ២. នេះជាបណ្ណាល័យប៉ុន្តែគ្មានភ័ស្តុតាងបញ្ជាក់ថាវាត្រូវបានប្រើប្រាស់អំឡុងម៉ោងសិក្សាទេ។ |
| ☐ ១. គ្មានបណ្ណាល័យ ឬទ្វារបណ្ណាល័យចាក់សោរ។ |

## ៨. ការបង្រៀន និងការរៀន

| ១. ការរៀបចំថ្នាក់រៀន | |
|---|---|
| *វិធានសំខាន់ៗ* | **ការពិពណ៌នា** |
| **ការតាំងបង្ហាញ** | ☐ ៥. ទាំងនេះជាការតាំងបង្ហាញការសិក្សានៅលើជញ្ជាំង។ ការងាររបស់សិស្សគឺបានតាំងបង្ហាញនៅលើជញ្ជាំងដែលមានការរៀបចំបានល្អ និងមានភាពទាក់ទាញ។<br>☐ ៤. មានការតាំងបង្ហាញការសិក្សារនៅលើជញ្ជាំង។ ការងារមួយចំនួនរបស់សិស្សមាននៅលើជញ្ជាំង។<br>☐ ៣. មានរូបភាព និងប៉ូស្ទ័រមួយចំនួននៅលើជញ្ជាំង។ គ្មានការងាររបស់សិស្សនៅលើជញ្ជាំងទេ។<br>☐ ២. មានរូបភាព ២ ទៅ ៣នៅលើជញ្ជាំង។<br>☐ ១. គ្មានការតុបតែងថ្នាក់រៀនទេ។ |
| **អនាម័យ** | ☐ ៥. ថ្នាក់រៀនមានការរៀបចំបានល្អ។ វាមានអនាម័យស្អាតៈ គ្មានធូលី សម្រាម ឬនំចំណីទេ។ តុកៅអីមានអនាម័យល្អ។<br>☐ ៤. តុសម្អាតបានស្អាត និងមានកន្លែងអង្គុយ។ កម្រាលឥដ្ឋសំអាតបានស្អាត។<br>☐ ៣. កម្រាលឥដ្ឋស្អាត ហើយតុភាគច្រើនស្អាត។ តុគ្មានកន្លែងអង្គុយទេ។<br>☐ ២. មានសម្រាម និងចំណីអាហារខ្លះៗលើកម្រាលឥដ្ឋ។ តុភាគច្រើនមិនស្អាត។<br>☐ ១. មានសម្រាម និងចំណីអាហារនៅក្នុងថ្នាក់រៀននិងលើតុ។ |
| **សម្ភារ** | ☐ ៥. សិស្សទាំងអស់មានក្រដាសនិងខ្មៅដៃ/ប៊ិច។<br>☐ ៤. សិស្សភាគច្រើនមានក្រដាស និងខ្មៅដៃ។<br>☐ ៣. សិស្សជាងពាក់កណ្តាលមានក្រដាស និងខ្មៅដៃ។<br>☐ ២. សិស្សតិចជាងពាក់កណ្តាលមានក្រដាស និងខ្មៅដៃ។<br>☐ ១. សិស្សតែ ២ ទៅ ៣នាក់ប៉ុណ្ណោះដែលមានក្រដាស និងខ្មៅដៃ។ |
| **សៀវភៅសិក្សា** | ☐ ៥. សិស្សទាំងអស់មានសៀវភៅសិក្សាផ្ទាល់ខ្លួន។<br>☐ ៤. សិស្សភាគច្រើនមានសៀវភៅសិក្សាផ្ទាល់ខ្លួន។ សិស្សមួយចំនួនបានចែករំលែក សៀវភៅសិក្សាជាមួយដៃគូររបស់គេ។<br>☐ ៣. សិស្សមួយចំនួនមានសៀវភៅសិក្សាផ្ទាល់ខ្លួនរបស់គេ។ សិស្សភាគច្រើនបានចែករំលែកសៀវភៅសិក្សានៅក្នុងក្រុម ២ ឬ៣។<br>☐ ២. សិស្សទាំងអស់បានចែករំលែកសៀវភៅសិក្សានៅក្នុងក្រុម ២ ឬ ៣។ សិស្សមួយចំនួនគ្មានសៀវភៅសិក្សានោះទេ។<br>☐ ១. សិស្សភាគច្រើនគ្មានសៀវភៅសិក្សាផ្ទាល់ខ្លួន ឬចែកពីអ្នកដទៃទេ។ |
| | ☐ ៥. តុមានការរៀបចំបានល្អដើម្បីគាំទ្រដល់ការសិក្សារបស់សិស្ស។ តុស្អាត និងមិនរាយប៉ាយ។ |

| | |
|---|---|
| **ការរៀបចំតុកៅអី** | ☐ ៤. តុមានការរៀបចំបានល្អ។ តុភាគច្រើនមិនរាយប៉ាយ។ ថ្នាក់រៀនមិនបានប្រើជាបន្ទប់ ស្តុកអីវ៉ាន់ទេ។<br>☐ ៣. តុរៀបមានការរៀបចំប៉ុន្តែមិនបានល្អ។ តុភាគច្រើនមិនរាយប៉ាយ។ សម្ភារមួយចំនួនទុកនៅក្នុងថ្នាក់រៀន ដូចជាតុមិនបានប្រើប្រាស់។<br>☐ ២. គ្រូមិនប្រើកន្លែទំនេរដើម្បីរៀបចំតុសិស្សទេ។ សម្ភារមួយចំនួនបានទុកនៅក្នុងថ្នាក់រៀន។ តុភាគច្រើនរាយប៉ាយ។<br>☐ ១. ទីធ្លានៅក្នុងថ្នាក់រៀនគ្មានការរៀបចំបានល្អ។ ថ្នាក់រៀនត្រូវបានប្រើសម្រាប់ស្តុកអីវ៉ាន់ ដូចជាតុមិនប្រើប្រាស់ ឈើ អង្ករ គ្រឿង ។ល។ តុរាយប៉ាយដែលមានថង់ និងចាននៅពីលើ។ |
| **បញ្ជីស្រង់វត្តមាន** | ☐ ៥. បញ្ជីស្រង់វត្តមានមានការកែលម្អ និងត្រឹមត្រូវ។<br>☐ ៤. បញ្ជីស្រង់វត្តមានភាគច្រើនត្រឹមត្រូវ និងមានការកែលម្អ។<br>☐ ៣. បញ្ជីស្រង់វត្តមានបានស្រង់វត្តមានរៀងរាល់ថ្ងៃ ប៉ុន្តែមិនត្រឹមត្រូវ។<br>☐ ២. បញ្ជីស្រង់វត្តមានថែរក្សាមិនបានល្អ។ ការស្រង់វត្តមានមិនបានស្រង់រៀងរាល់ថ្ងៃទេ។<br>☐ ១. គ្មានភស្តុតាងបញ្ជាក់អំពីបញ្ជីស្រង់វត្តមានទេ។ |

| **២. ការបង្រៀន** | |
|---|---|
| **វិធានសំខាន់ៗ** | **ការពិពណ៌នា** |
| **វត្ថុបំណង មេរៀន** | ☐ ៥. គ្រូពន្យល់ពីវត្ថុបំណងមេរៀន និងគ្រូតពិនិត្យតាមដានគ្រប់មេរៀន។ សិស្សយល់ពីវត្ថុបំណង មេរៀន។ វត្ថុបំណងមេរៀនគឺទទួលបានជោគជ័យ។<br>☐ ៤. គ្រូពន្យល់ពីវត្ថុបំណងមេរៀន។ សិស្សយល់ពីវត្ថុបំណងមេរៀន។ គ្រូត្រួតពិនិត្យតាមដានប្រសិនបើវត្ថុបំណងមេរៀនទទួលបានជោជ័យ។<br>☐ ៣. គ្រូពន្យល់ពីវត្ថុបំណងមេរៀន។ សិស្សភាគច្រើនយល់ពីវា។ ទាំងនេះគ្មានការត្រួតពិនិត្យ តាមដាន ដូច្នេះវាគ្មានភាពច្បាស់លាស់ទេប្រសិនបើវត្ថុបំណងមេរៀនទទួលបានជោគជ័យនោះ។<br>☐ ២. វត្ថុបំណងមេរៀនគឺមិនច្បាស់សម្រាប់គ្រូនិងសិស្សទេ។ គ្រូគ្មានការត្រួតពិនិត្យតាមដានការសិក្សារបស់សិស្ស។ វត្ថុបំណងមេរៀនគឺមិនទទួលបានជោគជ័យ។<br>☐ ១. គ្រូគ្មានវត្ថុបំណងមេរៀនសម្រាប់សិស្ស។ |
| **កិច្ចតែងការ បង្រៀន** | ☐ ៥. កិច្ចតែងការបង្រៀនរៀបតាមលំដាប់លំដោយ ហើយច្បាស់។ ផែនការធ្វើតាមមេរៀន ទាំងមូល។<br>☐ ៤. គ្រូមានកិច្ចតែងការបង្រៀនច្បាស់លាស់។ ផែនការអនុវត្តតាមមេរៀនភាគច្រើន។<br>☐ ៣. គ្រូបានបំពេញកំណែទម្រង់កិច្ចតែងការបង្រៀន។ គ្រូមិនអនុវត្តតាមផែនការមេរៀនទាំងមូល។<br>☐ ២. គ្រូបានបញ្ចប់កិច្ចតែងការបង្រៀន។ គ្រូមិនអនុវត្តតាមផែនការ។<br>☐ ១. គ្មានកិច្ចតែងការបង្រៀនទេ។ |

| | |
|---|---|
| **សិស្សរៀនយឺត** | ☐ ៥. គ្រូមានផែនការដើម្បីគាំទ្រដល់សិស្សរៀនយឺតនៅក្នុងថ្នាក់រៀន និងប្រើប្រាស់វា។<br>☐ ៤. គ្រូស្គាល់សិស្សរៀនយឺត និងមានផែនការជួយពួកគេ។<br>☐ ៣. គ្រូស្គាល់សិស្សរៀនយឺត។ គាត់គ្មានផែនការដើម្បីជួយពួកគេទេ។<br>☐ ២. គ្រូស្គាល់សិស្សរៀនយឺតមួយចំនួននៅក្នុងថ្នាក់រៀន ប៉ុន្តែមិនដឹងថាតើត្រូវផ្តល់ជំនួយបន្ថែមដោយរបៀបណា។<br>☐ ១. គ្មានការគាំទ្រដល់សិស្សរៀនយឺត ឬលើកសរសើរពួកគេទេ។ |

| | |
|---|---|
| **សម្ភារបង្រៀន (គ្រូប្រើប្រាស់)** | ☐ ៥. គ្រូប្រើសម្ភារបង្រៀនបានត្រឹមត្រូវដើម្បីគាំទ្រវត្ថុបំណងមេរៀន។<br>☐ ៤. គ្រូប្រើសម្ភារបង្រៀន ហើយសម្ភារទាំងនោះទាក់ទងទៅនឹងវត្ថុបំណងមេរៀន។<br>☐ ៣. គ្រូប្រើសម្ភារបង្រៀន ប៉ុន្តែសម្ភារទាំងនោះមិនសំខាន់។ សម្ភារទាំងនោះគ្មានប្រសិទ្ធិភាពដើម្បីគាំទ្រដល់វត្ថុបំណងមេរៀនទេ។<br>☐ ២. គ្រូបានជ្រើសរើសសម្ភារដែលត្រឹមត្រូវទៅសម្រាប់មេរៀន។ សម្ភារទាំងនោះមិនគាំទ្រដល់ វត្ថុបំណងមេរៀនទេ។<br>☐ ១. គ្រូមិនបានប្រើសម្ភារបង្រៀនពេលវាចាំបាច់នោះទេ។ |
| **លំហាត់ធ្វើក្នុងថ្នាក់** | ☐ ៥. លំហាត់ធ្វើក្នុងថ្នាក់មានវត្ថុបំណងច្បាស់លាស់ ហើយវត្ថុបំណងគាំទ្រដល់វត្ថុបំណងមេរៀន។ កិច្ចការក្នុងថ្នាក់ផ្សាភ្ជាប់ទៅនឹងសមត្ថភាពខុសៗគ្នារបស់សិស្ស។<br>☐ ៤. លំហាត់ធ្វើក្នុងថ្នាក់គឺត្រឹមត្រូវទៅនឹងវត្ថុបំណងមេរៀន។ វាមានវត្ថុបំណងច្បាស់លាស់។ សិស្សភាគច្រើនអាចសម្រេចកិច្ចការបាន។<br>☐ ៣. លំហាត់ធ្វើក្នុងថ្នាក់មិនត្រឹមត្រូវចំពោះវត្ថុបំណងមេរៀនទេ ប៉ុន្តែវាមានវត្ថុបំណង។ សិស្សភាគច្រើនអាចបំពេញលំហាត់ធ្វើក្នុងថ្នាក់បាន។<br>☐ ២. សិស្សភាគច្រើនអាចបំពេញលំហាត់ធ្វើក្នុងថ្នាក់បាន។ កិច្ចការសាលាបានផ្សាភ្ជាប់ទៅនឹង វត្ថុបំណងមេរៀនទេ។ វត្ថុបំណងមិនច្បាស់លាស់។<br>☐ ១. កិច្ចការសាលាមិនត្រឹមត្រូវចំពោះវត្ថុបំណងមេរៀន ហើយគ្មានវត្ថុបំណងទេ។ សិស្សមិនអាចធ្វើលំហាត់ធ្វើក្នុងថ្នាក់បាន។ |
| **សំណួរ របស់គ្រូ** | ☐ ៥. គ្រូប្រើសំណួរសម្រាប់គោលបំណងផ្សេងៗ ឧទាហរណ៍ ការតាមដានការយល់របស់សិស្ស និងចម្រាញ់ព័ត៌មានពីសិស្ស។<br>☐ ៤. គ្រូប្រើសំណួរដើម្បីតាមដានការយល់របស់សិស្ស និងតាមដានចម្លើយរបស់សិស្ស។<br>☐ ៣. គ្រូប្រើសំណួរដើម្បីតាមដានការយល់របស់សិស្ស ប៉ុន្តែមិនអាចតាមដានចម្លើយរបស់សិស្សបាន។<br>☐ ២. គ្រូសួរសំណួរទៅសិស្ស ប៉ុន្តែសំណួរមិនបានតាមដានការយល់របស់សិស្សទេ។ សិស្សមិនចំណាយពេលដើម្បីឆ្លើយសំណួរឲ្យបានពេញលេញនោះទេ។<br>☐ ១. គ្រូមិនប្រើសំណួរទេ។ |

| | |
|---|---|
| **ការរំពឹងទុក/ ចំណាប់ អារម្មណ៍** | ☐ ៥. គ្រូមានការរំពឹងទុកខ្ពស់សម្រាប់ភាពជោគជ័យរបស់សិស្ស។<br>☐ ៤. គ្រូមានការរំពឹងទុកសម្រាប់ភាពជោគជ័យរបស់សិស្ស។<br>☐ ៣. គ្រូមានការរំពឹងទុកខ្លះសម្រាប់ភាពជោគជ័យរបស់សិស្ស។<br>☐ ២. គ្រូមានការរំពឹងទុកតិចតួចសម្រាប់ភាពជោគជ័យរបស់សិស្ស។<br>☐ ១. គ្រូគ្មានការរំពឹងទុកសម្រាប់ភាពជោគជ័យរបស់សិស្ស។ |

| **៣. ការរៀន** | |
|---|---|
| *វិធានសំខាន់ៗ* | **ការពិពណ៌នា** |
| **សម្ភារសិក្សា (សម្រាប់សិស្សប្រើប្រាស់)** | ☐ ៥. សិស្សទាំងអស់ប្រើសម្ភារសិក្សានៅពេលចាំបាច់ចំពោះការផ្តួចផ្តើមសកម្មភាពផ្ទាល់ខ្លួន របស់ពួកគេ។<br>☐ ៤. សិស្សទាំងអស់ប្រើសម្ភារសិក្សាដើម្បីសម្របសម្រួល ប៉ុន្តែប្រើតម្រូវតាមមេរៀនតែប៉ុណ្ណោះ។<br>☐ ៣. សិស្សភាគច្រើនប្រើសម្ភារសិក្សាក្នុងពេលខ្លះ។<br>☐ ២. សិស្សកម្រប្រើសម្ភារសិក្សាណាស់។<br>☐ ១. សិស្សមិនបានប្រើសម្ភារសិក្សាដែលអាចជួយសម្របសម្រួលពួកគេបាននោះទេ។ |
| | ☐ ៥. សិស្សទាំងអស់ចូលរួមសកម្មនៅក្នុងការងារក្រុមផ្សេងៗគ្នាៈ បុគ្គល ដៃគូ ក្រុមតូច និងថ្នាក់ ទាំងមូល។ ការងារក្រុមមានទំនាក់ទំនងទៅនឹងវត្ថុបំណងនៃកិច្ចការក្នុងថ្នាក់ និងវត្ថុបំណង មេរៀន។ |
| | ☐ ៤. សិស្សធ្វើការងារក្រុមផ្សេងៗគ្នា ជាពិសេសចូលរួមធ្វើកិច្ចការក្នុងថ្នាក់។ ការងារក្រុមមានទំនាក់ទំនងទៅនឹងវត្ថុបំណងនៃកិច្ចការក្នុងថ្នាក់ និងវត្ថុបំណងមេរៀន។ |
| **ការងារក្រុម** | ☐ ៣. សិស្សធ្វើការក្នុងក្រុមប៉ុន្តែមិនមែនសមាជិកក្រុមទាំងអស់បានចូលរួមធ្វើកិច្ចការក្នុងថ្នាក់នោះ។ ក្រុមប្រហែលជាមានធំហឹធំពេក។ ការងារក្រុមមានទំនាក់ទំនងទៅនឹងវត្ថុបំនងនៃកិច្ចការក្នុងថ្នាក់ និងវត្ថុបំណងមេរៀន។ |
| | ☐ ២. សិស្សអង្គុយនៅក្នុងក្រុម ប៉ុន្តែធ្វើការជាបុគ្គល។ ការងារក្រុមគ្មានទំនាក់ទំនងទៅនឹងវត្ថុបំណងនៃកិច្ចការក្នុងថ្នាក់ទេ ប៉ុន្តែវាមានទំនាក់ទំនងទៅនឹងវត្ថុបំណងមេរៀន។ |
| | ☐ ១. សិស្សនៅក្នុងក្រុមតែមួយ ពេលដែលច្រើនក្រុមច្រើនប្រសើរជាងមួយក្រុម។ ការងារក្រុមគ្មានទំនាក់ទំនងទៅនឹងវត្ថុបំណងនៃកិច្ចការក្នុងថ្នាក់។ |
| **សំណួររបស់សិស្ស** | ☐ សិស្សសួរសំណួរសម្រាប់គោលបំណងផ្សេងៗទៅគ្រូ និងសិស្សផ្សេងៗទៀត។ សិស្សមានការ គាំទ្រសម្រាប់ការសួរសំណួររបស់ពួកគេ។ |
| | ☐ ៤. សិស្សសួរសំណួរជាជំនួយ និងបញ្ជាក់សិស្សផ្សេងទៀត និងគ្រូ។ |
| | ☐ ៣. សិស្សមួយចំនួនសួរសំណួរដូច្នេះពួកគេអាចយល់បានច្រើន។ |
| | ☐ ២. សិស្សកម្រសួរសំណួរដើម្បីបញ្ជាក់មេរៀន និងលំហាត់ធ្វើក្នុងថ្នាក់។ |
| | ☐ ១. សិស្សគ្មានការលើកទឹកចិត្តដើម្បីសួរសំណួរ។ |
| **ការចូលរួម** | ☐ ៥. សិស្សបានចូលរួមយ៉ាងសកម្ម និងសប្បាយរីករាយ។ |

| | |
|---|---|
| | ☐ ៤. សិស្សភាគច្រើនបានចូលរួម និងមានចំណាប់អារម្មណ៍។ |
| | ☐ ៣. សិស្សមួយចំនួនមានចំណាប់អារម្មណ៍ប៉ុន្តែមិនបានចូលរួមសកម្មនៅក្នុងមេរៀនទេ។ |
| | ☐ ២. សិស្សមួយចំនួនបានចូលរួមពេលខ្លះ ប៉ុន្តែសិស្សភាគច្រើនគ្មានការលើកទឹកចិត្តទេ។ |
| | ☐ ១. សិស្សគ្មានការចូលរួមនៅក្នុងមេរៀន។ ពួកគេគ្មានការលើកទឹកចិត្ត ឬ ចំណាប់អារម្មណ៍ទេ។ |
| **ការផ្តល់ព័ត៌មាន ត្រឡប់ទៀងទាត់ អំឡុង ម៉ោងសិក្សា** | ☐ ៥. គ្រូផ្តល់ព័ត៌មានត្រឡប់ទៀងទាត់លើការរីកចំរើនរបស់ពួកគេចំពោះមេរៀន។ គ្រូត្រួតពិនិត្យតាមដានមេរៀនទាំងមូលចំពោះការយល់របស់សិស្ស កំណែទម្រង់ការចែកចាយដែលត្រឹមត្រូវ។ |
| | ☐ ៤. សំណួរត្រូវបានប្រើនៅក្នុងថ្នាក់ដើម្បីស្វែងរកអ្វីដែលសិស្សបានរៀនរួចហើយ។ មូលវិចារលើការងាររបស់សិស្សត្រូវបានលើកទឹកចិត្ត។ |
| | ☐ ៣. គ្រូសួរសំណួរ ប៉ុន្តែពួកគេតែងតែមិនពន្យល់ទៅសិស្សថាហេតុអ្វីបានជាចម្លើយរបស់គេល្អ ឬ មិនល្អនោះ។ |
| | ☐ ២. គ្រូមិនបានតាមដានការយល់របស់សិស្សអំឡុងម៉ោងសិក្សាទេ។ |
| | ☐ ១. សិស្សទទួលបានតិចតួច ឬគ្មានព័ត៌មានត្រឡប់។ |

| | |
|---|---|
| | ☐ ៥. សៀវភៅសរសេរទាំងអស់របស់សិស្សមានគម្រប និងស្អាត។ គ្រូផ្តល់ការណែនាំច្បាស់ចំពោះការរៀបចំសៀវភៅសរសេររបស់សិស្ស។ គ្រូដាក់ពិន្ទុ និងមូលវិចារលើការងារសរសេរ របស់សិស្ស។ |
| | ☐ ៤. សៀវភៅសរសេរសិស្សភាគច្រើនបានថែទាំលើៈ គម្រប និងស្អាត។ គ្រូផ្តល់ការណែនាំច្បាស់ចំពោះការរៀបចំសៀវភៅសរសេររបស់សិស្ស។ គ្រូដាក់ពិន្ទុ និងមូលវិចារលើសៀវភៅសរសេរទៀងទាត់ប៉ុន្តែគ្មានមូលវិចារនោះទេ។ |
| **សៀវភៅសរសេររបស់សិស្ស** | ☐ ៣. សៀវភៅសរសេរភាគច្រេនបានថៃទាំលើៈ គម្រប និងស្អាត ប៉ុន្តែមាតិការៀបចំមិនច្បាស់។ គ្រូដាក់ពិន្ទុទៀងទាត់លើសៀវភៅសរសេរ។ |
| | ☐ ២. សៀវភៅសរសេរមិនបានថៃទាំលើៈ គ្មានគម្រប និងកខ្វក់។ នេះជាភស្តុតាងខ្លះៗនៃការដាក់ពិន្ទុរបស់គ្រូ។ |
| | ☐ ១. សៀវភៅសរសេរភាគច្រើនមិនបានថៃទាំលើៈគ្មានគម្រប និងកខ្វក់។ គ្មានភស្តុតាងអំពីការដាក់ពិន្ទុរបស់គ្រូ។ |
| **លំហាត់ធ្វើនៅផ្ទះ** | ☐ ៥. លំហាត់ធ្វើនៅផ្ទះគឺមានគោលបំណងច្បាស់លាស់ និងគាំទ្រដល់វត្ថុបំណងមេរៀន។ លំហាត់ធ្វើនៅផ្ទះជាការងារមិនទាន់បញ្ចប់ ឬជាសកម្មភាពបន្ថែម។ លំហាត់ធ្វើនៅផ្ទះគឺត្រឹមត្រូវ និងមានមូលវិចារបញ្ជាក់។ |
| | ☐ ៤. លំហាត់ធ្វើនៅផ្ទះគឺគាំទ្រដល់វត្ថុបំណងមេរៀន និងមានគោលបំណងច្បាស់លាស់។ លំហាត់ធ្វើនៅផ្ទះគឺត្រឹមត្រូវ ប៉ុន្តែគ្មានមូលវិចារនោះទេ។ |
| | ☐ ៣. លំហាត់ធ្វើនៅផ្ទះគឺមានទំនាក់ទំនងទៅនឹងវត្ថុបំណងមេរៀន ប៉ុន្តែវាគ្មានគោលបំណងច្បាស់លាស់នោះទេ។ លំហាត់ធ្វើនៅផ្ទះគឺមិនត្រឹមត្រូវនោះទេ។ |
| | ☐ ២. លំហាត់ធ្វើនៅផ្ទះត្រូវបានប្រគល់ ប៉ុន្តែពុំមានទំនាក់ទំនងនឹងវត្ថុបំណងមេរៀនទេ។ វាមិនត្រឹមត្រូវនោះទេ។ |

| | |
|---|---|
| | ☐ ១. សិស្សមិនទទួលបានលំហាត់ធ្វើនៅផ្ទះនោះទេ។ |